# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣២ លេខ ៤ ខែមេសា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| - ពុទ្ធជីវប្បវត្តិ ព្រះមហា ប៉ាង.ខាត់ រៀបរៀង | | ៣៦១ |
| - ព្រះអភិធម្មបិដក (គម្ពីរបុគ្គលបញ្ញត្តិ) (តមក) លោក ប៊ូ-ប៉ូ រៀបរៀង | | ៣៧៧ |
| - មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឿន ពិនិត្យ | | ៣៨៩ |
| - មហោសថជាតក (តមក) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-ឌួរ ពិនិត្យ | | ៤០៤ |
| - ប្រវត្តិព្រះនាងឥសិទាសីថេរី លោក យូ-អ៊ុង ប្រែចាកភាសាបាលី | | ៤១៣ |

**ផ្នែកអក្សរសាស្ត្រ**

| | | |
|---|---|---|
| - រឿងមរណមាតា (តមក) លោក ប៉ំ-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត | | ៤២៣ |
| - រឿងព្រេងប្រទេសស៊ុយអែដ ភិក្ខុ ម៉ែន-វៀម ប្រែចាកភាសាអង់គ្លេស | | ៤៣១ |
| - ស្នាដៃទីពុក លោក ស៊ុន-ធី រៀបរៀង លោក ចាប.ពិន ពិនិត្យ | | ៤៣៨ |
| - រឿងសាមកុក (តមក) ទកញ៉ា ឡូ-កន ប្រែ | | ៤៥៧ |
| - ពាក្យវេជ្ជធម៌ (តមក) លោក នាង-ហ៊ួ រៀបរៀង លោក សម-ថាំង ពិនិត្យ | | ៤៦១ |

**ផ្នែកកំណត់ទីងប្រវត្តិការណ៍**

| | | |
|---|---|---|
| - មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យលើកទី ១១ លោក វ៉ាយ-ប៊ុក រៀបរៀង | | ៤៦៨ |
| - វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង | | ៤៨០ |

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃផ្សាវ ២៣០រ០០

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
Publiée par l'Institut Bouddhique de Phnom Penh

## sommaire

### Partie religieuse :

— La Vie du Buddha par Prah maha PANG-KHAT . . . 361
— Prah Abhidhammapitaka (Puggalappannatti) (suite) par M. BOU-PO 377
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par Vén-NHEAN CHHOEUN . . . . . . . . . . . . 389
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON' revu par Vén-KEM-TO 404
— L'histoire de Prah Neang Isidasi theri traduite du pali par M. YOU-OUN . . . . . 413

### Partie littéraire :

— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 423
— Contes et Légendes suédois traduits de l'anglais par le bonze MEN RIEM . . . 431
— L'oeuvre du père par M. SIN-PHO revu et corrigé par M. CHAP-PIN . . . . . . 438
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 457
— Activités de la Commission culturelle par M. NEANG-HU revues et corrigées par M. SAM-THANG. . . . 461

### Notes et Chroniques :

— Onzième assemblée générale de l'Association des Amis du Lycée bouddhique par M. RAY BUC. . . . . 468
— Dictionnaire Sanscrit-khmer (suite) par Vén-PANG-KHAT 480

---

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

# ពុទ្ធជីវប្បវត្តិ

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

## ជម្ពូទ្វីប

តាំងពីបុរាណកាល ភូមិប្រទេសដ៏ធំទូលាយ មានអារ្យធម៌ចម្រើនបរិបូណ៌ ជាទីប្រជុំកើតមេសាសនាធំៗ ដូចព្រាហ្មណសាសនា ពុទ្ធសាសនាជាដើម ជាទីកើតចំណេះវិជ្ជា ប្រពៃណី រឿនទំទានផ្សេងៗ ផ្សាយទូទៅពេញសកលលោក នៅក្នុងកាលបច្ចុប្បន្ននេះហៅថាឥណ្ឌៀ។

កាលដើមឡើយ គេមិនហៅថាឥណ្ឌៀទេ គេហៅថាភារតវិប ឬជម្ពូទ្វីប, ពាក្យថា ឥណ្ឌៀនេះ ក្លាយចេញមកពីពាក្យដើមថា សិន្ធុ ជាឈ្មោះទន្លេធំមួយ ជាគោលចារឹកសំខាន់នៅភាគខាងលិចប្រទេសឥណ្ឌៀសព្វថ្ងៃនេះ ។ អ្នកអស្តង្គតប្រទេស កាលគេមកកាន់ជម្ពូទ្វីប បានស្គាល់ទន្លេនេះមុន តែគេហៅឈ្មោះទន្លេមិនច្បាស់ ក៏ហៅក្លាយទៅជាឥណ្ឌុស (Indus) វិញ ។ ពាក្យថាឥណ្ឌុសនេះ បានយាក្លាយមួយលើកទៀតទៅជាពាក្យថាឥណ្ឌៀ (India) ក្នុងបច្ចុប្បន្ននេះ ។ លោកទាំងមូលសព្វថ្ងៃបបួលគ្នាហៅប្រទេសនេះថា ឥណ្ឌៀ ឬឥណ្ឌុស្ថាន (Hindoustan) ។

## ប្រជាជនឥណ្ឌៀ

ពីសម័យបុរាណ គេចែកជម្ពូទ្វីបជា ២ ជនបទធំៗគឺ មជ្ឈិមជនបទ១

បច្ចន្តជនបទ១ ។ ការបែកជា២នេះ មានមកយូរអង្វែងហើយ តាមទំនង ប្រហែលជាបែកកាលជំនាន់ពួកអរិយកៈ ដែលលុកលុយចូលមកប្រទេសឥណ្ឌា ។ កាលនោះមានរឿងដំណាលថា ពួកអរិយកៈតាំងទីឋាននៅទីខ្ពង់រាបបព៌្វតាប៉ាមីរ (Pamir) ដែលជាដំបូលពិភពលោក ជាពោលកាកកើត អរិយកជន មានជាតិភូមិនៅអុកសុស ( Oxus) ភូមិភាគកូកាស (Caucase) ។ បំណោរមក ពួកអរិយកជននេះ ជាពួកពនេចរធ្វើដំណើរចេញពីទីឋានកំណើតរបស់ខ្លួនទៅកាន់ទីឋានផ្សេងៗ នៃពិភពលោក ដើម្បីតាំងឋានលំនៅអាស្រ័យចិញ្ចឹមជីវិត ។ ដំណើរពនេចរនេះ កើតទៅជាប្រពៃណីប្រទេសឥណ្ឌាដែលមានប្រាកដក្នុងនិទានជាតកផ្សេងៗ ថា ព្រះរាជាអង្គនោះ មានព្រះអគ្គមហេសី មានព្រះរាជបុត្រព្រះរាជធីតា, លុះព្រះអគ្គមហេសីទ្រង់ទិវង្គតទៅ ព្រះរាជាទ្រង់លើកព្រះនាងដទៃទៀតទុកក្នុងឋានៈជាអគ្គមហេសី បើមានព្រះរាជបុត្រ ព្រះអគ្គមហេសីអង្គនេះ តែងតែចូលទៅគាល់ព្រះរាជស្វាមី ហើយសូមព្រះរាជ្យថ្វាយព្រះរាជបុត្ររបស់ខ្លួន ឯព្រះរាជាតែងតែភ្លាត់ព្រះឱស្ឋថ្វាយរាជ្យដល់ព្រះរាជបុត្រអង្គ ជាអនុជនេះជាធម្មតា ហើយតែងតែត្រាស់បញ្ជូនព្រះរាជបុត្រព្រះរាជធីតាច្បងៗឲ្យទៅសាងរាជធានីថ្មីតាមគាប់ចិត្ត ។ រឿងភ្លាត់ព្រះឱស្ឋនេះ មិនមែនជាការភ្លាត់ធម្មតាទេ គឺជាប្រពៃណីរបស់ព្រះរាជា ដែលទ្រង់មានព្រះរាជបំណងនឹងពង្រីកព្រះរាជាណាចក្រព្រះអង្គឲ្យធំទូលាយទៅទៀត ។

រឿងនេះកើតចេញពីពួកអរិយកជន ក្នុងកាលដែលធ្វើដំណើរទៅកាន់ទិសផ្សេង ៗ តាមប្រវត្តិសាស្ត្រ យើងបានដឹងថា អរិយជននេះបែកសាខាធំ២ មួយទៅខាងលិចទៅខាងអឺរ៉ុប មួយទៅខាងកើតទៅខាងអាស៊ី ៗ ពួកនេះគេហៅថាអរិយៈ ខ្លះសរសេរថា អារ្យៈ អរិយ៉េន ឬអរ្យ៉ែន ឬក៏អារ្យ៉ែន (f. Aryas ou Aryens; A. Aryan) ពួកអរិយៈនេះហើយជាបុព្វបុរសនៃត្រកូលធំដែលហៅថា ហិណ្ឌូ-អឺរ៉ុប ឬហិណ្ឌូ-អរ្យ៉ែន ។ សាខាអរិយៈធំមួយ ដែលពនេចរទៅខាងកើត ក៏បានទៅអាស្រ័យនៅប្រទេសឥណ្ឌា ហើយបែងចែកភូមិប្រទេសឥណ្ឌាឲ្យទៅជាពីរដូច្នេះ ឲ្យឈ្មោះទីខ្លួនទៅថា មជ្ឈិមជនបទ ឲ្យឈ្មោះទីអ្នកនៅដើមថា បច្ចន្តិមជនបទ តែមជ្ឈិមជនបទនេះ មានសីមាព្រំប្រទល់មិនប្រាកដទៀងទាត់ទេ ជួនកាលរីកធំទៅ ជួនកាលរួញតូចមកវិញ តាមជំនាន់ពេលដែលមានអំណាចតិចច្រើន ។ បើនិយាយក្នុងសម័យពុទ្ធកាល មានសេចក្តីមួយបទក្នុងគម្ពីរមហាវគ្គ ចម្មក្ខន្ធកថា:(១)

“ម្នាលភិក្ខុទាំងឡាយ! បច្ចន្តិមជនបទនោះគឺ ទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងណាយកជង្គលនិគមនោះមាននិគមឈ្មោះមហាសាល ខាងណាយនិគមឈ្មោះមហាសាល

១ មហាវគ្គ ចម្មក្ខន្ធកៈ សៀ.៣ ទំព័រ២១៤ ។

នោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះ សល្លវតី ខាងនាយស្ទឹងឈ្មោះសល្លវតីនោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះ សេតកណ្ណិក ខាងនាយនិគមនោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍មួយឈ្មោះ ថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងនាយភ្នំនោះទៅជា បច្ចន្តិមជនបទ ខាងអាយចូលមកជា មជ្ឈិមជនបទ" ។

*បើនិយាយតាមភូមិសាស្ត្រ គេបែកជា២ដូច្នេះគឺៈ*

*ក)កាយាវតី បិតៈនៅចន្លោះភ្នំហិមាល័យនិងភ្នំវិន្ធ្យា ដែលហៅសព្វថ្ងៃនេះថា ហិណ្ឌូស្ថាន គឺប្រទេសនៅភាគខាងជើង;*

*ខ)ទក្ខិណាបថ បានដល់ទីឋានដែលហៅសព្វថ្ងៃនេះថា ដេកន៍*

(Dekkan) គឺប្រទេសឥណ្ឌាភាគខាងត្បូង ។

តាមដំណើរនិទាននេះ យើងឃើញថា " អរិយជន " នេះមិនមែនជាអ្នកដើមកំណើតប្រទេសឥណ្ឌាទេ ឯអ្នកដើមកំណើតប្រទេសនោះ ជាជាតិមួយឈ្មោះ ទ្រាវិឌ ជាជនធ្លាប់មានអរិយធម៌ខ្ពង់ខ្ពស់ ហើយមិនចុះចាញ់អរិយជនដែលចូលមកថ្មីនោះទេ ។ តាមប្រវត្តិសាស្ត្រលោកថា ជនទ្រាវិឌដែលស៊ូទ្រាំចិត្តចាញ់អរិយជននោះ ដោយខ្លួនមិនចេះធ្វើកង់ចក្រ (១) សម្រាប់ចូលតយុទ្ធក្នុងសង្គ្រាមប៉ុណ្ណោះ ឯពួកអរិយជនចេះធ្វើរថមានកង់កាំទឹមសេះ ហើយចេះបរចូលតយុទ្ធសង្គ្រាម ។ លុះពួកអរិយជនមានជ័យហើយក៏តាំងឋានទីលំនៅ រកស៊ីចិញ្ចឹមជីវិត ចែកភូមិប្រទេសឥណ្ឌាជាបច្ចិមជនបទនិងមជ្ឈិមជនបទផ្សេងៗ មិនតែប៉ុណ្ណោះទេ ដើម្បីកុំឲ្យលាយជាតិខ្លួន ពួកអរិយជនបានចែកបាន មនុស្សជាជាន់ថ្នាក់ទៀត ដូចមានសេចក្តីប្រាកដថា

" ព្រះព្រហ្មយកមាត់មកសាងជាព្រាហ្មណ៍ យកដើមដៃមកសាងជា

---

១ អ្នកប្រាជ្ញប្រវត្តិសាស្ត្រយល់ថា ពួកអរិយៈចេះធ្វើកង់មុនគេ ដោយយកទេពតាសុរិយមកប្រតិស្ឋមុនដំបូង ហើយតមក កង់នេះកើតទៅជាព្រះសីលធម៌ ច្បាប់ ពុំនេះជាត្រាគ្រឿងសំគាល់សេចក្តីចំរើនដែលហៅថា ស្វស្តិកៈ 卐 ។ ព្រះពុទ្ធជាម្ចាស់យើង ក៏ទ្រង់យកចក្រជាសីលធម៌ដែរ ដូចទ្រង់ប្រកាសធម្មចក្កប្បវត្តនសូត្រ។ពុទ្ធសាសនាលទ្ធិមហាយានធ្លាក់ស្វស្តិកៈនេះ នៅលើព្រះឧរព្រះពុទ្ធរូប ។ ព្រះបាទអសោកមហារាជ ក៏យកចក្រនេះធ្វើត្រា គឺជាអំណាចរបស់ព្រះអង្គដែរ ។

ក្សត្រ យកភ្លៅមកសាងជាវេស្សៈ យកបាទដើងមកសាងជា សុទ្ទៈ(អ្នកគ្រួអ្នកស៊ីឈ្នួល ) ហើយបញ្ញត្តគ្រឿងស្លៀកពាក់ឲ្យមានពណ៌ខុសគ្នា គឺព្រាហ្មណ៍ស្លៀកពាក់ពណ៌ស, ក្សត្រស្លៀកពាក់ពណ៌ក្រហម; វេស្សៈស្លៀកពាក់ពណ៌លឿង, សុទ្ទៈស្លៀកពាក់ពណ៌ខ្មៅ " ។

ដោយហេតុនេះ ជាន់ថ្នាក់មនុស្ស ទើបហៅថា "វណ្ណ" (១) ។ តាមតួព្យញ្ជនៈ ពាក្យថាវណ្ណៈនេះប្រែថា «ពណ៌» ព្រោះយកគ្រឿងស្លៀកពាក់មានពណ៌ខុសគ្នាជាគ្រឿងសំគាល់ តែក្នុងបច្ចុប្បន្នកាលនេះ ពាក្យថា វណ្ណៈ ប្រែថា „ភេទ" ទៅតាមន័យឥឡូវនេះវិញ (ឬថា ពួកអរិយៈជាស្បែកស ជនទ្រាវិឌជាស្បែកខ្មៅ ) ។ កាលពួកអរិយៈបានជាធំនៅលើផែនដីនេះហើយ ចាប់យកអ្នកដើមកំណើតប្រទេស ដែលឈ្មោះថាទ្រាវិឌនោះមកធ្វើឈ្លើយរបស់ខ្លួន ហើយហៅថា ទស្យុ ប្រែថា "សត្រូវរបស់ព្រះឥន្ទ្រ" ព្រោះព្រះឥន្ទ្រជាទេវតារបស់ខ្លួន ឬថា ឈ្លើយ តមកពាក្យថា ទស្យុ នេះ ក្លាយទៅជាទាសៈប្រែថា „ខ្ញុំ" ទៅវិញ ដូចសព្វថ្ងៃនេះ ។ មួយទៀត ពួកអរិយជន ហៅជនទ្រាវិឌថា មិលក្ខុ ប្រែថា អ្នកស្រុកក្តុំ ទៅជា «អ្នកព្រៃ» វិញ ជាការបន្តោកបន្ទាបមើលងាយ។

ព្រះសម្មាសម្ពុទ្ធនៃយើងទ្រង់យកកំណើតក្នុងត្រកូលក្សត្រ អរិយក-

១-អម្ពដ្ឋសូត្រ ទីឃ. សៀវ. ១៤ ទំព័រ ២២៦ ។

ជាតិ កាលទ្រង់បានត្រាស់ដឹងជាអង្គព្រះសម្មាសម្ពុទ្ធហើយ ទ្រង់ពុទ្ធដំណើរប្រោសវេនេយ្យសត្វ តែក្នុងប្រទេសឥណ្ឌាភាគខាងជើង ដែលហៅថា អារ្យាវត្ត បានជាមានរឿងនិយាយច្រើន តែបែកខាងជើងជាងខាងត្បូង ។

ដែនទាំងឡាយទាំងតូចទាំងធំ ក្នុងសម័យពុទ្ធកាលមាន ៣៥ ដែន

១– ដែន អង្គៈ រាជធានី ចម្ប៉ា
២ „ មគធៈ „ រាជគ្រឹះ
៣ „ កាសី „ ពារាណសី
៤ „ កោសល „ សាវត្ថី
៥ „ វជ្ជី „ វេសាលី
៦ „ មល្លៈ „ កុសាវតី (តមកបែកជា២គឺកុសិនារា និងបាវ៉ា)
៧ „ ចេតីយ „ សោត្ថិវតី
៨ „ វង្សៈ „ កោសម្ពី
៩ „ កុរុ „ ឥន្ទបត្ត
១០ „ បញ្ចាល „ កម្បិលៈ
១១ „ មច្ឆៈ „ សាគលៈ

| | | | | |
|---|---|---|---|---|
| ១២ | ដែន | សុរសេនៈ | រាជធានី | មធុរា |
| ១៣ | " | អស្សកៈ | " | ពោតលិ |
| ១៤ | " | អវន្តី | " | ឧជ្ជេនី |
| ១៥ | " | គន្ធារៈ | " | តក្កសិលា |
| ១៦ | " | កម្ពោជៈ | " | ទ្វារកៈ |
| ១៧ | " | សក្កៈ | " | កបិលវត្ថុ |
| ១៨ | " | កោលិយៈ | " | ទេវហៈឬ រាមគ្រាម |
| ១៩ | " | ភគ្គៈ | " | សុង្សុមារគិរៈ |
| ២០ | " | វិទេហៈ | " | មិថិលា |
| ២១ | " | អង្គុត្តរាបៈ | " | អាបណៈ ( ជានិគម ) |
| ២២ | " | សិវិ (១) | " | ( មិនប្រាកដ ) |
| ២៣ | " | សោវិរៈ | " | រោរុកៈឬ រារុវៈ |
| ២៤ | " | វិរាតៈ | " | ( មិនប្រាកដ ) |
| ២៥ | " | មទ្ទៈ | " | សាគលៈ |
| ២៦ | " | ទុក្រោនៈ | " | ( មិនប្រាកដ ) |

១. លោករិសដេវីដ (Rhys Davids) រកឃើញ ៣ រដ្ឋពីលេខ ២២ ដល់លេខ ២៨ (Pali English Dictionary Pali lext Sosiety) ។

២៧ រដ្ឋ ពូលិ រាជធានី អលកប្បៈ

២៨ ,, កាលាមៈ ,, កេសបុត្តៈ

២៩ ,, វង្គៈ (១) ,, (តាំងនៅបង្កាល់សព្វថ្ងៃ)

៣០ ,, មោរិយៈ (២) ,, បិប្ផលិវន

៣១ ,, សុហ្មៈ (៣) ,, បូរី

៣២ ,, សមតដ ,, (មិនប្រាកដ)

៣៣ ,, កាមរូប ,, (មិនប្រាកដ)

៣៤ ,, បុណ្ឌ្រ ,, (មិនប្រាកដ)

៣៥ ,, អាករៈ ,, វិទិសា ។

រដ្ឋដែលមានឥទ្ធានុភាពខ្លាំងជាងគេមាន ២ គឺ

ក) រដ្ឋកោសលជារដ្ឋធំទីមួយផ្សាយឥទ្ធានុភាពទៅលើរដ្ឋច្រើនមាន រដ្ឋកាសីជាដើម នឹងត្រកូល២គឺ ត្រកូលកោលិយ ទីក្រុងរាមគ្រាម ១ នឹងត្រកូលសក្កៈ ទីក្រុងកបិលពស្តុ ១ ។ រដ្ឋកោសលនេះ មានអាណាខែត្រធំទូលាយជាងរដ្ឋមគធៈ,

ខ) រដ្ឋមគធៈ ជារដ្ឋធំទីពីរ មានឥទ្ធានុភាពប៉ុនគ្នានឹងរដ្ឋកោសល

---

១ - លោកថោមាស (Ed. thomas) រកឃើញរដ្ឋមួយគឺលេខ ២៩ ។ ២- លោក ពិមលចរ័ន ឡ (Bimala Charan Law) រកបាន ១ គឺលេខ ៣០ ។ ៣ - លោក ល៊ី-ហ្វីណូត៍ (L. Finot) រកឃើញ ៥ រដ្ឋគឺលេខ ៣១ ទៅដល់លេខ ៣៥ ។

ដែរ តែក្រោយសម័យពុទ្ធកាល រដ្ឋមគធៈ វាយដណ្ដើមយករដ្ឋកោសលបាន ត្រឡប់ជាធំជាងរដ្ឋកោសលទៅវិញ ។

សម័យពុទ្ធកាល រដ្ឋទាំងឡាយនៅប្រទេសឥណ្ឌាច្រើនតែរួមចូលគ្នា ដូចជាដែនអង្គៈរួមនឹងដែនមគធៈ ព្រះបាទពិម្ពិសារជាស្ដេច ក្រុងរាជ-គ្រឹះជារាជធានី , ដែនកាសីរួមនឹងដែនកោសល ព្រះបាទបសេនទិជាស្ដេច ក្រុងសាវត្ថីជារាជធានី, ដែនវជ្ជីរួមនឹងដែនមល្លៈ,ដែនចេតិយរួមនឹងដែនវង្សៈ, ដែនកុរុរួមនឹងដែនបញ្ចាលៈ, ដែនមច្ឆៈរួមនឹងដែនសុរសេនៈជាដើម ។ ក្នុងសម័យបែកព្រះធាតុ យើងឃើញថា ដែនវជ្ជីនឹងមល្លៈផ្សេងរដ្ឋបាលគ្នា មិនមានស្ដេចសោយរាជ្យទេ មានតែនាយកត្រួតត្រា ។

ឯសក្កជនបទ ក្រុងកបិលពស្តុជាជាតិភូមិនៃព្រះបរមសាស្ដាចារ្យនៃយើងទាំងឡាយ ឋិតនៅទិសនិរតីប្រទេសនេប៉ាល់ ខាងជើងប្រទេសឥណ្ឌា ជារដ្ឋតូចមួយនៅក្រោមអំណាចព្រះបាទបសេនទិកោសលរាជ ។ កាលទ្រង់គង់ធរមាននៅឡើយ ក៏ទ្រង់មានព្រះពុទ្ធដីកា ត្រាស់ចំពោះវាសេដ្ឋៈថា [១]

„ម្នាលវាសេដ្ឋៈ! ព្រះរាជាបសេនទិកោសលជ្រាបថា ព្រះសមណគោតមជាបុគ្គលខ្ពង់ខ្ពស់ ចេញចាកសក្យត្រកូលមក

---

១. អគ្គញ្ញសូត្រ បាដិកវគ្គ ទីឃ. សៀវ. ១៨ ទំព័រ ១៦៨ ។

ទ្រង់ព្រះផ្នួស ពួកសក្យជាអ្នកនៅជិត នៅក្រោមអំណាចនៃព្រះបាទបសេនទិកោសល តែងធ្វើបដិសណ្ឋារៈ ធ្វើអភិវាទនកម្ម ក្រោកឡើងទទួលធ្វើអញ្ជលីកម្ម និងសាមីចិកម្មចំពោះព្រះរាជាបសេនទិកោសល ។ ម្នាលវាសេដ្ឋៈ! ពួកសក្យធ្វើបដិសណ្ឋារៈជាដើម ចំពោះព្រះរាជាបសេនទិកោសលយ៉ាងណា ព្រះរាជាបសេនទិកោសលធ្វើបដិសណ្ឋារៈជាដើមចំពោះតថាគត ( កាលតថាគតបួសហើយ) យ៉ាងនោះដែរ " ។

*មួយទៀត , កាលព្រះបរមពោធិសត្វទ្រង់ទើបបព្វជ្ជាថ្មី ៗ ទ្រង់បាទសន្ទនាទីវព្រះបាទពិម្ពិសារក្នុងក្រុងរាជគ្រឹះថា* (១)

"បពិត្រមហារាជ! ត្រង់ទៅមានជនបទមួយនៅប្របភ្នំហិមវន្ត ជាជនបទបរិបូណ៌ដោយទ្រព្យ និងអ្នកមានព្យាយាម អាស្រ័យនៅនឹងដែនកោសល មានជនមួយពួក ជាអាទិច្ចគោត្រ មានជាតិជាសាកិយៈ តថាគតបានចេញចាកត្រកូលនោះមកបួស"។

---

១- បព្វជ្ជាសូត្រ មហាវគ្គ សុត្តនិបាត សៀវ. ៥៥ ទំព័រ ១៣៤ ។

# ដើមកំណើតសក្យវង្ស

*កាលពីអតីតកាលយូរណាស់ហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទឧក្កាករាជ[១] សោយរាជសម្បត្តិក្នុងនគរមួយ លើកព្រះរាជភគិនីជាព្រះអគ្គមហេសី មានព្រះរាជបុត្រ ៤ ព្រះអង្គ[២] ។ លុះព្រះអគ្គមហេសីអង្គនេះទិវង្គតទៅ ព្រះរាជាលើកព្រះនាងដទៃទៀតជាព្រះអគ្គមហេសី មានព្រះរាជបុត្រ ១ អង្គ ព្រះនាមថាជន្តុ ដូចមានសេចក្ដីប្រាកដក្នុងអម្ពដ្ឋសូត្រថា[៣]*

"ម្នាលអម្ពដ្ឋ! កាលពីដើមមានព្រះរាជាព្រះនាមឧក្កាកៈ មានព្រះមហេសីជាទីស្រឡាញ់ ជាទីពេញព្រះទ័យ មានបំណងនឹងបង្វែររាជសម្បត្តិ ឲ្យព្រះរាជបុត្ររបស់ព្រះមហេសីអង្គនោះ ហើយក៏បង្វេះពួកព្រះរាជកុមារជាច្បង ៤ ព្រះអង្គ គឺព្រះរាជកុមារនាមឧក្កាកមុខៈ ១ ករណ្ឌុៈ ១ ហត្ថិនិកៈ ១ សិនិបុរៈ ១ ឲ្យចេញពីដែន ។ ព្រះរាជបុត្រទាំងនោះ លុះព្រះវរបិតាបង្វេះចេញអំពី

១. សំ ឥក្ស្វាកុ ។ ២. គម្ពីរជំនាន់ក្រោយថា «មានព្រះរាជធីតា ៥ អង្គគឺ បិយា សុប្បិយា អានន្ទា វិជិតា វិជិតសេនា ។ ៣- អម្ពដ្ឋសូត្រ ទីឃ. សៀវ ១៤ ទំព័រ២២៧ ។

ដែនហើយ ក៏នាំគ្នាទៅអាស្រ័យនៅក្នុងដងព្រៃឈ្មោះ មហាសាក ទៀបឆ្នេរស្រះបោក្ខរណីរជិតខាងហិមវន្តប្រទេស ។ ព្រះរាជបុត្រទាំងនោះ បានសម្រេចការរួមនៅជាមួយនឹងពួកព្រះភគិនីរបស់ខ្លួន ព្រោះខ្លាចក្រែងក្លាយខូចជាតិ ។

ម្នាលអម្ពដ្ឋ ! គ្រានោះ ព្រះបាទឧក្កាករាជបានត្រាស់ហៅពួកអាមាត្យមកសួរថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ! កុមារទាំងឡាយទៅនៅក្នុងទីណា ? រាជអាមាត្យក្រាបទូលថា ‹‹បពិត្រព្រះសម្មតិទេព ! មានដងព្រៃមួយឈ្មោះមហាសាក នៅទៀបឆ្នេរស្រះបោក្ខរណីខាងហិមវន្តប្រទេស ឥឡូវនេះ ព្រះរាជកុមារទៅនៅក្នុងទីដងព្រៃនោះ ព្រះរាជកុមារទាំងនោះ សម្រេចការនៅរួមជាមួយនឹងពួកព្រះភគិនីរបស់ខ្លួន ដោយហេតុខ្លាចក្រែងក្លាយខូចជាតិ ។

គ្រានោះ ព្រះបាទឧក្កាករាជបន្លឺឧទានវាចាថា ‹‹អើហ្ន៎! កុមារទាំងឡាយពេញជាអង់អាច អើហ្ន៎! កុមារទាំងឡាយ

ពេញជាមោះមុតមែន" ។

ម្នាលអម្ពដ្ឋ! ចាប់ដើមពីកាលនោះមក ពួកសក្យវង្សក៏កើតប្រាកដឡើង ។ ព្រះបាទឧក្កាករាជនោះហើយ ជាបុព្វបុរសរបស់ពួកសក្យៈ" ។

*ឯព្រះជេដ្ឋភគិនីមានព្រះទ័យប្រតិព័ទ្ធ នឹងព្រះរាជាក្រុងពារាណសី ហើយសម្រេចការនៅរួមជាមួយគ្នា កើតបានទៅជាវង្សមួយទៀត ហៅថា កោលិយវង្ស(១) ។*

*ចំណេរចរកាលតមក ព្រះរាជាច្រើនអង្គសោយរាជសម្បត្តិក្នុងក្រុងកបិលពស្ដុជាលំដាប់តរៀងគ្នាមករហូតដល់ព្រះបាទជយសេន ។ ព្រះរាជាអង្គនេះ មានព្រះរាជបុត្រមួយអង្គ ព្រះនាមសីហហនុរាជ និងព្រះរាជធីតា១អង្គព្រះនាមយសោធរា ។ អំណើះតអំពីព្រះបាទជយសេនទៅ ព្រះបាទសីហហនុឡើងសោយរាជ្យ បានព្រះនាងកាញ្ចនាជាព្រះរាជធីតា*

១–ព្រះរាជាក្រុងពារាណសីមួយព្រះអង្គ ទ្រង់កើតព្រះរោគព្យាធិហើយលះបង់រាជសម្បត្តិទៅនៅព្រៃ សោយផលាផលក្នុងព្រៃជាអាហារ សោយទៅប្រទះផ្លែឈើជាថ្នាំ បានជាព្រះរោគនោះទៅ ហើយស្ដេចចរយាត្រាតទៅមុខទៀត បានជួបព្រះរាជធីតាជាព្រះជេដ្ឋភគិនីនៃសាក្យវង្ស ដែលកើតរោគព្យាធិដែរ ទ្រង់បានជួយព្យាបាលឲ្យជាព្រះរោគហើយក៏សម្រេចការនៅរួមសំវាសជាមួយគ្នា ។

នៃព្រះបាទជនាធិបតិរាជខាងកោលិយវង្សជាព្រះអគ្គមហេសី មានព្រះរាជបុត្រ៤ព្រះអង្គគឺ សុទ្ធោទន ១ សុក្កោទន ១ អមិតោទន ១ ធោតោ-ទន ១, ព្រះរាជធីតា ២ ព្រះអង្គគឺ អមិតា ១ បមិតា ១ ។

ព្រះរាជាខាងកោលិយវង្ស សោយរាជសម្បត្តិជាសន្តតិវង្ស រៀងរហូតមកទល់ព្រះបាទជនាអធិបតីរាជ ។ ព្រះរាជាអង្គនេះ មានព្រះរាជបុត្រ១អង្គព្រះនាមអញ្ជនៈ, ព្រះរាជធីតា១អង្គព្រះនាម កាញ្ចនា ។ ព្រះបាទអញ្ជនៈ បានអភិសេកជាមួយនឹងព្រះនាងយសោធរា ជាព្រះរាជធីតានៃព្រះបាទជ័យសេនជាព្រះអគ្គមហេសី មានព្រះរាជបុត្រ២អង្គគឺសុប្ប-ពុទ្ធ១ទណ្ឌបាណិ១ មានព្រះរាជធីតា២ព្រះអង្គគឺ មាយា១បជាបតី១ ។

ព្រះបាទសុទ្ធោទនៈ បានអភិសេកជាមួយនឹងព្រះនាងមាយា ជាព្រះរាជធីតានៃព្រះបាទអញ្ជនៈ ជាព្រះអគ្គមហេសី ។ ក្រោយដែលព្រះវរមហាពោធិសត្វប្រសូតបាន ៧ ថ្ងៃ ព្រះនាងមាយាជាព្រះវរមាតាទិវង្គតទៅ ព្រះបាទសុទ្ធោទនៈ បានលើកព្រះនាងបជាបតី ជាព្រះរាជកនិដ្ឋភគិនីនៃព្រះនាងមាយាជាព្រះអគ្គមហេសី មានព្រះរាជបុត្រ១អង្គគឺនន្ទកុមារ, មានព្រះរាជធីតា ១ អង្គគឺ នាងជនបទកល្យាណីឬរូបនន្ទា ។

ឯសុប្បពុទ្ធកុមារ(១) បានទាំងអមិតាជាព្រះរាជធីតានៃព្រះបាទសីហហនុរាជជាព្រះជាយា មានព្រះរាជបុត្រ១អង្គគឺទេវទត្ត មានរាជធីតា១អង្គគឺពិម្ពាយសោធរា ។

សុក្កោទនៈ មានរាជបុត្រ១អង្គគឺអានន្ទ, អមិតោទនៈមានព្រះរាជបុត្រ២អង្គគឺ មហានាម១ អនុរុទ្ធ១ មានរាជធីតា១ អង្គគឺ រោហិណី ។

---

១-ព្រះនាមក្សត្រទាំងពីរវង្សនេះក្នុងគម្ពីរទាំងឡាយជាថេរវាទក្តី មហាយានក្តី មិនប្រាកដដូចគ្នាទេ ផ្សេងគ្នាច្រើនអន្លើណាស់ ទាំងចំនួនក៏មិនស្របគ្នាដែរ ទោះតែមានលើសខ្វះគ្នាជាដរាប ។

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរបុគ្គលបញ្ញត្តិ

(តមក)

*លោក ប៊ូ-ប៊ូ រៀបរៀង*

---

### តិកបុគ្គល

ក្នុងលំដាប់អំពីទុកបុគ្គល ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់សំដែងនូវបុគ្គលមួយពួក ៗ មានជាដើមថា បុគ្គលមានចក្ខុខ្វាក់ទាំងពីរខាងមួយពួក, បុគ្គលមានចក្ខុខ្វាក់ម្ខាងមួយពួក, បុគ្គលមានចក្ខុភ្លឺទាំងពីរខាងមួយពួក ។

បុគ្គលមានចក្ខុខ្វាក់ទាំងពីរខាងនោះ បានដល់បុគ្គលឥតបញ្ញា មិនបានដឹងនូវបុណ្យនិងបាប ។

បុគ្គលមានចក្ខុខ្វាក់ម្ខាងនោះ, បានដល់បុគ្គលដឹងតែបុណ្យ មិនដឹងបាប និងដឹងតែបាប មិនដឹងបុណ្យ ។

បុគ្គលមានចក្ខុភ្លឺទាំងពីរខាងនោះ បានដល់បុគ្គលមានបញ្ញាដឹងនូវបុណ្យ និងបាបទាំងពីរប្រការ ។

បុន ច បរំ ប្រការមួយទៀត តយោ បុគ្គលា បុគ្គលបីពួកនៅមានទៀត គឺ អវកុជ្ជបញ្ញបុគ្គល មួយពួក, ឧច្ឆង្គបញ្ញបុគ្គល មួយពួក, ភូរិបញ្ញបុគ្គល ពួកមួយ ។

អវក្កុជ្ជបញ្ញាបុគ្គល នោះ បានដល់បុគ្គលមានបញ្ញាដូចឆ្នាំងផ្កាប់ ។

ឧច្ចង្គបញ្ញាបុគ្គល នោះ បានដល់បុគ្គលមានបញ្ញាដូចថ្នក់ ។

ភូរិបញ្ញាបុគ្គល នោះ បានដល់បុគ្គលមានបញ្ញាដ៏ក្រាស់ជ្រាលជ្រៅដូចផ្ទៃផែនដី ។

## ចតុក្កបុគ្គល

សម្តេចព្រះមហាមុនី ទ្រង់ត្រាស់សំដែងនូវបុគ្គលបីពួកចប់ហើយ ទើបទ្រង់សំដែងនូវបុគ្គលបួនពួកតទៅទៀតថា៖

ទក្ខោ ច បុគ្គលឈ្លាសវៃប៉ិនប្រសប់មួយពួក, អនលសោ បុគ្គលមិនខ្ជិលច្រអូសមួយពួក, សម្បជានោ បុគ្គលដឹងជុំវិញឬដឹងសព្វគ្រប់មួយពួក, បដិស្សតោ បុគ្គលប្រកបដោយស្មារតីតាំងមាំមួនមួយពួក ។

ទក្ខបុគ្គលនោះ បានដល់បុគ្គលអ្នកឈ្លាសវៃក្នុងសិល្បសាស្ត្រ អាចធ្វើការឲ្យសំរេចប្រយោជន៍ដល់ខ្លួនបាន ដូចព្រះបាទកដ្ឋវាហនរាជ កាលដើមឡើយ ជាអ្នកចេះដឹងឈ្លាសវៃក្នុងសិល្បសាស្ត្រខាងវិជ្ជាជាងឈើ មានសេចក្តីដំណាលថា៖ ។

កោកនទំ នាម បាសាទំ កត្វា មានមេជាងឈើម្នាក់ឈ្មោះមិនប្រាកដ បានធ្វើប្រាសាទមួយខ្នងថ្វាយព្រះពោធិរាជកុមារ

ឈ្មោះថា  គោកុទ្ទប្រាសាទ  ល្អស្អាតហាក់ដូចជាអណ្តែតនៅឯអាកាស ។ ព្រះរាជកុមារសួរមេជាងឈើថា តយា  កាតបុញ្ញោ ប្រាសាទបែបនេះ  អ្នកឯងធ្លាប់បានធ្វើឲ្យអ្នកឯទៀតរួចហើយដែរឬទេ ? ឬអ្នកទើបតែធ្វើម្តងនេះជាគ្រាដំបូង ? ។

មេជាងឈើក្រាបទូលថា  បឋមសិប្បំ ឯវ  សិល្បសាស្ត្រ គឺការធ្វើប្រាសាទនេះជាគ្រាដំបូងបំផុត  ទូលព្រះបង្គំមិនដែលធ្វើថ្វាយព្រះមហាក្សត្រអង្គណាទេ ។  ព្រះរាជកុមារបានទ្រង់ព្រះសណ្តាប់ហើយ  ក៏ទ្រង់ព្រះចិន្តាថា  បើអញមិនសម្លាប់ជាងឈើនេះ  ឬមិនក្តៀលភ្នែកទាំងពីរខាងរបស់ជាងនេះឲ្យខ្វាក់ទេ  ប្រាសាទនៃអញមុខជាមិនល្អអស្ចារ្យ ,  ទ្រង់ដំណាលប្រាប់សេចក្តីនេះឲ្យមាណពឈ្មោះសញ្ជ័យកបុត្រជាសម្លាញ់បានដឹងផង ។  មាណពនឹកអាណិតអាសូរមេជាងឈើនោះខ្លាំងពេក  អត់ទ្រាំពុំបាន  ក៏ប្រាប់អាថ៌កំបាំងនេះឲ្យមេជាងដឹងខ្លួន ។ មេជាងដឹងរឿងនេះហើយ  ក៏ឥតនិយាយប្រាប់អ្នកណាម្នាក់សោះ  ។ កាលព្រះរាជកុមារ  ចូលទៅសាកសួរមេជាងអំពីកិច្ចការសង់ប្រាសាទនោះឲ្យបានជ្រាបថា  ធ្វើរួចហើយ  ឬនៅឡើយ  ។  មេជាងក្រាបទូលថា ធ្វើមិនទាន់ស្រេចទេព្រោះខ្វះឈើស្រាល ៗ ឥតខ្លឹម  សូមព្រះអង្គឲ្យគេយកឈើស្រាល ៗ  ឥតខ្លឹមមកឲ្យទូលព្រះបង្គំ ៗ នឹងធ្វើឲ្យហើយស្រេចឆាប់ ៗ  ។  ព្រះរាជកុមារត្រាស់ប្រើរាជបុរសឲ្យយកឈើស្រាល ៗ

ឥតខ្ចីមទៅឲ្យមេដាន ហើយបង្គាប់ឲ្យឡោមព័ទ្ធប្រាសាទនោះជុំវិញ កុំឲ្យមេដានចេញទៅណារួច ។

មេដានក្រាបទូលថា ទូលព្រះបង្គំធ្វើការនេះល្អិតសុខុមណាស់សូមព្រះអង្គហាមប្រាមកុំឲ្យអ្នកណាម្នាក់ចូលមករកទូលព្រះបង្គំឡើយ បើកឲ្យតែភរិយានៃទូលព្រះបង្គំម្នាក់ យកអាហារមកឲ្យប៉ុណ្ណោះ ព្រោះថាបើមានគេចូលមកនាំនិយាយ កិច្ចការដ៏ល្អិតសុខុមនេះមុខជាខុសខូចទៅមិនបានជាល្អស្អាត ។ ព្រះពជកុមារក៏ធ្វើតាមពាក្យមេដានគ្រប់ប្រការ ។ មេដានបានធ្វើការស្អាតល្អ កំពូនសម្ងំនៅក្នុងបន្ទប់នៃប្រាសាទតែម្នាក់ឯង ខំធាត់តែងធ្វើរូបគ្រុឌយន្តដោយឈើស្រាល ។ ធំល្មមខ្លួនឯងនិងប្រពន្ធកូនអង្គុយចុះ លុះធ្វើស្រេចហើយ ប្រាប់ប្រពន្ធឲ្យលក់ដូរវត្ថុផ្សេង ៗ យកតែប្រាក់ទង់មាស ហើយឲ្យនាំកូនចូលទៅក្នុងប្រាសាទ ។ នាងប្រពន្ធធ្វើតាមពាក្យស្វាមីសព្វគ្រប់ ។ ស្វាមីនាំប្រពន្ធនិងកូនប្រុសស្រីចូលអង្គុយនិងរោះរូបគ្រុឌយន្ត ហើយចេញពីប្រាសាទហោះហើរទៅតាមអាកាសរំទៅចុះនៅព្រៃហិមពាន្ត កសាងនគរនៅក្នុងអរញ្ញប្រទេស ចំណេរចូរមកក៏បានជាក្សត្រនៅក្នុងព្រៃហិមពាន្ត មានព្រះនាមថាព្រះបាទកដ្ឋវាហនពជ ។ បុគ្គលអ្នកចេះស្ទាត់ក្នុងសិល្បសាស្ត្រ តែងយានខ្លួនឲ្យរួចផុតអំពីមរណភ័យ ហើយបានធ្វើជាធំយ៉ាងនេះ ។

បុគ្គលមិនខ្ជិលច្រអូស, បុគ្គលដ៏ជុំវិញ និងបុគ្គលមានស្មារតី

មាំមួន បើមិនទាន់បានសម្រេចសម្បត្តិជាលោកុត្តរនៅឡើយទេ ក៏គង់តែបានសម្រេចសម្បត្តិជាលោកិយមិនខានដែរ ទម្រាំបានសម្រេចសម្បត្តិជាលោកុត្តរក្នុងភពជាអវសាន ។

## បញ្ចកបុគ្គល

សម្តេចព្រះបរមទសពល ទ្រង់សំដែងបុគ្គលបួនពួកចប់ហើយ ទើបទ្រង់សំដែងបុគ្គលប្រាំពួកតទៅទៀតថា ៖

បុគ្គលកំណាញ់អាវាសមួយពួក, កំណាញ់ត្រកូលមួយពួក, កំណាញ់លាភមួយពួក, កំណាញ់ពណ៌សម្បុរនិងសេចក្តីសរសើរមួយពួក, កំណាញ់ធម៌មួយពួក ។

ឯបុគ្គលកំណាញ់អាវាសនោះមានពីរពួក គឺបព្វជិតមួយពួក, គ្រហស្ថមួយពួក ។

បព្វជិតកំណាញ់អាវាស គឺកំណាញ់ទីលំនៅ ឃើញភិក្ខុអាគន្តុកៈមកដល់ហើយ ក៏ហាមប្រាមប្រាប់ថា ទីនេះ ជាកន្លែងសម្រាប់ទុកដាក់របស់សង្ឃ, ទីនេះ ជាកន្លែងសម្រាប់ទុកដាក់របស់ចេតិយ ។ បេតោ វា អជគរោ វា ហុត្វា និព្វត្តិ ភិក្ខុកំណាញ់អាវាសនោះ លុះរលត់បញ្ចក្ខន្ធៈហើយ រមែងទៅកើតជាប្រេតឬជាពស់ថ្លាន់ ។

គហដ្ឋា បន ចំណែកបុគ្គលកំណាញ់អាវាស ជាគ្រហស្ថនោះ ឃើញអ្នកដទៃមានទីលំនៅ មានទីសំណាក់អាស្រ័យ ក៏កើតចិត្តលោភ

ចង់បាន ចូលទៅបៀតបៀនគេ ឬរស់នៅដោយគិតគោលចូលទៅឲ្យលើស ព្រំដែនតែបង្ខំយកទ្រព្យរបស់គេមកធ្វើជារបស់ខ្លួន ។ គ្រហស្ថអ្នកមានចិត្តលោភបែបនេះ លុះក្ស័យជីវិតហើយក៏ទៅកើតជាប្រេត នៅសេសសល់បាបនោះ មកកើតជាមនុស្សកំសត់ទុគ៌តអនាថា ។

ចំណែកអ្នកកំណាញ់ត្រកូលនោះ ជាហេតុនឹងនិយាយបេសុញ្ញវាទ ពាក្យញុះញង់បង្កាច់បង្ខូចកេរ្តិ៍ឈ្មោះគេ ហេតុនោះ អកុសលចេះតែកើតមានច្រើន ៗ ឡើងរាល់ថ្ងៃ ។

អ្នកកំណាញ់លាភ ច្រើនតែមានចិត្តប្រណាំងប្រជែងគេ បើឃើញអ្នកដទៃបានលាភ ក៏នឹកកាញ់កញ្ចិត្តនិយាយសំដីអាក្រក់តាំងដោតដេរប្រទេចផ្ដាសាគេ ខំគិតរកឧបាយធ្វើឲ្យគេខូចខាតលាភនោះ ថែមទាំងនិយាយញុះញង់កាច់កិនគេ នឹងធ្វើអទិន្នាទានលួចលាក់បំបាត់លាភរបស់គេទៀតផង ។ ឯអទិន្នាទានគឺការលួចនោះ មិនមែនសំដៅយកតែត្រង់ការលួចលាក់បំបាត់បង្ខំយកទ្រព្យសម្បត្តិដែលម្ចាស់គេមិនបានឲ្យប៉ុណ្ណោះទេ សូម្បីគ្រាន់តែធ្វើឲ្យអ្នកដទៃខូចខាតលាភគឺកេរ្តិ៍ដែលគេនឹងត្រូវបានក៏ឈ្មោះជាអទិន្នាទានដូចគ្នាដែរ ។

អ្នកកំណាញ់ពណ្ណសម្បទានឹងសេចក្ដីសរសើរនោះ កាលបើឮគេនិយាយសរសើរអំពីពណ្ណសម្បុររូបកាយរបស់អ្នកណា ថាល្អស្រស់ណាស់ ក៏បែរជាធ្វើយដំតាស់បន្ទុះបង្អាប់ ពណ្ណសម្បុររូបកាយអ្នកនោះមិនល្អទេ

មួយបើឮគេសរសើរអំពីគុណធម៌របស់អ្នកណា ក៏កើតចិត្តឫស្យាឆ្លើយកាត់គេថា អ្នកនោះចិត្តល្អមែនហើយ ប៉ុន្តែកាលដើមគាត់ប្រព្រឹត្តអាក្រក់យ៉ាងនេះខ្លះ យ៉ាងនោះខ្លះ យើងមិនគួរសរសើរអ្នកនោះទេ ។

ចំណែកអ្នកកំណាញ់ធម៌នោះ លោកសំដៅយកកំណាញ់ព្រះបរិយត្តិធម៌គឺធម៌សម្រាប់រៀនសូត្រ ។ អ្នកកំណាញ់ធម៌រមែងគិតថា អ្នកនេះបើអញប្រាប់ធម៌ឲ្យចេះដឹងទៅហើយ មុខជានឹងសួរដេញដោលផ្ចាញ់ផ្ចាលអញក្នុងទីប្រជុំជនមិនខាន ឬនឹងល្បីកេរ្តិ៍ឈ្មោះថាជាអ្នកចេះដឹងធម៌ជាងអញ លុះគិតយល់យ៉ាងនេះហើយ ក៏លាក់ធម៌ទុកចេះតែម្នាក់ឯង សូម្បីអ្នកណាសួរដូចម្តេចក៏មិនប្រាប់អ្នកនោះឲ្យចេះដឹងដែរ ។ មនុស្សបែបនេះហៅថាអ្នកកំណាញ់ធម៌ ។

បុគ្គលកំណាញ់ទាំងប្រាំពួកដូចរៀបរាប់មកហើយនេះ បើហៅតាមភាសាបាលីដែលមានក្នុងគម្ពីរព្រះអភិធម្មបុគ្គលបញ្ញត្តិថា៖

១- អាវាសមច្ឆរិយបុគ្គល បុគ្គលអ្នកកំណាញ់ទីលំនៅ

២- កុលមច្ឆរិយបុគ្គល -ដ- ត្រកូល

៣- លាភមច្ឆរិយបុគ្គល -ដ- លាភ

៤- វណ្ណមច្ឆរិយបុគ្គល -ដ- ពណ៌ឬកិត្តិគុណ

៥- ធម្មមច្ឆរិយបុគ្គល -ដ- ព្រះបរិយត្តិធម៌

អ្នកកំណាញ់ទាំងប្រាំពួកនេះ ស្លាប់ហើយ រមែងទៅកើត

ក្នុងអបាយភូមិ ។

នៅមានបុគ្គលតាំងប្រាំពួកទៀត បើរស់ជីវិតហើយ រមែងបាន ទៅកើតក្នុងស្ថានសួគ៌ គឺ បុគ្គលបរិបូណ៌ដោយញាតិមួយពួក, បរិបូណ៌ ដោយសម្បត្តិមួយពួក, បរិបូណ៌ដោយការមិនមានរោគមួយពួក បរិបូណ៌ ដោយសីលមួយពួក បរិបូណ៌ដោយសម្មាទិដ្ឋិមួយពួក ។

បុគ្គលអ្នកបរិបូណ៌ដោយញាតិនោះ គឺញាតិទាំងឡាយជាមនុស្ស មានចិត្តជាកុសល ជាមនុស្សសង្គ្រោះញាតិ ជាមនុស្សសប្បុរស ទើប ហៅអ្នកសម្បូណ៌ញាតិបានទៅកើតនៅស្ថានសួគ៌ៗបើអ្នកនោះមានសន្តាន ច្រើនមែនហើយ ប៉ុន្តែញាតិទាំងនោះ ជាមនុស្សចិត្តអកុសលជាមនុស្ស មិនជួយសង្គ្រោះញាតិ ជាមនុស្សអសប្បុរស ក៏មិនបានទៅកើតក្នុងស្ថាន សួគ៌ដែរ ព្រោះខ្លួនជាមនុស្សអសប្បុរសទៅតាមញាតិទាំងនោះ ។

បុគ្គលអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិនោះ សំដៅយកអ្នកមាន ទ្រព្យសម្បត្តិច្រើន ហើយមានសទ្ធាជ្រះថ្លាជឿកម្មផលផង បើមានតែ ទ្រព្យសម្បត្តិច្រើន ហើយគ្មានសទ្ធាជ្រះថ្លា ក៏មិនបានទៅកើតនៅស្ថាន សួគ៌ដែរ ។ ចំណែកអ្នកទ័លក្រខ្សត់ធនធាន ប៉ុន្តែជាមនុស្សមានសទ្ធា ជ្រះថ្លាបានឈ្មោះថាអ្នកនោះមានទ្រព្យធន សមតាមព្រះពុទ្ធភាសិតថា សទ្ធានេះ ក៏ជាអរិយទ្រព្យប្រការមួយ ព្រោះថាបុគ្គលគ្មានសទ្ធាជ្រះ ថ្លា បើទុកជាមានធនធានច្រើនដល់ប៉ុន្មានៗ ក៏មិនអាចនឹងធ្វើកងការ

កុសលអ្វីមួយបានដែរ លុះតែមានសទ្ធាទើបអាចនឹងធ្វើកិច្ចការកុសលទាំង
ពួងបាន ដែលជាបច្ច័យនឹងឲ្យបានលោកិយសម្បត្តិនិងលោកុត្តរសម្បត្តិ ៗ

បុគ្គលអ្នកបរិបូណ៌ដោយការមិនមានរោគនោះ គឺជាអ្នកមិនមានរោគ
ប្រចាំនៅក្នុងខ្លួនជាប់ជាមួយ មិនដែលឈឺធ្ងន់ដល់ទៅជិតស្លាប់ មានជម្ងឺឈឺ
ចាប់ខ្លះដែរ ប៉ុន្តែឈឺស្រាលៗបន្តិចបន្តួចក៏បាត់ទៅវិញ អ្នកឥតរោគនេះ
ជាហេតុនឹងឲ្យបានទៅកើតទៅស្ថានសួគ៌ ព្រោះថាបើខ្លួនឥតជម្ងឺហើយ
នឹងធ្វើកុសលអ្វីៗក៏ចេះតែធ្វើបានតាមចិត្តប្រាថ្នា នេះបើយកបុគ្គលអ្នក
មានបញ្ញាចេះគិតឃើញអនិច្ចំ ទុក្ខំ អនត្តា ជាអ្នកមិនប្រមាទ មិនស្រវឹង
ស្រវើង ៗ បើបុគ្គលឥតរោគាពាធប្រចាំនៅក្នុងខ្លួនមែនហើយ ប៉ុន្តែជាអ្នក
ប្រមាទស្រវឹងស្រវើងសំគាល់ថាខ្លួនឥតជម្ងឺឈឺចាប់អ្វីសោះ ហើយចេះតែប្រ
ព្រឹត្តអំពើទុច្ចរិតផ្សេងៗជានិច្ចទៅមិនបានគិតឃើញសង្ខារជា អនិច្ចំ ទុក្ខំ
អនត្តាសោះ ៗ អ្នកឥតរោគបែបនេះមិនបានទៅកើតទៅស្ថានសួគ៌ទេ
ព្រោះខ្លួនមិនបានធ្វើកុសលណាមួយ ៗ

ចំណែកអ្នកមានបញ្ញានោះ បើទុកជាខ្លួនឥតឈឺចាប់អ្វីមានសេចក្ដី
សុខកាយសប្បាយចិត្តយ៉ាងណាក៏ដោយ គង់នៅតែពិចារណាឃើញថាបើ
អាត្មាអញមិនទាន់បានដល់ព្រះនិព្វានដរាបណា រូបកាយរបស់អាត្មាអញ
ឈ្មោះថាមានរោគនៅប្រចាំជាប់ជានិច្ចគ្រប់ពេលវេលាដរាបនោះ ៗឯរោគ
ធំបំផុតដែលកើតមាននៅក្នុងខ្លួនអាត្មាអញជានិច្ចនោះ គឺរោគស្រេកឃ្លាន

ដូចស្រេកទឹកឃ្លានបាយជាដើម សមតាមព្រះពុទ្ធភាសិតថា ជិឃច្ឆា
បរមា រោគា គ្មានរោគឯណាខ្លាំងក្លាលើសរោគស្រេកឃ្លានទេ
(ធ.ខុ) ។ អ្នកស្រេកទឹក ឬឃ្លានបាយបណ្ដាលឲ្យអស់កម្លាំងទន់ដៃជើង
ធ្វើការងារសូម្បីបន្តិចបន្តួចក៏មិនកើត ទាល់តែរកបាយទឹកមកបរិភោគឲ្យ
បាត់ឃ្លាន ទើបធ្វើការងារកើត ។ ឯបុណ្យកុសលទាំងពួងក៏ដូចជា
ការងារដែរ ។ មានបញ្ញាយល់ឃើញថា ខ្លួនមានរោគជានិច្ចទាល់
តែដល់ព្រះនិព្វាន ទើបគ្មានរោគទាំងអស់ លុះយល់យ៉ាងនេះហើយ
ក៏ធ្វើកុសលប្រាថ្នាឲ្យបានដល់ព្រះនិព្វាន បើមិនទាន់ដល់ព្រះនិព្វានទេ
នៅត្រាត់ក្នុងវដ្ដសង្សារនៅឡើយ ក៏នឹងបានសោយនូវសុខសម្បត្តិ ។

បុគ្គលអ្នកបរិបូណ៌ ដោយសីលនោះជាហេតុនាំឲ្យបានទៅកើតនៅ
ស្ថានសួគ៌រមែងមានអានិសង្សប្រាំប្រការ សមតាមពាក្យព្រះសារីបុត្តត្ថេរ
ថា ឥធ សីលវា សម្បន្នោ សីលេន កុលបុត្តក្នុងព្រះពុទ្ធ
សាសនានេះ ជាអ្នកមានសីលបរិបូណ៌ដោយសីលដែលខ្លួនរក្សា ដោយ
សេចក្ដីមិនប្រមាទរមែងបាននូវភោគសម្បត្តិដ៏ធំ នេះជាអានិសង្សដំបូង ។

សីលវតាយ សីលសម្បទាយ បុគ្គលអ្នកមានសីល
បរិបូណ៌ដោយសីលនោះ មានកិត្តិសព្ទពាក្យសរសើរល្បីល្បាញទូទៅ
គ្រប់ទិសថា អ្នកនេះ ជាមនុស្សរក្សាសីលបរិសុទ្ធបរិបូណ៌ប្រពៃ នេះ
ជាអានិសង្សគំរប់ពីរ ។

បុគ្គលអ្នកមានសីលបរិសុទ្ធបរិបូណ៌ប្រពៃនោះ បើនឹងចូលទៅជិត

បរិស័ទណាៗ គឺខត្តិយបរិស័ទ, ព្រាហ្មណ៍បរិស័ទនិងសមណបរិស័ទក៏ក្លៀវក្លាឥតតក់ស្លុត មិនសំយុងមុខជ្រប់ នេះជាអានិសង្សគំរប់បី ។

អសម្មូឡ្ហោ កាលំ ករោតិ បុគ្គលអ្នកមានសីល ជិតនឹងក្ស័យជីវិតមិនវង្វេងស្មារតី នេះជាអានិសង្សគំរប់បួន ។

បុគ្គលអ្នកមានសីល កាលបើអស់ជីវិតហើយ រមែងបានទៅកើតទៅស្ថានសួគ៌ នេះជាអានិសង្សគំរប់ប្រាំ ។

ចំណែកបុគ្គលអ្នកបរិបូណ៌ដោយសម្មាទិដ្ឋិនោះ តែងពិចារណាឃើញថា ខ្លួនមានកម្មជារបស់ខ្លួនៗ ជាអ្នកទទួលនូវផលនៃកម្ម បើខ្លួនធ្វើកម្មល្អក៏រមែងបានផលជាសុខ បើខ្លួនធ្វើកម្មអាក្រក់ ក៏រមែងបានផលជាទុក្ខ, សុខនិងទុក្ខនេះ ជាផលនៃកម្មល្អនិងអាក្រក់ដែលខ្លួនធ្វើដោយខ្លួនឯង គ្មានអ្នកណាឲ្យខ្លួនទេ កាលបើឃើញយ៉ាងនេះជាដើមហើយ ក៏ខំប្រឹងធ្វើនូវការកុសល ទាំងពួងដែលជាចំណែកខាងកម្មល្អ លុះអស់ជីវិតហើយរមែងបានទៅកើតទៅស្ថានសួគ៌ ។

សម្ដេចព្រះបរមសាស្ដាទ្រង់ទេសនានូវបុគ្គលប្រាំពួក គឺអ្នកបរិបូណ៌ដោយញាតិ ដោយសម្បត្តិ ដោយការមិនមានរោគ ដោយសីល និងអ្នកបរិបូណ៌ដោយសម្មាទិដ្ឋិ តែងបានទៅសោយសុខសម្បត្តិទៅស្ថានសួគ៌ ។

## ឆក្កបុគ្គល

ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងនូវបុគ្គលប្រាំពួកចប់ហើយ ព្រះអង្គទ្រង់សំដែងនូវបុគ្គលប្រាំមួយពួកតទៅទៀត ប៉ុន្តែ ទ្រង់ពន្យល់នូវសារាណីយធម៌ជាមុនថា ៖

ឆ សារាណីយា ធម្មា ធម៌តាំងឲ្យជាទីតាំងនៃសេចក្តីរឭកមាន ៦ ប្រការ គឺ –

១– មេត្តាកាយកម្ម ជួយធ្វើការងារគ្នាទាំងចំពោះមុខ ទាំងកំបាំងមុខដោយចិត្តមេត្តា ;

២ មេត្តាវចីកម្ម ជួយបង្ហាត់បង្រៀនប្រាប់ពន្យល់ឬប្រដៅ:

៣– មេត្តាមនោកម្ម ជួយគិតគូរនូវកិច្ចការ ដែលជាប្រយោជន៍ឲ្យដល់គ្នា ទាំងចំពោះមុខ ទាំងកំបាំងមុខដោយចិត្តមេត្តា:

៤– លាភៈ ចែកវត្ថុដែលខ្លួនរកបានមកដោយធម៌ ឲ្យដល់គ្នីគ្នា មិនលាក់លៀមទុកបរិភោគតែម្នាក់ឯង ។

៥– សីលៈ រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា មិនឲ្យគេរង្កៀសនឹងសីលរបស់ខ្លួន ។

៦– ទិដ្ឋិ មានសេចក្តីយល់ឃើញត្រូវគ្នា មិនឈ្លោះប្រកែកទាស់ទែងនឹងអ្នកណា ព្រោះតែការយល់ឃើញខុសគ្នា ។ (នៅមានត)

# មធុរសភាហិណី

## សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

---

ខ្ញុំព្រះអង្គ បានចូលទៅកាន់សំណាក់សេតៈសោមៗនោះក៏មានចិត្តកតញ្ញូពុំភ្លេចគុណខ្ញុំព្រះអង្គឡើយ បានឃាត់ខ្ញុំព្រះអង្គឲ្យនៅរង់ចាំក្នុងទីជិតដើមជ្រៃនោះ ហើយហើរចេញទៅស្វែងរកទ្រព្យ បានពាំនាំកែវមុក្តាហារ យកមកឲ្យជាការតបគុណខ្ញុំព្រះអង្គៗក៏បានយកកែវមុក្តាហារនោះទៅផ្ញើទុកនឹងមនុស្សជាសំឡាញ់ដែរ ហើយបាននិយាយប្រាប់រឿងដែលសេតៈសោមបានយកកែវនោះមកតបគុណខ្ញុំព្រះអង្គដោយសព្វគ្រប់ ឥឡូវនេះ ព្រោះហេតុតែមនុស្សនោះឯង បានជាខ្ញុំព្រះអង្គដល់នូវទោសត្រូវសម្លាប់ លុះពជបុរសទាំងឡាយនាំខ្ញុំព្រះអង្គទៅតាមផ្លូវ ខ្ញុំព្រះអង្គក៏នឹកភ្នកដល់ពស់ ស្រាប់តែខ្ញុំព្រះអង្គបានជួបប្រទះនឹងពស់នាគរាជ ដែលជាសំឡាញ់នឹងខ្ញុំព្រះអង្គនោះ ៗ នាគរាជនោះក៏មានចិត្តកតញ្ញូកតវេទីដឹងឧបការគុណនៃខ្ញុំព្រះអង្គ ខំស្វះស្វែងរកឧបាយដោះឲ្យរួចអំពីសេចក្តីស្លាប់ ព្រមទាំងអាចញុំាងខ្ញុំព្រះអង្គ ឲ្យបានសម្បត្តិទ្រព្យដ៏បរិបូណ៌ ជាសុខសប្បាយឥតមានទុក្ខទោសអ្វីឡើយ ៗ

ឆការិយ: បពិត្រព្រះអង្គជាធំជាងនរជន! សុជនោ ធម្មភាង

ជនល្អជាសប្បុរស ទោះបីជាសត្វតិរច្ឆានក្តី ជាមនុស្សជាតិក្តី ក៏បុគ្គលមិន
គប្បីមើលងាយថា តូច ថាថោកទាបឡើយ ឧទាហរណ៍ដូចយ៉ាងជនទាំង
ពីរនេះគឺ សេកសោមមួយ ពស់នាគរាជមួយ សឹងបានស្និតនៅក្នុងមិត្ត-
ធម៌ ដែលជាធម៌ល្អគឺបណ្ឌិតគប្បីគប់ ជាអ្នកមានឧស្សាហ៍ប្រកបដោយ
ហេតុល្អ ប្រព្រឹត្តតាមធម៌ អាចធ្វើបដិការតបគុណដល់ខ្ញុំព្រះអង្គដែលជា
អ្នកបានធ្វើគុណដល់ខ្លួនជាមុនដោយពិត ។ ចំណែកឯមនុស្សជាតិជា
អ្នកថោកទាបមានសន្តានចិត្តជាពាលប្រាកដដូចបាបមិត្តនេះ ទោះបីមាន
ជាតិស្មើដោយខ្ញុំព្រះអង្គ អ្នកបានធ្វើឧបការគុណចំពោះខ្លួនដល់ប៉ុន្មានក្តីគង់
បាបមិត្តជាមនុស្សថោកទាបនោះ ក៏ពុំដឹងគុណដែលមិត្តល្អមានឧបការដល់
ខ្លួនឡើយ សឹងតែប្រែត្រឡប់ប្រទូស្តដល់មិត្តដែលមានគុណចំពោះខ្លួនវិញ
ដោយចំណែកមួយ, បពិត្រព្រះសម្មតិទេព! បុគ្គលជាអសប្បុរសពុំបានធ្វើ
ឧបការតបដល់ខ្ញុំព្រះអង្គឡើយ តែប្រែត្រឡប់ទៅជាទឹងប្រទូស្តដល់ខ្ញុំព្រះអង្គ
វិញ ឯពួកជនជាសប្បុរសតែងមានសេចក្តីជ្រះថ្លាប្រាថ្នាតែសេចក្តីសុខ
សេចក្តីចំរើនដល់ខ្ញុំព្រះអង្គដោយពិត មួយទៀតបុគ្គលពាលទាំងឡាយ
ដែលមានចរិតជាអសប្បុរស ក៏ពុំបានដឹងគុណទីងទោសជាប្រក្រតីក្នុង
លោកយ៉ាងនេះឯង ៗ បពិត្រមហារាជ! ចំណែកឯមិត្តជាបណ្ឌិតអ្នកមានចិត្ត
សប្បុរស ទោះបីជាមនុស្សក្តី ជាសត្វតិរច្ឆានក្តី តែបានស្និទ្ធស្នាលនឹងអ្នក
ណាមួយហើយ តែងមានសន្តានចិត្តស្រឡាញ់ស្មោះត្រង់អ្នកនុ៎ះ ប្រកាន់

ខ្ជាប់ថាជាសំឡាញ់មែនពិត ៗ ចបការបុរសនោះបានសម្តែងព្រឹត្តិការណ៍របស់ខ្លួនថ្វាយព្រះមហាក្សត្រិយ៍សូមទ្រង់ព្រះសណ្តាប់ក្នុងកាលនោះឯង ៗ

លុះព្រះបរមក្សត្រិយ៍ ទ្រង់បានសណ្តាប់ពាក្យចបការបុរសក្រាបទូលដូច្នោះហើយ ស្តេចក៏មានព្រះហឫទ័យជ្រះថ្លា មានព្រះរាជឱង្ការត្រាស់បង្គាប់សេវកាមាត្យទាំងឡាយថា: ម្នាលអ្នកទាំងឡាយដ៏ចំរើន! អ្នកត្រូវបញ្ជាដល់នាយជាងទាំងឡាយឲ្យគាត់ចែងធ្វើគេហស្ថាន ឲ្យធំ ឲ្យល្អឆើត ប្រគល់ឲ្យដល់បុរសនេះជាដាច់ ៗ ឯចំណែកចបការបុរសនោះក៏បានក្រាបថ្វាយបង្គំលាព្រះមហាក្សត្រិយ៍ចេញទៅ ហើយនិយាយប្រាប់នាយជាងទាំងនោះថា សូមអ្នកទាំងឡាយធ្វើផ្ទះឲ្យខ្ញុំត្រង់ចន្លោះដើមជ្រៃនឹងដម្បូកធំនេះចុះ លុះបាននិយាយហើយ ក៏ឲ្យនាយជាងចាត់សង់ផ្ទះក្នុងទីនោះដរាបតែហើយស្រេច ទើបទៅនៅអាស្រ័យក្នុងផ្ទះនោះជាសុខសប្បាយ ៗ បុរសនោះបរិបូណ៌ដោយទ្រព្យសម្បត្តិនឹងបរិវារចោមរោមបំរើជានិច្ច ហើយតែងចូលទៅគាល់បំរើព្រះបរមក្សត្រិយ៍ជាប្រក្រតីបានរីករាយស្មោះសរជាមួយនឹងសំឡាញ់ទាំងពីរ គឺសេកសោមនឹងពស់នាគរាជនោះអស់កាលជានិរន្តរ៍ គាត់តែងចិញ្ចឹមរក្សាឲ្យបាយចំណីទឹកឃ្មុំដល់សំឡាញ់ទាំងពីរបរិភោគឆ្អែតស្កប់ស្កល់ដរាបដល់អស់ជីវិតទៅ ៗ អាយុហា-បរិយោសានេ កាលបើជនទាំងបីនាក់ បានធ្វើមរណកាលក្សណក្ស័យជីវិតហើយ ក៏បានឡើងទៅកើតក្នុងស្ថានសួគ៌សោយទិព្វសម្បត្តិដ៏

សមគួរតាមកម្មរបស់ខ្លួនៗ ។ ព្រោះហេតុដូច្នេះ ទើបព្រះអរហន្តទាំងឡាយបានពោលនូវបទព្រះគាថាដូច្នេះថា:

ឥតិ បតិតសុខម្ហា   អត្តតោ វា ធនម្ហា
បរមតរបតិដ្ឋា   ហោតិ មិត្តាសវានំ
វិរហិតសំចិនម្ហា   នត្ថិ យស្មា ហិ វុទ្ធិ
ភជថ កុសលធម្មំ   មិត្តវន្តោ មហន្តំ(១)

អធិប្បាយថា: បពិត្រសប្បុរសទាំងឡាយដ៏ចំរើន ! ទំពីងដ៏ឧត្តមវិសេសហូរធ្លាក់ចុះមកអំពីសេចក្តីសុខខ្លះ អំពីខ្លួនឯងខ្លះ អំពីទ្រព្យសម្បត្តិខ្លះ តែងកើតប្រាកដផលមិត្តសំឡាញ់ទាំងឡាយ សេចក្តីពិតថា បើបុគ្គលមិនមានមិត្តសំឡាញ់ទេ នឹងមានសេចក្តីចំរើនសួស្តីមកពីហេតុណា, ព្រោះហេតុនោះ បើអ្នកទាំងឡាយបានមិត្តសំឡាញ់ល្អហើយ ត្រូវតែបំពេញកុសលធម៌ឲ្យច្រើនដោយពិត ។

សំដែងរឿងជនទាំងបីនាក់ ក្នុងវគ្គបឋម និទានជាគំរប់បី ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

៤- តុណ្ឌិលវត្ថុគាថា សំដែងរឿងនិទាននាងដីតាឈ្មោះ តុណ្ឌិលី ជាគំរប់៤តទៅទៀត ដោយបទបាលីថា: ជម្ពុទីបេ តិរ ដូច្នេះជាដើម អធិប្បាយថា: បានឮរឿងរ៉ាវមកពីកាលមុន ក្នុងជម្ពូទ្វីប

---

១- មាលិនីឆន្ទ ១៥ ក. ។ វុត្តោទយទំព័រ ៦៥ ។

មានត្រកូលសេដ្ឋីមួយ មានទ្រព្យកប់ទុកចំនួនប៉ែតសិបប្រាំពីរកោដិ នៅ
អាស្រ័យក្នុងនគរបាតលីបុត្រ ។ សេដ្ឋីនោះមានធីតាមួយរូបឈ្មោះនាង
ពុទ្ធេណី ។ លុះដល់នាងពុទ្ធេណីនោះចំរើនវ័យធំឡើង បានអាយុ៧ឆ្នាំ
ហើយ សេដ្ឋីជាមាតាបិតាក៏ធ្វើមរណកាលក្ស័យជីវិតទៅ នាង
ធីតានៅក្រោយតែម្នាក់ឯង ។

ឯទ្រព្យសម្បត្តិទាំងអស់ក្នុងត្រកូលនោះ ក៏បានទៅជារបស់ទ្រព្យ
នាងពុទ្ធេណីនោះឯង, ឯនាងពុទ្ធេណីនោះសោភ៍ត នាងមានរូបឆោមទ្រង់
ទ្រាយល្អគួរជាទីត្រេកអរដល់ប្រជុំជនដែលបានឃើញនាង ប្រកបដោយ
ពណ៌សម្បុរដ៏ឧត្តមប្រសើរ មានដំណើរប្រៀបផ្ទឹមប្រហែលស្រីទេពអប្សរ
នាងជាទីស្រឡាញ់ពេញចិត្តដល់ជនទាំងឡាយ, ហើយជាស្ត្រីមានសទ្ធា
ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជាស្ត្រីគោរពប្រតិបត្តិពប់អានទូវគុណព្រះរតន-
ត្រ័យគឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាប់ជានិច្ច ឥតមានចិត្តគម្រើកឡើយ ។
ចំណែកឯជនទាំងឡាយក្នុងព្រះនគរនោះ មានសេដ្ឋីសេនាបតីស្តេចឧប-
រាជជាដើមសឹងមានសេចក្តីប្រាថ្នាចង់បាននាងពុទ្ធេណីនោះ ដើម្បីធ្វើជា
ករិយានៃខ្លួនទីទៃៗ បានចាត់មនុស្សឲ្យកំចំរើទាំងឡាយ ឲ្យនាំគ្រឿង
បណ្ណាការទៅឲ្យដល់នាងពុទ្ធេណីនោះ ហើយឲ្យនិយាយលួងលោមនាង
តាមការប្រលោមរៀងៗខ្លួន ។

ឯនាងពុទ្ធេណីនោះ នាងបានស្តាប់ដំណឹងនោះហើយ គិតគិតពិចារ-

ណាដោយសេចក្ដីសំរេចថា ឱអាត្មាអញអើយ! មាតាបិតាលោកបានខ សន្សំទ្រព្យសម្បត្តិទុកជាច្រើន ដល់វេលានឹងស្លាប់ក៏ស្លាប់ទៅចោលទ្រព្យ សម្បត្តិទាំងអស់ទុកនៅអាយយកទៅផងពុំបានឡើយ គឺទៅតែខ្លួនម្នាក់ឯង ដោយពិត ៗ ដំណើរអាត្មាអញទៀតក៏គង់នឹងត្រូវទៅតាមទំនងនោះ ឯង, បើដូច្នេះ អាត្មាអញប្រយោជន៍អ្វីនឹងមានប្ដី ប្រយោជន៍អ្វីនឹងទ្រព្យ សម្បត្តិទាំងនេះ, ត្រូវតែអាត្មាអញយកទ្រព្យសម្បត្តិទាំងអស់នេះ កប់ទុក ក្នុងព្រះពុទ្ធសាសនា ឲ្យជាកំណប់ព្រេងទៅខាងមុខប្រសើរជាង ៗ

លុះនាងបានរំពឹងគិតយ៉ាងនេះហើយ ក៏ឃាត់មនុស្សអ្នកបំរើទាំង នោះថា អើ! អ្នកទាំងឡាយ, ត្រូវនាំយកគ្រឿងបណ្ណាការត្រឡប់ទៅវិញ ចុះ ខ្ញុំមិនត្រូវការនឹងមានប្ដីសើឡើយ នាងពោលដូច្នេះហើយ ក៏បញ្ជូន មនុស្សទាំងឡាយទៅក្នុងកាលនោះឯង ៗ

ចាប់ដើមតាំងពីកាលនោះមក នាងពុទ្ធេណីបានបរិច្ចាគទ្រព្យធនញុំាង មហាទានឲ្យប្រព្រឹត្តទៅពុំដាច់ អាចធ្វើសមណៈនឹងព្រាហ្មណ៍ទាំងពួងឲ្យ ឆ្អែតបរិបូណ៌ដោយបច្ច័យទាំងឡាយតាមប្រាថ្នាឥតមានខ្វះខាតវត្ថុអ្វីឡើយ ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយលោកពោលជាបទព្រះគាថាថា:

ចតុទ្ទិសា យាតជិជិត្រជានំ ឧទបានភូតំ ឃរមាសិ ត-ស្សា ជាដើម អធិប្បាយថា: ទីផ្ទះរបស់ឧបាសិកាឈ្មោះពុទ្ធេណីនោះ កើត ប្រាកដដូចជាអណ្ដូងទឹកសម្រេចដល់ស្រមណ៍ទាំងឡាយ ដែលជាបុត្រ

ព្រះជិនស្រី និមន្តមកអំពីទិសទាំងបួនតាមតែត្រូវការ បើប្រាថ្នាបច្ច័យណាក៏បានបច្ច័យនោះតាមប្រាថ្នា បីដូចជាដើមកប្បព្រឹក្សជាហេតុឲ្យសម្រេចលាភទឹងបច្ច័យទាំងពួងតាមសមគួរដល់សេចក្ដីប្រាថ្នាបាន, ម្យ៉ាងទៀតសាលាទានដ៏ប្រសើររបស់នាងពុទ្ធណីនោះ សឹងមានអានុភាពធំទូលាយប្រដាប់ដោយពិតានសំពត់ ដ៏វិចិត្រមានក្បូរក្បាច់រយោលផ្កាភ្ញីជាដើមមានរបៀបតាមកែវប្រទីបថ្លាលា ចង់សំយុងចុះសម្រាប់អុជដ៏ភ្លឺរុងរឿងល្អដែលនាងតែងតាំងបំរុងទុកជាស្រេច ព្រមទាំងប្រដាប់ដោយរបៀបគ្រឿងកម្រាលសម្រាប់ដេកអង្គុយជាសុខស្រួលឥតមានខ្វះ, ឯនាងពុទ្ធណីឧបាសិកាសោតសឹងមានដៃបានលាងស្អាតបម្រុងទឹងឲ្យទានជានិច្ច, នាងមានចិត្តដ៏ស្អាតផូរផង់បានរក្សាសីល៥ជាប់ជានិច្ចសព្វកាលទាំងពួង, នាងមានកិត្តិស័ព្ទដ៏ប្រសើរខ្ពង់ខ្ពស់ល្បីខ្ចាយទូលាយ ដោយគុណមានករុណាគុណជាដើម ព្រោះបានឲ្យនូវមហាទានដ៏វិសេស ដែលព្រះអរិយទាំងឡាយតែងសរសើរដោយពិត ។

លុះចំណេរមកក្នុងកាលជាខាងក្រោយ មានឈ្មួញសេះម្នាក់នាំសេះចេញមកអំពីទិសខាងកើត ឆ្ពងចូលមកទិសខាងលិច នៃក្រុងបាតលីបុត្តនោះ ដើម្បីនឹងលក់សេះ ក៏បានមកសំណាក់នៅគេហស្ថានរបស់នាងពុទ្ធណីឧបាសិកានោះឯង ។

គ្រានោះ ឈ្មួញសេះបានឃើញកិរិយាមារយាទនាងហើយមានសេចក្ដី

ស្នេហាស្រឡាញ់ដូចជាជីតាបង្កើតរបស់ខ្លួន បានធ្វើទុកការជាប្រយោជន៍ដល់នាងជីតា ដោយប្រដាប់សម្រាប់តែងកាយទាំងឡាយមានគ្រឿងក្រអូបផ្កាកំរងនិងសំពត់ស្លៀកដណ្តប់ជាដើម, លុះដល់ពេលដែលនឹងត្រឡប់ទៅវិញក៏បាននិយាយនឹងនាងជីតានោះថា: ម្នាលនាង! បណ្តាសេះរបស់យើងទាំងអស់នេះ បើនាងត្រូវការដោយសេះណាមួយ ចូរនាងរើសយកតាមគាប់ចិត្តរបស់នាងចុះ ។

នាងពុទ្ធិណីបានស្តាប់ហើយ ក៏មានចិត្តត្រេកអរ បានពិនិត្យមើលសេះទាំងនោះ បានឃើញកូនសេះសិន្ធពមួយជាទីពេញចិត្តខ្លួន ហើយនិយាយតបថា បពិត្របិតា! សូមលោកឲ្យកូនសេះនេះដល់នាងខ្ញុំចុះ ។

ឈ្មួញសេះនោះ បានពោលជូនទៀតថា ម្នាលនាងអើយ ! កូនសេះនេះជាកូនសេះសិន្ធពពិត ដូច្នេះ ត្រូវនាងកុំប្រមាទប្រហែសធ្វេសឡើយ ត្រូវនាងខំយកចិត្តទុកដាក់ថែទាំរក្សាកូនសេះនេះឲ្យល្អចុះ ។ លុះពាណិជបានពោលយ៉ាងនេះហើយ ក៏បានប្រគល់កូនសេះនោះដល់នាងពុទ្ធិណីទាសិកានោះឯង ហើយក៏នាំសេះដទៃក្រៅពីនេះចៀសចេញទៅក្នុងកាលនោះឯង ។ ចំណែកឯនាងជីតាក៏ខំយកចិត្តទុកដាក់ថែទាំកូនសេះសិន្ធពនោះដោយប្រពៃ ហើយបានដឹងច្បាស់ថា កូនសេះសិន្ធពនេះមានឫទ្ធិច្រើនអាចហោះត្រាចទៅតាមអាកាសបានដោយពិត នាងបានរំពឹងគិតទៀតថា អាត្មាអញនឹងបានកូនសេះសិន្ធពនេះជាសំឡាញ់ក្នុងការធ្វើ

បុញ្ញកម្មរបស់អាត្មាអញក្នុងកាលជាខាងក្រោយ ដ្បិតទីកន្លែងដើមពោធិព្រឹក្ស នៃព្រះមានព្រះភាគដែលព្រះអង្គបានកំចាត់បង់មារាធិរាជជាបុគ្គលបាបលាមក ព្រមទាំងពលសេនារបស់មារបានឈ្នះស្រឡះហើយ ព្រះអង្គបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោកនេះ ទីកន្លែងដើមពោធិព្រឹក្សនោះ អាត្មាអញពុំដែលបានឃើញ ពុំដែលបានគោរពដល់ម្តងឡើយ បើដូច្នេះ ត្រូវតែអាត្មាអញទៅក្នុងទីនោះទាំងថ្វាយបង្គំពោធិព្រឹក្ស នៃព្រះមានព្រះភាគនោះឯង លុះនាងពុទ្ធេណីឧបាសិការគិតយ៉ាងនេះហើយ ក៏បានបញ្ជាទ្រព្យឲ្យពួកជាងទងចាត់ចែងធ្វើគ្រឿងបូជា មានផ្កាកម្រងមាសប្រាក់ជាដើមយ៉ាងច្រើន ។ សម័យថ្ងៃមួយ នាងក៏បានឡើងជិះលើខ្នងសេះសិន្ធព ហោះទៅតាមអាកាសដោយកម្លាំងឆាប់រហ័សតែមួយស្របក់ក៏បានដល់ពោធិព្រឹក្ស ហើយនាងចុះពីលើខ្នងសេះទៅស្ថិតនៅក្នុងមណ្ឌលជិតដើមពោធិព្រឹក្សនោះ ហើយស្រែកប្រកាសឃោសនាកេព្រះសង្ឃទាំងឡាយថា: បពិត្រព្រះសង្ឃដ៏ចំរើន! សូមលោកទាំងឡាយនិមន្តទទួលយកផ្កាកម្រងមាសប្រាក់នេះ ហើយបូជាព្រះមហាពោធិព្រឹក្សក្នុងកាលឥឡូវនេះឯង ។ ព្រោះហេតុដូច្នេះបានជាព្រះអរហន្តទាំងឡាយពោលជាបទព្រះគាថាដូច្នេះថា: យតោ បដ្ឋាយ សម្ពុទ្ធសាសនេ សុទ្ធមានសា បសន្នា តេន សទ្ធេន មហាទុក្ខហា ពទ្ធិយា ជាដើម អធិប្បាយថា ខ្ញុំមានចិត្តស្អាត មានចិត្តជ្រះថ្លាក្នុងសាសនាព្រះ

សម្មាសម្ពុទ្ធជាម្ចាស់ បានផ្តើមឡើងដោយពាក្យសច្ចៈឯណា សូមលោកម្ចាស់ទាំងឡាយនិមន្តមកនមស្ការបូជាពោធិព្រឹក្ស ដោយផ្កាកម្រងមាសប្រាក់ទាំងឡាយ ដើម្បីភ្ជាប់នូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ដោយពាក្យសច្ចៈនោះ ។ ចំណែកឯព្រះអរិយសាវកជាពុទ្ធបុត្រទាំងឡាយដែលនៅក្នុងជម្ពូទ្វីបទាំងប៉ុន្មាន លុះបានស្តាប់ពាក្យនាងពុទ្ធេណីទុបាសិកាពោលយ៉ាងនោះហើយ ក៏សឹងចូលមកប្រជុំគ្នាក្នុងទីនោះមួយរំពេច ហើយបាននមស្ការថ្វាយបង្គំបូជាព្រះមហាពោធិព្រឹក្ស ដោយផ្កាកម្រងមាសប្រាក់ របស់នាងពុទ្ធេណីទុបាសិកានោះឯង ។

តាំងដើមតាំងពីកាលនោះមក នាងធីតានោះមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនាពន់ពេក តែងឡើងជិះសេះហោះទៅបូជាព្រះពោធិព្រឹក្សជាមួយនឹងព្រះអរិយសាវកទាំងឡាយអស់កាលជានិច្ច ។

គ្រានោះ មនុស្សទាំងឡាយមានថ្មើរព្រៃជាដើមដែលបានត្រេចទៅក្នុងទីជិតក្រុងបាតលីបុត្តទាំងប៉ុន្មាន កាលបើបានឃើញរូបសម្បត្តិដ៏មានសិរីសួស្តីរបស់នាងពុទ្ធេណីនោះរឿយៗហើយ ក៏យកសេចក្តីទៅក្រាបបង្គំទូលដល់ព្រះបរមក្សត្រិយ៍ដូច្នេះថា: បពិត្រព្រះសម្មតិទេព! ឥឡូវនេះមាននាងកុមារិកាម្នាក់មានរូបល្អ មានសភាពសមរម្យល្មមធ្វើជាអគ្គមហេសីព្រះសម្មតិទេពបាន សូមព្រះអង្គទ្រង់ជ្រាប ។ ព្រះបរមក្សត្រិយ៍ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏ចាត់សេវកាមាត្យឲ្យបញ្ជូនទូវបុរសទាំងឡាយ

ដើម្បីព័ទ្ធចាប់នាងនោះ ដោយព្រះរាជឱង្ការត្រាស់បង្គាប់ដូច្នេះថា ម្នាលនាយដំរីរើនអើយ! បើដូច្នេះត្រូវអ្នកទាំងឡាយបបួលគ្នាព្រួតចាប់នាងធីតានោះឲ្យតែទានបាន យើងនឹងអភិសេកជាអគ្គមហេសីឲ្យវានេះឯង ។

ឯរាជបុរសដែលបានទទួលព្រះរាជបញ្ជាទាំងប៉ុន្មាន ក៏បានយកចិត្តទុកដាក់ព្រមគំនិតគ្នាថា យើងទាំងឡាយនឹងព្រួតចាប់នាងធីតានៅវេលាដែលបានធ្វើបូជាព្រះពោធិព្រឹក្សរួចហើយត្រឡប់មកវិញ ឲ្យបានតាមព្រះបញ្ជានោះឯង, លុះរាជបុរសទាំងនោះគិតដូច្នេះហើយ ក៏លាក់ខ្លួនពួនក្នុងទីកំបាំងមួយនៅសងខាងផ្លូវ ប្រុងប្រៀបនឹងចាប់យកនាងធីតានោះ ។

គ្រានោះ នាងពុទ្ធណីកុមារិកាក៏បានឡើងជិះលើខ្នងសេះ ហើយបរហោះទៅតាមអាកាស នាងបានទៅដល់មណ្ឌលមហាពោធិព្រឹក្សហើយ ក៏បូជាផ្កាកម្រងជាមួយនឹងព្រះអរិយទាំងឡាយរួចស្រេចហើយ ថ្វាយបង្គំត្រឡប់មកវិញ ។

កាលនោះមានព្រះអរហន្តមួយអង្គ ព្រះនាមធម្មរក្ខិតត្ថេរ លោកបានជ្រាបហេតុនោះជាក់ច្បាស់ ទើបលោកមានថេរវាចានឹងនាងពុទ្ធណីនោះថា ម្នាលឧបាសិកា! អាត្មាភាពបានឮថាក្នុងពាក់កណ្ដាលផ្លូវខាងមុខនោះមានចោរទាំងឡាយច្រើន បង្កប់ពួនលាក់ខ្លួនស្ងំនៅក្នុងទីនោះដើម្បីចាប់នាង បើនាងបានទៅដល់ទីនោះហើយ ត្រូវកុំប្រមាទប្រហែសធ្វេសខ្លួនឡើយ ត្រូវបរសេះទៅឲ្យលឿនឲ្យរហ័សទើបរួចខ្លួន ។

ចំណែកឯនាងតុល្លណីឧបាសិកាសោត កាលបើបានទៅដល់ទី
នោះហើយ ស្រាប់តែចោរទាំងឡាយចេញមកអំពីផ្ទាំងសងខាងរត់
ដេញប្រដិតជាប់តាមពីខាងក្រោយ នាងក៏ឲ្យសញ្ញា យកកែងគោះសេះ
នោះក៏ស្ទុះទៅដោយរហ័ស ចោរទាំងឡាយរត់ដេញជាប់តាមក្រោយពុំ
លែងឡើយ ។

ឯសេះសិន្ធពសោត ក៏ញាំងកម្លាំងយ៉ាងខ្លាំងឲ្យកើតឡើង ហើយ
ស្ទុះហោះទៅលើអាកាសដោយសំទុះដ៏ឆាប់រហ័សនោះ ។

នាងតុល្លណីកុមារិកា ពុំអាចទប់អាត្មានៅលើខ្នងសេះបាន ក៏ភ្លាត់
ធ្លាក់ខ្លួនចុះអំពីខ្នងសេះ នាងស្រែកហៅសេះសិន្ធពថា នែកូនអើយ !
អ្នកត្រូវនឹករលឹកឧបការគុណ ដែលម្ដាយបានធ្វើដល់អ្នកកុំភ្លេចឡើយ ។
កូនសេះសិន្ធពនោះបានស្ដាប់ហើយ ក៏ត្រឡប់ហោះបន្ទាបចុះមកដោយ
ឆាប់រហ័សយកខ្នងរងទទួលនាងតុល្លណី ដែលធ្លាក់ចុះមកនោះឲ្យជិះនៅ
លើខ្នងវិញដដែលពុំឲ្យធ្លាក់ចុះដល់ដីឡើយ ហើយស្ទុះហោះទៅលើអា
កាសវិញតែមួយរំពេច នាំនាងទៅឲ្យស្ថិតនៅក្នុងទីលំនៅរបស់នាងវិញ
ដដែល ពុំមានសេចក្ដីអន្តរាយអ្វីឡើយ ។ ព្រោះហេតុនោះព្រះអរហន្ត
ទាំងឡាយលោកពោលបទព្រះគាថាដូច្នេះថា:

តិរច្ឆានគតា ចេវ សរន្តិ ឧបការំ តំ

ន ជហន្តីតិ មន្តាន កតញ្ញូ ហោន្តុ ចាណិនោ

អធិប្បាយថា: សត្វទាំងឡាយបានដឹងថា ពួកសត្វតិរច្ឆានកាលរំលឹកនូវឧបការគុណគេ ហើយវៀងពុំលះបង់ចោលបុគ្គលដែលមានគុណនោះឡើយ លុះបានដឹងដូច្នេះហើយ ត្រូវតែធ្វើកតញ្ញូកតវេទីដល់លោកអ្នកមានឧបការគុណដល់ខ្លួនដោយពិត ៗ ឯនាងពុទ្ធណើកុមារិកាចាប់ដើមតាំងពីកាលនោះមក នាងបានចំណាយទ្រព្យទាំងប៉ែតសិបប្រាំពីរកោដិ ឲ្យប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនាតែម្យ៉ាង ហើយបានរក្សាសីលប្រាំ ធ្វើនូវឧបោសថសីលពុំដែលដាច់ដរាបដល់អស់ជីវិត , លុះនាងពុទ្ធណើឧបាសិកានោះ ច្យុតអំពីអត្តភាពនោះក៏ឡើងទៅកើតក្នុងស្ថានទេវលោក នាងសោយទិព្វសម្បត្តិទាំង៥ប្រការ មានរូបទិព្វជាដើម នាងបិតនៅក្នុងប្រាសាទកែវទាំង៧ប្រការ ដ៏ពេញដោយស្រីទេពអប្សរជាបរិវារអស្ចារ្យក្នុងពេលមួយរំពេច ដូចជាភ្ញាក់អំពីដេកលក់ដូច្នោះ ៗ

ព្រោះហេតុនេះ បានជាព្រះអរហន្តទាំងឡាយលោកពោលប្រដៅជនានុជនដោយបទព្រះគាថាដូច្នេះថា :

អតីតរុណាវយា ភោ មាតុតាមាបិ ឃរំ
វិវិធកុសលកម្មំ កត្វា សគ្គំ វជន្តិ
កុសលផលមហន្តំ មញ្ញមានា ភវន្តា
ភវថ កាថមុបេក្ខា ធាឯមាធាធិកាយេ

អធិប្បាយថា បពិត្រអ្នកដ៏ចំរើន ! សូម្បីស្ត្រីមានវ័យក្មេងពេកម៉្លេះ គង់ចេះមានប្រាជ្ញាឃើញត្រូវ អាចលះបង់ទ្រព្យជាច្រើន ធ្វើអំពើជាកុសលផ្សេងៗ ហើយបានឡើងទៅកាន់ស្ថានសួគ៌ សោយទិព្យសម្បត្តិយ៉ាងនេះ, ចុះអ្នកដ៏ចំរើនទាំងឡាយ កាលបើបានដឹងថា ផលរបស់កុសលមានច្រើនយ៉ាងនេះហើយ ទឹងធ្វើព្រងើយកន្តើយក្នុងកុសលកម្មមានទានទឹងការបូជាជាដើមដូចម្ដេចកើត ត្រូវតែខំខ្វល់ខ្វាយចំណាយទ្រព្យធ្វើទានជាដើមទើបគួរ ។

សម្ដែងរឿងនិទាន នាងពុទ្ធណាឧបាសិកាជាគំរប់បួន ក្នុងវគ្គទី១នេះ ក៏ចប់សេចក្ដីជាសង្ខេបតែប៉ុណ្ណោះឯង ។

៥- អហិតុណ្ឌិកវត្ថុកាថា សម្ដែងរឿងនិទានព្រានពស់ដូចមានគេពោលថា ឥមស្មឹ កិរ ភទ្ទកប្បេ ដូច្នេះជាដើម សេចក្ដីថា នៅក្នុងភទ្ទកប្បនេះ មានព្រះបរមគ្រូសាស្ដាមួយព្រះអង្គ ទ្រង់ព្រះនាមកស្សបៈ ព្រះអង្គបានត្រាស់ឡើងប្រាកដក្នុងលោក ព្រះអង្គតែងសម្ដែងធម៌ទេសនា ចម្លងមនុស្សលោក ព្រមទាំងទេវលោក ឲ្យឆ្លងផុតកាត់សមុទ្រសាគរគឺសំសារវដ្ដឲ្យបានដល់ត្រើយគឺព្រះនិព្វាន ព្រះអង្គញ៉ាំងពុទ្ធកិច្ចឲ្យសម្រេចស្រេចហើយ ទ្រង់ចូលព្រះបរមនិព្វានទៅ បីដូចជាព្រះអាទិត្យអស្ដង្គតដូច្នោះឯង ។

កាលនោះ មនុស្សទាំងឡាយដែលនៅក្នុងជម្ពូទ្វីបបានកសាងព្រះ

ចេតិយមានកំពស់មួយយោជន៍គឺយកថ្មនោសិលាមកធ្វើជាដីស្អិត យកប្រេងមកធ្វើជាទឹក ណាយរៀបក្បាច់ឥដ្ឋមាសមួយដុំ ៗ មានតម្លៃមួយកោដិ ៗ ទាំងវិចិត្រដោយកែវផ្សេង ៗ ពីខាងក្រៅ ហើយក្បាច់ឥដ្ឋមាសមួយដុំ ៗ មានតម្លៃប្រាំបីកោដិ ៗ ញដ៏ផ្ទៃខាងក្នុង ស្រេចហើយធ្វើសក្ការបូជាយ៉ាងធំបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធអង្គនោះ ។

កាលនោះ មានព្រានពស់ម្នាក់ តែងចាប់ពស់យកបានមកហើយក៏បង្ហឹកបង្ហាត់ប្រើពស់ឲ្យលេងល្បែងផ្សេង ៗ យកឈ្នួលពីប្រទេសនានាមានស្រុកនិគមជនបទជាដើម ជាស្បៀងចិញ្ចឹមជីវិតខ្លួននឹងកូនប្រពន្ធជានិច្ច លុះបានចូលទៅដល់ស្រុកមួយ ក៏បានឲ្យពស់លេងល្បែងផ្សេង ៗ ក្នុងស្រុកនោះ អ្នកស្រុកទាំងឡាយក៏មានសេចក្ដីត្រេកអរបានឲ្យរង្វាន់ជាច្រើន ព្រានពស់នោះបានបរិភោគខាទនីយៈនឹងភោជនីយៈផ្គួតបរិបូណ៌ហើយ ទើបសំណាក់អាស្រ័យនៅក្នុងស្រុកនោះឯង ។

បានឮមកថា មនុស្សទាំងឡាយដែលនៅក្នុងស្រុកនោះសុទ្ធតែជាមនុស្សសម្មាទិដ្ឋិ អ្នកកាន់គោរពប្រតិបត្តិព្រះរតនត្រ័យទាំងបីដោយច្រើន , ព្រោះហេតុដូច្នោះ ក្នុងវេលាពត្រី មនុស្សជាឧបាសកឧបាសិកាទាំងឡាយ កាលបើដឹកនាំទទួលធំណោកគេសូត្រនមស្សការរំលឹកគុណព្រះរតនត្រ័យថា:

(នៅមានត)

# មហោសថជាតក

(ត៥ក)

លោកអ៊ឹម-ភន បម្រួលពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កឹម-តូវ ពិនិត្យ

---

រីឯអាចារ្យសេនកស្ដាប់ព្រះបន្ទូលមហាក្សត្រហើយ ហេតុតែជាអ្នកលោភស័ក្តិយសទ្រព្យរបស់ច្រើន ចង់បានលាភសក្ការៈនោះម៉ិញ ក៏មកគិតទូលថា បពិត្រមហាពជអើយ នាបលោកហៅជាអ្នកប្រាជ្ញសុភាព មាត្រាបានធ្វើសាលាប៉ុណ្ណោះម៉្លោះទេគួរ លោកមិនពប់ហៅជាអ្នកប្រាជ្ញបានឡើយ បពិត្រមហាពជអើយ រីអំពើការតម្រិះអ្នកនោះតែអម្បាលម៉្លោះ ហៅចំណេះនោះតិចណាស់ណាមហាពជ ។ រីមហាក្សត្រស្ដេចស្ដាប់ពាក្យអាចារ្យសេនកទូលដូច្នោះហើយ ក៏ស្ដេចគង់ស្ងៀមនៅវិញហោង ទើបស្ដេចបន្ទូលថា នែអ្នកទាំងឡាយអើយ ចូរទៅកាន់ពជអាមាត្យនៅស្រុកបាចិនយវមជ្ឈគ្រាម ហើយចូលឲ្យពជអាមាត្យទាំងឡាយនោះមើលគលចំណាំ ទៅបណ្ឌិតអ្នកប្រាជ្ញនោះ ក្រែងមានហេតុការណ៍ម្ដេចៗវិញទៀតនោះ ចូរឲ្យមានដំណឹងមកដល់អញឲ្យបានដឹងផង ។ រីរាជទូតនោះ ក្រាបថ្វាយបង្គំប្រណម្យលាមហាក្សត្រ ទៅប្រាប់ពតិមានដូចមហាក្សត្របន្ទូលផ្ដាំនោះហោង ។

តគ្រិច រីមំសទនុពាទំ បពិត្រអើយ យើងទឹងស្រដីដំណើរ ដំណាលកាលព្រះបាទវិទេហរាជ ស្ដេចត្រាស់ប្រើឲ្យរាជអាមាត្យទៅ ចាំមើលល្បែងនៃព្រះមហោសថ ប្រាកដកាលព្រះអង្គយកជាតិកំណើត ជាពោធិសត្វនោះឯង ។

មំសំ គោណោ គន្ធុំ សុត្តំ បុត្តំ គោជំ រថេង ច
ទណ្ឌោ សីសំ អហិ ចេវ កុក្កុដោ មណី វិជាយនំ
ឱទនំ ពាលុកញ្ចាបិ តាឡាកុយ្យានំ គទ្រភោ
មណីតិ ។

មំសំ គឺល្បែងសាច់ ១, គោណោ គឺល្បែងគោ ១, គន្ធុំ គឺល្បែងសង្វារ ១, សុត្តំ គឺល្បែងអំបោះ ១, បុត្តំ គឺល្បែងកូន ១, គោជំ គឺល្បែងគោធកាឡ ១, រថេធច គឺល្បែងរទេះ ១, ទណ្ឌោ គឺល្បែងកំណាត់ឈើ ១, សីសំ គឺល្បែងក្បាលខ្មោច ១, អហិ ចេវ គឺល្បែងក្បាលពស់១, កុក្កុដោ គឺល្បែងមាន់១, មណី គឺល្បែងកែវមណីតែ៥១ វិជាយនំ គឺល្បែងការប្រសូតកូន១, ឱទនំ គឺល្បែងបាយជូរ១, ពាលុកាញ្ចាបិ គឺល្បែងពួរខ្សាច់ ១, តាឡាកំ គឺល្បែងស្រះ ១ ឧយ្យានំ គឺល្បែងឧទ្យាន១, គទ្រភោ គឺល្បែងលា១, មណីបិ គឺល្បែងមណីជោត១ ។ រីសការល្បែងផងទាំងឡាយនោះ ឯកូនវី- សតិ មាន១៩គត់, ឡើយទីលែងល្បែងផងទាំងឡាយនោះ យើងទុក

ស្ទះនៅនេះសិន, នេះនឹងស្រដៀងសាច់ឯងជាដើម ។

ឯកាទិវសំ ពោធិសត្តោ គាមទ្វារមណ្ឌលំ គច្ឆន្តោ ឯកោ សេនោ សូនផលកតោ មំសបេសឹ គហេត្វា អាកាសេន បក្ខន្ទិ ។ មានកាលសម័យថ្ងៃមួយគ្រូពោធិសត្វមហាបុរសរតនវិសេស អ្នកដើរទៅកាន់ឋានមណ្ឌលល្បែងអ្នកតែងលេងសព្វថ្ងៃនោះ ។ កាលនោះ មានអ្នកជង់មកចតសម្រាន្តនៅបរមសាលានៃព្រះមហាសត្វនោះ ហើយហាលសាច់នៅឰដ៏ចុងក្តារបែនបរមសាលានោះហោង ។ កាលនោះ មានសត្វខ្លែងមួយ វាហើរមកឆាបឆក់យកនៀតសាច់អំពីចុងក្តារបែននោះ ផ្លោះហោះហើរនាំឡើងទៅនាកណ្តាលអាកាសនោះហោង ។ រីអស់ក្មេងផងជាបរិវារនៃពោធិសត្វនោះមិញ កាលណាបើមិលមើលឃើញខ្លែងវាឆាបឆក់សាច់នោះហើយ វាស្រែកហៅហៅហៅគ្នាទៅវិញទៅមក ឲ្យដេញយកនៀតសាច់អំពីខ្លែងនោះហោង ម្ល៉ោះហើយអស់ក្មេងផងទាំងឡាយនោះ នាំគ្នារត់តាមដោយក្រោមខ្លែងហើរនោះឯង ។ រីខ្លែងនោះ វាពុំខ្លាចអំណាចក្មេងដេញនោះឡើយ ហើយវាហើរអំពីនោះទៅកាន់ឋានឯណា ៗហើយ រីអស់ក្មេងផងទាំងនោះ ក៏វាពុំលែងឡើយ ដើរវាតែងរត់ ក្អេកវាតែងមើលឯលើ តាមដោយក្រោមខ្លែង ដ៏មានដើរនោះដំពប់ទីងដុំដី ដុំថ្ម កំណាត់ឈើ អម្បែងចែស អម្បែងចាន គ្រួសរវ៉ាន់គល់ឈើ ចុងឈើ នោះវាដួល

ភីងចុះ ជង្គង់រលាត់ មាត់នោះដូចជាគេវាំងដី ផង់ចូលទៅក្រប់កក់ជាប់មុខ ស្រមូញស្រមាញ ប្រវាំងើបឡើងដ៏ម្នាក់ដេញទៅទៀត ។

ក្នុងកាលនោះ ព្រះពោធិសត្វអ្នកស្រដីទៅនឹងអស់ក្មេងទាំងឡាយថា ម្នាលក្មេងទាំងឡាយអើយ ចូរអ្នកទាំងឡាយមើលអញ អញនឹងដេញខ្លែងនោះឯងឥឡូវនេះ ឲ្យខ្លែងនោះមានទុក្ខភិតភ័យ ះចាលនៀតសាច់នោះឥឡូវនេះមិនខានឡើយ ទោះហើយអស់ក្មេងទាំងឡាយស្រដីថាសាមិ បពិត្រអង្គម្ចាស់អើយ ចូរម្ចាស់ធ្វើឲ្យខ្លែងនោះវាប្រាសលះបង់បោលនូវនៀតសាច់នោះល្បឿនមើលម្ចាស់ ។ ព្រះមហាសត្វស្ដាប់ពាក្យហើយឆ្លើយថា អើបើដូច្នោះ ចូរអ្នកទាំងឡាយមើលអញណា ។ ទើបពោធិសត្វអ្នកលីលាចុះពីបរមសាលានោះ ហើយអ្នកសំឡឹងមើលឡើងទៅលើ ហើយអ្នកតែតាមដោយនូវកម្លាំងអ្នកនោះធាប់ស្មុំឲ្យល់ព្រះអង្គយល់ស្រមោលខ្លែងនោះហើយ អ្នកទះនូវព្រះហស្ដជាងឹងៗហើយអ្នកស្រែកនូវស័ព្ទសំរែកនោះខ្លាំងក្រៃ ស័ព្ទនោះរន្ទុះព្ធទៅដល់ខ្លែងនោះ វាក៏គិតស្មុតហាក់ដូចគេពុះទំលាយទ្រូងចេញ ហើយខ្លែងនោះភិតភាំងរង់តាំងអស់ទាំងចំរេងស្ដាប់ នឹងប្រឹងហើរទៅពុំរួចឡើយ ដោយនូវតេជះព្រះប្រាជ្ញាបារមីនៃអ្នកនោះហោង ។ ពោធិសត្វអ្នកមិលមើលតែស្រមោលខ្លែងហើរនោះហើយអ្នកទះស្រមោលខ្លែងនោះក្ដី ខ្លែងវាប្រឹងរងំពុំបាន វាជំរុះនូវនៀតសាច់ស្រែចះហើយ អ្នកស្ទុះឡើងទៅទទួល

ចាប់យកនូវដុំសាច់នោះអំពីកណ្តាលអាកាសនោះឯងបានហោង ពុំអាច ដើម្បីនឹងឲ្យជ្រុះចុះដល់ដីឡើយ ។ បពិត្រអ៊ីយ រីអស់មហាជនផងទាំងឡាយនោះ យល់ឃើញហេតុមានជាអស្ចារ្យដូច្នោះហើយ សឹងស្រែកនូវស័ព្ទសាធុការនោះខ្ទាំង ឲ្យសាធុការមហិមាកងរំពងក្រៃពេក ។

រីរាជអាមាត្យនោះ បានដឹងយល់ស្តែងប្រាកដហើយ ប្រើរាជទូតចូលទៅក្រាបទូលព្រះបាទវិទេហរាជ ដោយដំណើរដែលគាត់បានយល់ប្រាកដនោះហោង ។ ព្រះបាទវិទេហរាជព្រោះសុភាពដូច្នោះហើយ មានព្រះហឫទ័យនោះត្រេកអរសាទរមហិមា ហើយបន្ទូលទៅកាន់អាចារ្យសេនកថា ហៃអាចារ្យសេនក ឥឡូវនេះ យើងនឹងឲ្យទៅនាំយកនូវចៅអ្នកប្រាជ្ញនោះមកឬម្តេចហ្ន៎ ? ។ រីអាចារ្យសេនកនោះ ហេតុតែជាអ្នកកំណាញ់យសលាភនោះមិញ ក៏គិតក្នុងចិត្តថា បើអញគិតព្រមលមឲ្យទៅនាំចៅអ្នកប្រាជ្ញនោះមកហើយ រីអស់យើងជាអ្នកប្រាជ្ញទាំង ៤ នេះ ក៏សឹងកើតជាអ័ប្បយសចុះលាភសក្ការៈផងពុំបានដូចកាលអំពីមុននោះឡើយ ពោះយោបីស្តេចជ្រាបថាជាអ្នកប្រាជ្ញក្តី ពោះពុំថាជាអ្នកប្រាជ្ញក្តី យើងគិតឲ្យស្ងៀមទុកនៅនោះសិនហោង ។

រីអាចារ្យនោះគិតដូច្នោះហើយ ក៏ក្រាបទូលឃាត់ពុំឲ្យមហាក្សត្រស្តេចឲ្យទៅនាំចៅមហោសថអ្នកប្រាជ្ញនោះមកឡើយ ។ រីអាចារ្យសេនកកាមិន្ទ, ទេវិន្ទ, បុក្កុស គិតព្រមគ្នាដូច្នោះហើយទូលថា

បពិត្រមហារាជអើយ ,  នាយលោកហៅថាអ្នកប្រាជ្ញផង  មានប្រការអម្បាលនោះហើយ  លោកក៏មិនគប្បីហៅថាជាអ្នកប្រាជ្ញឡើយ, បពិត្រអម្ចាស់អើយ រីតម្រេះទៅមហោសថតែប៉ុណ្ណោះ ដូច្នេះនោះ ក៏ហៅតម្រេះគិតណាស់ក្នុងណាមហារាជ ។ ព្រះមហាក្សត្រស្ដេចស្ដាប់ពាក្យអាចារ្យទាំង៤នោះហើយ ស្ដេចគង់ស្ងៀមនៅហោង, ទើបស្ដេចត្រាស់ប្រើរាជទូតនោះ ឲ្យនាំពត៌មានទៅកាន់រាជសាមាត្យនោះវិញទៀត ប្រយោជន៍ដើម្បីនឹងឲ្យដឹងនូវដំណឹងនៃចៅអ្នកប្រាជ្ញនោះហោង ។

ឃោសា  ចាចីឆយវជ្ជតាមកសប្បុរិសោ  ។ល។ ឱក្ខាមិ ។ បពិត្រអើយ រីនឹងស្រដីល្បងគោសោត កាលនោះមានបុរសកំសត់មួយចិញ្ចឹមជីវិតអាត្មា នៅស្រុកបាចីនយវមជ្ឈគ្រាមនោះ លុះដល់ខែហេមន្តរដូវភ្ជួររាស់គួរ  បុរសនោះគិតក្នុងចិត្តឯងថា អញអើយ ឥឡូវនេះមិញគួររដូវភ្ជួររាស់ហើយ ដូច្នេះតើអញបានអ្វីជាគោជាគ្រឿងនឹងធ្វើស្រែនឹងគេអេះ  បុរសនោះគិតដូច្នោះហើយ ក៏យកនិទៅនូវមាសប្រាក់ ដើរស្រោកទៅរកទិញគោគេអំពីស្រុកឯទៀត ជាវនោះបានហើយ ក៏ស្រ័យនាំមកដល់លំនៅអាត្មា លុះព្រឹកឡើងវិញទៀតហើយ ទើបបុរសនោះនាំគោចេញទៅទីឲ្យស៊ីស្មៅនៅឰដ៏ផ្ទៃបឹងក្រោម បុរសនោះដេកលើខ្នងគោនោះទៅ ដ៏មានខ្លួននោះនឿយព្រួយលំបាក ហេតុត្រូវខ្យល់អំពល់នូវកំដៅព្រះអាទិត្យជិតបៀតបៀនអាត្មា ហើយម្នាចុះចេញ ហើយលែងគោទៅឲ្យស៊ីស្មៅ ហើយទៅអង្គុយ

ក្រោមម្លប់ឈើមានញ្ញដ៏ក្ដូមិចាស់មួយក្ដូវ គាប់ជួនត្រូវខ្យល់បក់មកត្រជាក់ហើយត្រសៀកៗ ក៏ប្រះខ្លួនដេកដុះលក់ស្រមុកខ្ចុរៗ នៅក្រោមម្លប់ឈើនោះហោង ។ ក្នុងកាលនោះសោត មានអាចោរម្នាក់ដើរមកលួចយកបានគោនោះដឹកនាំពន្លត់ទៅហោង ។ រីឯម្ចាស់គោនោះវិញ ភ្ញាក់រលឹកដោះឡើងអំពីដេក ក្រឡេកមើលមើល ទៅមិនយល់គោនោះឡើយ ហើយក្រោកដោះឡើងមើលទៅឯណេះ ឯណោះហើយក្ដូវ យល់អាចោរវាដឹកបំបោលគោនោះចេញទៅហោង ។

រីឯបុរសនោះវិញ រត់ដេញតាមទៅដោយទូរកំឡាំងនោះឆាប់ក្ដាត់ជិតៈទៀបហៀបនឹងដល់ក្ដូវ ក៏ស្រែកទៅថា ហៃយៗឯងយកគោអញទៅឯណាហ្នឹង ? ។ ឯអាចោរនោះក្ដុះហើយឆ្លើយថា យើ! ឯណាគោព្រះស្ដែន នោះហ្នឹង ! គោអញអេះ, កំម្ដេចព្រះស្ដែនមកថាគោព្រះស្ដែនដូច្នោះហ្នឹង! ម្ល៉ោះហើយបុរសទាំង២ នោះកើតពាក្យជំលោះប្រកែកទៅមកកាន់គ្នានោះក្រៃពេក, រីឯសមហាជនទាំងពួង សឹងក្ដុះក្លូវស័ព្ទជំលោះប្រកែកនៃបុរសទាំង ២ នោះហើយ សឹងជំនុំគ្នានៅមាត់សាលានៃចៅអ្នកប្រាជ្ញនោះ លុះបុរសទាំង ២ នោះប្រកែកគ្នាទៅដល់ទ្វារសាលានោះហើយ ទើបពោធិ-សត្វឲ្យហៅបុរសទាំង ២ នោះមកហើយ ព្រះមហាសត្វអ្នកយល់បុរសទាំង ២ នោះហើយ អ្នកស្គាល់ដោយនូវព្រះប្រាជ្ញាឯងថា អ្នកនោះឯងជាចោរ បុរសនោះឯងជាម្ចាស់គោ រីពោធិសត្វសួម្បីអ្នកជំនឹង

ហើយក៏អ្នកធ្វើជាមិនដឹងវិញ, ហើយមានព្រះបន្ទូលដូច្នេះថា ម្នាលបុរស ទាំង ២ អើយ នាព្រះស្តេងទាំង២ ធ្វើពាក្យជំលោះប្រកែកនឹងគ្នានេះ តើហេតុប្រការអ្វីហ្នឹង ? រីបុរសជាម្ចាស់គោនោះមិញ ជំរាបប្រាប់មកពោធិសត្វវិញថា សាមិ បពិត្រម្ចាស់អើយ, រីអញខ្ញុំទិញគោនេះ អំពីស្រុកនោះឈ្មោះដូច្នោះ ។ ហើយអញខ្ញុំមកទុកក្នុងផ្ទះ លុះព្រឹកឡើងខ្ញុំនាំទៅភូមិតាស់ទាទានស្មៅល្អ អញខ្ញុំលែងគោឲ្យស៊ីស្មៅ ហើយខ្ញុំទៅដេកក្រោមម្លប់ឈើមួយប្រណុក កាលណាបើខ្ញុំដេកលក់ហើយក្លូវ គាត់នេះយកគោអញខ្ញុំនាំពង្រត់ទៅហោង ។ កាលនោះ រីគោចោរនោះមិញទូលថា បពិត្រម្ចាស់អើយ រីគោខ្ញុំនេះវាកើតក្នុងផ្ទះខ្ញុំឯង រីគាត់នេះសោត មកស្រដីពាក្យក្លូតបំភោតហ្វូ គោខ្ញុំទេអម្ចាស់ , លំដាប់នោះរីបរមហោសថអ្នកប្រាជ្ញ ស្រដីទៅនឹងបុរសទាំង ២ ថា ម្នាលបុរសទាំង ២ អើយ ចូរព្រះស្តេងស្វែងសណ្តិតសេចក្ដីនេះទុកមួយអន្ទើសិន , ឥឡូវនេះព្រះស្តេងទាំង ២ ឋិតទៅដោយបង្គាប់ពណ៌នានៃអញនេះឬទេ? ។ បុរសទាំង ២ នោះឆ្លើយថា សូមទានបើដូច្នោះ យើងខ្ញុំទាំង ២ នេះនឹងឋិតក្នុងឋាននេះ ដូចបង្គាប់អម្ចាស់ហោង ។ រីព្រះមហាសត្វអ្នកគិតថា គួរអញនឹងយកចិត្តនៃបុរសទាំង ២ នេះ ហើយនឹងដណ្ដឹងគោចោរឯងជាមុន, ទើបអ្នកដណ្ដឹងទៅចោរថា ម្នាលបុរសអើយ រីគោព្រះស្តេងនោះ ឲ្យស៊ីអ្វីផឹកអ្វីខ្លះ ៗ ហ្នឹង ? ឯគោចោរឆ្លើយថា អម្ចាស់អើយ ! គោខ្ញុំនេះ ខ្ញុំឲ្យផឹកតែយាគូ ឲ្យស៊ីតែស្លឹកសណ្តែកបំណែកល្ងនោះហោង ។

ព្រះមហាសត្វអ្នកឲ្យកត់សំគាល់ស្រេចហើយ ទើបអ្នកជណ្តឹងទៅបុរស
ម្ចាស់គោនោះជាខាងក្រោយវិញ បុរសជាម្ចាស់គោនោះឆ្លើយថា អម្ចាស់
អើយ, វេយាគូនេះ ខ្ញុំជាអ្នកកំសត់ទុគ៌តដូច្នេះ តែខ្ញុំបានយាគូនោះអំពី
ណា វីគោនេះ នៅតែស្មៅនោះហោង ៗ ពោធិសត្វឲ្យកត់ពាក្យអ្នក
ទាំង ២ នោះស្រេចហើយ ទើបប្រើឲ្យបុរសអ្នកបំរើគាត់ ឲ្យយកទឹក
ដាក់ទឹងថាសស្រេចហើយ អ្នកឲ្យយកប្រិយង្គុមកបុកប្រឡាក់ទឹកឲ្យបំផឹក
គោនោះហោង គោនោះកាលណាបើផឹកទឹកនោះហើយ ក៏ក្អួតចេញមក
សុទ្ធតែស្មៅឯងហោង ឯចៅអ្នកប្រាជ្ញជណ្តឹងទៅកាន់អស់មហាជនទាំង
ឡាយថា ម្នាលអ្នកទាំងឡាយអើយ ចូរអ្នកទាំងឡាយរមិលមើលចុះ
ម្ល៉ោះហើយអ្នកជណ្តឹងឯអាចោរថា ម្នាលបុរសអើយ ព្រះស្អែងជាចោរ
ឬមិនជាចោរ, ឯអាចោរនោះ[illegible]តឆ្លើយថា អម្ចាស់អើយ ខ្ញុំម្ចាស់ជា
ចោរពិតហោង ទើបពោធិសត្វមហាបុរសតេ៌អ្នកឲ្យដំជើង·ដៃនៃបុរស
នោះឲ្យរាប់ថយកំឡាំង ទើបអ្នកឲ្យដំបូន្មានថា ម្នាលបុរសអើយ ចូរអ្នក
ទល់ទុក្ខនាលោកិយនេះក្សិណ ដោយទូរសភាពរបស់ប្រាកដឯង លុះ
ព្រះស្អែងនឹងទល់ទុក្ខវេទនានៅក្នុងមហានរក ជាទូរទៅក្រៃលែងជាងនេះទៅ
ទៀត, ចាប់ដើមអំពីនោះទៅ កុំបីព្រះស្អែងធ្វើអំពើដូច្នេះឡើយ ៗ ក្សិណ
នោះ រាជទូតនាំពាក្យមានទៅទូលព្រះបាទវិទេហរាជនោះ ៗ

(នៅមានត)

## ប្រវត្តិនាងឥសិទាសីថេរី

ឃុនសុវត្ថិវេទី យូរ-អ៊ុន

*ប្រែចាកថេរីគាថា ត្រង់ចត្តាឡីសនិបាត*

*នៃសុត្តន្តបិដក ខុទ្ទកនិកាយ*

---

បុរសស្ត្រីក្នុងលោកិយលុះតណ្ហា
ក្នុងកាមាធិការមេជាផងគេ
តែងរងទុក្ខក្នុងនរកគ្មានស្រាកល្ហែ
តមកប្រែកើតជាប្រេតតិរច្ឆាន ។
រួចពីនោះកើតជាមនុស្សមានភេទខ្ទើយ
លុះបង្ហើយទើបមានភេទស្រីប្រុសប្រាណ
តែគង់ពៀរតាមផ្ដន្ទាយ៉ាងក្លាហាន
បៀសពុំបានដូចនិទានតទៅនេះ ៖-

*ក្នុងនគរកុសុមបាដលិបុត្ត ដែលជាមណ្ឌលនៃផែនដី មានភិក្ខុនីពីររូប ជាធីតាក្នុងសាក្យត្រកូល ជាអ្នកមានគុណសម្បត្តិក្នុងពុទ្ធសា-សនា ។ បណ្ដាភិក្ខុនីទាំងពីររូបនោះ ភិក្ខុ១រូប ឈ្មោះ ឥសិទាសិ*

ភិក្ខុនីទី២ ឈ្មោះ ពោធិ ជាអ្នកបរិបូណ៌ដោយសីល ត្រេកអរដោយការរំពឹងក្នុងឈាន ជាពហុស្សុត មានកិលេសកំចាត់បង់ជ្រះស្រឡះហើយ ៗ ក្នុងថ្ងៃមួយ ភិក្ខុនីទាំងពីររូបនោះត្រាច់ទៅបិណ្ឌបាត ហើយធ្វើនូវភត្តកិច្ច រួចលាងបាត្រហើយ ក៏អង្គុយជាសុខស្រួលក្នុងទីស្ងាត់ ៗ នាងពោធិ· ភិក្ខុនីបានផ្ដើមសួរថា ម្នាលឥសិទាសី នាងជាស្ត្រីមានរូបល្អស្រស់ត្រជ្រះថ្លា ទាំងវ័យរបស់នាងក៏មិនទាន់ចាស់ទេ តើចុះ នាងឃើញទោសដូចម្ដេច ទើបមកប្រកបខ្លួនក្នុងបព្វជ្ជាភេទ ?

ឥសិទាសីភិក្ខុនីនោះ ជាអ្នកឈ្លាសវៃក្នុងធម្មទេសនា កាលបើពោធិភិក្ខុនីសាកសួរ ក្នុងហេតុជាប្រយោជន៍យ៉ាងនេះហើយ ក៏បានពោលនូវពាក្យនេះថា ម្នាលនាងពោធិ នាងចូរស្ដាប់តាមដំណើរដែលខ្ញុំបួសចុះ ខ្ញុំនឹងសំដែងដូចតទៅនេះ :-

បិតារបស់ខ្ញុំ ជាសេដ្ឋី អ្នកសង្រួមសីល នៅក្នុងបុរីដ៏ប្រសើរឈ្មោះឧជ្ជេនី ក្នុងដែនអវន្តិ ៗ ខ្ញុំជាធីតាម្នាក់ដែលជាទីស្រឡាញ់ពេញចិត្តបិតា ជាអ្នកគួរទទួលសេចក្ដីអនុគ្រោះរបស់បិតានោះ ៗ លុះចំណេរមកខាងក្រោយ មានសេដ្ឋីម្នាក់មានត្រកូលឧត្ដម មានទ្រព្យច្រើន នៅឯនគរសាកេត បានមកដណ្ដឹងខ្ញុំ ៗ បិតាក៏បានឲ្យខ្ញុំជាកូនប្រសាររបស់សេដ្ឋីនោះ ៗ ខ្ញុំចូលទៅក្រាបក្បាលថ្វាយបង្គំ នូវជើងម្ដាយក្មេកនិងឪពុកក្មេក ពេលល្ងាចព្រឹក តាមដំណើរដែលមាតាបិតាប្រដៅខ្ញុំ ៗ ខ្ញុំកាលបើបាន

ឃើញនូវអ្នកដែលមកដណ្តឹងខ្ញុំ សូម្បីម្នាក់ ជាបងប្អូនប្រុស ឬបងប្អូនស្រី ឬក៏ជាបរិវាររបស់ស្វាមី ខ្ញុំក៏រលះរលំងក្រាលអាសនៈទទួល ហើយអង្គាសផ្គត់ផ្គង់ ឲ្យបាយទឹកទំនិញបន្ថែម ដែលមានក្នុងទីលំនៅនោះ តាមសមគួរដល់តែដែលគេត្រូវការ ៗ ខ្ញុំតែងក្រោកឡើងតាមកាលគួរ ហើយចូលទៅគោរពប្រណិបត៌ន៍ប្តី ខ្ញុំជូតលាងដៃជើងប្តី ទាំងជូតសំអាតនូវធរណីទ្វារជាដើម ៗ ខ្ញុំយកស្និតសក់ ម្សៅសម្រាប់លាបមុខ ថ្នាំសម្រាប់បន្តក់ភ្នែកទឹកកញ្ចក់ ស្អិតស្អាងប្តីដោយខ្លួនឯង ហាក់ដូចជាខ្ញុំស្រីដែលធ្វើនូវការបំរើម្ចាស់ ៗ ខ្ញុំដាំបាយខ្លួនឯង លាងភាជន៍ខ្លួនឯង ខ្ញុំថ្នមកស្តា ដូចមាតាបិតាថ្នមកូនខ្ចី ៗ តែកស្តាខ្ញុំ តែងរឹងសម្បាទឹងខ្ញុំ ដែលជាស្រីបំរើបាយ គ្មានស្រីណាលើស ជាស្រីធ្វើការគ្រប់យ៉ាង ជាស្រីមិនមានសេចក្តីប្រកាន់ មានសេចក្តីព្យាយាមមិនខ្ជិលច្រអូស មានមារយាទត្រឹមត្រូវយ៉ាងនេះ ៗ ស្វាមីនៃខ្ញុំនោះ និយាយនឹងមាតាបិតារបស់គេថា ខ្ញុំសូមលាលោកឪពុកលោកម្តាយ ទៅនៅកន្លែងណាមួយហើយ ព្រោះខ្ញុំមិនអាចនៅរួមគ្នាក្នុងផ្ទះមួយ ជាមួយនាងឥសិទាសីជាប្រពន្ធខ្ញុំឡើយ ៗ មាតាបិតានៃប្តីខ្ញុំ ពោលថា នែកូនប្រុសសំឡាញ់ កូនកុំពោលយ៉ាងនេះឡើយ នាងឥសិទាសី ប្រពន្ធកូនឯង ជាបណ្ឌិតឈ្លាសវៃ ជាស្រីមានសេចក្តីព្យាយាម មិនខ្ជិលច្រអូសទេ ឱកូនអើយ ហេតុអ្វីក៏កូនមិនពេញចិត្ត

នឹងប្រពន្ធ ៗ ប្ដីខ្ញុំពោលថា ឱលោកម្ដាយលោកឪពុក នាងឥសិតាសី មិនបៀតបៀនអ្វីដល់ខ្ញុំទេ ប៉ុន្តែខ្ញុំមិនអាចនៅជាមួយនឹងនាងឥសិតាសី ព្រោះនាងឥសិតាសីជាស្ត្រីស្អប់របស់ខ្ញុំ ខ្ញុំមិនគួរនឹងនៅរួមឡើយ ខ្ញុំសូមលាទៅហើយ ៗ ម្ដាយក្មេកនឹងឪពុកក្មេកខ្ញុំបានស្ដាប់ពាក្យប្ដីខ្ញុំនោះហើយ ក៏សួរមកខ្ញុំថា នែកូនស្រី ចុះនាងមានធ្វើខុសអ្វីនឹងប្ដីនាងទេ នាងចូរប្រាប់កំហុសដែលនាងធ្វើហើយ តាមសេចក្ដីពិតមកចុះ ៗ

ខ្ញុំក៏តបថា ឱលោកម្ដាយលោកឪពុក ខ្ញុំមិនបានប្រទូស្ដទេ ខ្ញុំមិនបៀតបៀន មិនពោលពាក្យអាក្រក់ទៅគេគាត់ទេ បើកស្ដាខ្ញុំស្អប់ខ្ញុំ តើឲ្យខ្ញុំធ្វើអ្វីត្រូវចិត្តគាត់ ៗ ម្ដាយក្មេកនឹងឪពុកក្មេកខ្ញុំនោះ ក៏អាក់អន់ចិត្តត្រូវសេចក្ដីព្រួយគ្របសង្កត់ ក៏នាំខ្ញុំត្រឡប់ទៅប្រគល់ឲ្យមាតាបិតាខ្ញុំវិញ ដើម្បីរក្សាចិត្តកូនប្រុសរបស់គាត់ ដោយគិតថា នឹងរកឲ្យបាននូវស្ត្រីមានរូបឆោមដ៏មានសិរី មកធ្វើជាប្រពន្ធនៃកូនគាត់ ៗ គ្រាក្រោយមកមាតាបិតាបានឲ្យខ្ញុំមានប្ដីម្ដងទៀត ប្ដីគ្រាទី ២ នេះ ជាអ្នកស្ដុកស្ដមបានជួះជំនូនចំនួនពាក់កណ្ដាលអំពីជំនូនដែលសេដ្ឋីឪពុកប្ដីមុន បានជូនមកខ្ញុំនោះ ៗ ខ្ញុំនៅក្នុងផ្ទះនៃប្ដីទី ២ នោះ បានតែ១ខែគត់ គ្រានោះប្ដីខ្ញុំបែរជាស្អប់ខ្ញុំ លែងខ្ញុំចោល ដែលជាស្ត្រីខ្នះខ្នែងបំរើដូចទាសីជាស្ត្រីមិនប្រទូស្ដ មានមារយាទល្អ ៗ

ក្នុងថ្ងៃមួយ បិតារបស់ខ្ញុំ បានឃើញបុរសម្នាក់ ជាអ្នកប្រព្រឹត្តទូន្មានចិត្ត ទូន្មានកាយទាំងពីរ ដែលកំពុងត្រាច់ទៅដើម្បីភិក្ខា បិតាខ្ញុំពេញចិត្តនឹងបុរសនោះ ទើបនិយាយបបួលថា អ្នកចូរមកធ្វើជាកូនប្រសារបស់ខ្ញុំចុះ អ្នកចូរបោះចោលនូវកំណាត់សំពត់នឹងផ្តាំងទៅ ។ បុរសនេះក៏បានទទួលធ្វើតាមពាក្យបិតាខ្ញុំ ហើយចូលមកនៅរួមនឹងខ្ញុំ ។ ស្វាមីទី៣ បាននៅជាមួយនឹងខ្ញុំអស់កន្លះខែ ក៏និយាយនឹងបិតាខ្ញុំថា អ្នកចូរឲ្យកំណាត់សំពត់ ផ្តាំងនឹងអំបែងមកខ្ញុំ ខ្ញុំសូមលានឹងត្រាច់ទៅដើម្បីភិក្ខាវិញពីថ្ងៃនេះទៅ ខ្ញុំឈប់នៅក្នុងផ្ទះនេះហើយ ។ គ្រានោះមាតាបិតានឹងពួកញាតិទាំងអស់របស់ខ្ញុំ និយាយនឹងបុរសនោះថា អ្នកណាមិនធ្វើតាមអ្នកក្នុងទីនេះឬ អ្នកចូរប្រាប់ហេតុដែលគេធ្វើនោះ ដល់យើងឲ្យដាច់ ។ បុរសនោះកាលបើគេសួរយ៉ាងនេះហើយ ក៏ពោលតបថា បើខ្លួនខ្ញុំអាចនៅបាន ក៏នាងឥសិទាសីមិនគួរនៅរួមជាមួយនឹងខ្ញុំ ព្រោះហេតុនោះខ្ញុំមិននៅជាមួយនាងឥសិទាសីក្នុងផ្ទះមួយជាមួយគ្នាទេ ។ បុរសនោះកាលបើពោលយ៉ាងនេះ រួចក៏លាបិតារបស់ខ្ញុំធ្វើដំណើរចេញទៅបាត់ទៅ ។

ចំណែកខាងខ្ញុំ ជាស្ត្រីនៅតែម្នាក់ឯង មានទុក្ខធ្ងន់ខ្លាំង គិតថា អាត្មាអញត្រូវលាមាតាបិតាទៅស្លាប់ ឬទៅបួស ។ គ្រានោះ មានថេរីមួយរូបឈ្មោះ ជិនទត្តា ជាអ្នកទ្រទ្រង់នូវវិន័យ ជាពហុស្សូត បរិបូណ៌ដោយ

សីល  កាលគ្រាចំទៅដើម្បីភិក្ខាហារ  ក៏បាននិមន្តមកកាន់ត្រកូលនៃបិតារបស់ខ្ញុំ ។ ខ្ញុំកាលនាងជិនទត្តាថេរីនោះនិមន្តមកដល់ ក៏ក្រោកឡើង ក្រាលអាសនៈប្រគេន លុះព្រះនាងគង់ហើយ ខ្ញុំក៏ថ្វាយបង្គំនូវព្រះបាទា ហើយប្រគេនភោជន ។ ខ្ញុំញុំាងជិនទត្តាថេរីឲ្យឆ្អែតស្កប់ស្កល់ដោយបាយទឹកនិងបង្អែមដែលមានក្នុងទីលំនៅខ្ញុំនោះ ហើយទូលថា បពិត្រព្រះនាងជាម្ចាស់ ! ខ្ញុំចង់បួសឲ្យបានដូចលោកម្ចាស់ដែរ ។ គ្រានោះបិតាពោលនឹងខ្ញុំថា ម្នាលកូនស្រីបិតា កូនកុំបួស នាងចូរប្រព្រឹត្តធម៌នោះក្នុងផ្ទះនេះវិញចុះ ហើយចូរធ្វើបុណ្យឲ្យទាន ដោយញុំាងសមណៈទាំងឡាយផង ព្រាហ្មណ៍ទាំងឡាយផង ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកចុះ ។ លំដាប់នោះ ខ្ញុំក៏ប្រណម្យអញ្ជលីយំពោលនឹងបិតាថា បពិត្របិតា ! សូមបិតាអនុញ្ញាតខ្ញុំ ខ្ញុំនឹងញុំាងបាបកម្មដែលខ្ញុំធ្វើហើយនោះឲ្យវិនាស ។ គ្រានោះ បិតាបានយល់ព្រមតាមពាក្យខ្ញុំ ហើយពោលនឹងខ្ញុំថា ព្រះសម្មាសម្ពុទ្ធព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ណា នាងចូរបានលុះនូវពោធិញាណនិងអគ្គធម៌ ព្រមទាំងព្រះនិព្វាននោះចុះ ។

វេលានោះ ខ្ញុំថ្វាយបង្គំលាមាតាបិតា នឹងពពួកនៃញាតិទាំងអស់ ហើយចេញទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធ លុះបួសបាន ៧ ថ្ងៃ

ក៏បានសម្រេចវិជ្ជាចំ ។ ខ្ញុំដឹងជាតិរបស់ខ្លួនបាន ៧ ជាតិ ។ ផល
វិបាកនេះរបស់កម្មណា ខ្ញុំនឹងប្រាប់នូវកម្មនោះដល់នាង ហេតុនេះ នាង
ចូរមានចិត្តមូលតែមួយ ចាំផ្ទៀងសោតស្តាប់នូវកម្មនោះ ដូចតទៅនេះ

នែនាងពោធិ ! ក្នុងអតីតជាតិ ខ្ញុំជាភេទប្រុស ធ្វើជាជាងមាសមាន
ទ្រព្យច្រើននៅក្នុងនគរឯកកច្ចៈ ។ ខ្ញុំនោះជាមនុស្សស្រវឹងវ័យ បានប្រព្រឹត្ត
សេពសម្ផពនឹងប្រពន្ធបុគ្គលដទៃ ។ លុះខ្ញុំឃ្លាតចាកអត្តភាពនោះហើយ
ក៏ឆេះពលពលក្នុងនរកអស់កាលយូរ លុះរួចចាកនរកនោះហើយ មក
ចាប់បដិសន្ធិក្នុងផ្ទៃនៃមេស្វា ។ ស្វាឈ្មោលធំ ជាម្ចាស់នៃហ្វូង បានខាំ
ផ្តាច់នូវអង្គជាតរបស់ខ្ញុំ ដែលទើបនឹងកើតបាន ៧ ថ្ងៃ ។ នេះជាផលនៃ
កម្មរបស់ខ្ញុំនោះ ដែលសេពគប់នូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំនោះលុះ
ច្យុតចាកកំណើតនៃស្វានោះហើយ ក៏បានមកចាប់បដិសន្ធិក្នុងផ្ទៃនៃមេ
ពពែ ។ ខ្ញុំជាពពែខ្វាក់ផង ខ្ចកផង ក្នុងដែននៃស្តេចសិន្ធវៈ ។ ខ្ញុំត្រូវ
គេព្រនាក់កូនក្មេងអស់ ១២ ឆ្នាំ ត្រូវគេក្រៀវមានដង្កូវបៀតបៀន ព្រម
ទាំងឈឺចាប់ខ្លោចផ្សាក្រៃលែង នេះព្រោះតែអំពើដែលខ្ញុំសេពនូវប្រពន្ធ
របស់បុគ្គលដទៃ ។ ខ្ញុំនោះកាលច្យុតចាកកំណើត នៃពពែនោះហើយ
ក៏កើតជាកូនគោអំពីមេគោ របស់ឈ្មួញគោ ខ្ញុំជាកូនគោខ្វាក់ ខ្ចក ។
កាលខ្ញុំកើតបាន ១៦ ខែ មានរោមក្រហមដូចជ្រលក់ល័ខ ក៏ត្រូវគេ

ក្រៀវ ៗ ខ្ញុំតែងទាញនង្គ័លនឹងរទេះទៅទាំងខ្វាក់ទាំងខ្វក ឈឺចាប់ ៗ នេះព្រោះតែខ្ញុំសេពទូវប្រពន្ធនៃបុគ្គលដទៃ ៗ ខ្ញុំនោះលុះច្យុតចាកកំណើតនៃគោនោះហើយ ក៏បានមកកើតក្នុងផ្ទៃនៃទាសីម្នាក់នៅក្នុងផ្ទះវៃស្យថ្មល់ ៗ ខ្ញុំមានភេទមិនប្រាកដជាស្រី មិនប្រាកដជាប្រុស (ខ្ទើយ) ៗ នេះព្រោះតែខ្ញុំសេពទូវប្រពន្ធ នៃបុគ្គលដទៃ ៗ ខ្ញុំស្លាប់ក្នុងអាយុ ៣០ ឆ្នាំ ហើយក៏បានមកកើតជាទារិកា ក្នុងត្រកូលនៃអ្នករទេះ ដែលជាត្រកូលកំព្រា គ្មានភោគសម្បត្តិ ត្រូវនាយឈ្មួញជាម្ចាស់ទ្រព្យរឹបជាន់ ៗ កាលការប្រាក់ចំរើនឡើងហើយ នាយឈ្មួញរទេះ ក៏អូសទាញខ្ញុំអំពីផ្ទះនៃត្រកូលដែលកំពុងយំខ្សឹកខ្សួល ៗ គ្រានោះ បុត្ររបស់ឈ្មួញរទេះ ឈ្មោះ គិរិទាសៈ បានឃើញខ្ញុំជាស្ត្រីនៅក្រមុំ មានវ័យចំរើន ក្នុងឆ្នាំជាគំរប់ ១៦ ក៏ហួងហែងរក្សាខ្ញុំទុកក្នុងផ្ទះរបស់ខ្លួន ៗ ប្រពន្ធធំរបស់គិរិ-ទាសៈ ជាស្ត្រីមានសីលផង មានគុណផង ជាស្ត្រីប្រព្រឹត្តតាមកស្ត ខ្ញុំក៏បានធ្វើការស្អប់ប្រពន្ធធំរបស់គាត់ ៗ ខ្ញុំលុះក្ស័យជាតិពីនោះមកបានមកកើតជាធីតានៃសាក្យត្រកូលនេះ ប្ដីទាំងឡាយលះលែងខ្ញុំ ដែលជាអ្នកខ្វះខ្វែនបំរើដូចទាសី ព្រោះផលនៃកម្មឯណា នេះជាផលកម្មរបស់ខ្ញុំនោះ ៗ ទីបំផុតនៃកម្មនោះឯង ខ្ញុំបានធ្វើហើយ ៗ

សូមបំព្រួញឲ្យរួញខ្លីនៃរឿងនេះ

ដើម្បីបេះកត់ចំណាំតាំងវែង

ទុកគ្រាន់ហាត់ពត់ចិត្តខ្លួនដោយខ្លួនឯង

ឲ្យវែងក្រែងអោពោសកាមេ ។

ឥសិតាសីកិក្ខុទ្រស្រស់ប្រសើរ

មុននឹងដើរចូលមកបួសផ្នួសទឹងគេ

នាងយកប្ដីដល់បីលើកជាហូរហែ

ប្ដីមួយៗនាងតែងតែគោរពជាប់ ។

ផ្គាប់ផ្គុនទាំងឪពុកម្ដាយញាតិខាងប្ដី

គ្មានខុសអ្វីពីច្បាប់ស្រីតាមទម្លាប់

តែស្វាមីទាំងបីប្រាណប្រែ.ប្អុះស្អាប់

គ្មានចិត្តរាប់ចង់មេត្រីស្នេហា ។

ប្ដីប្រែស្អប់ៗឃើញមុខមាត់ពុំបាន

លែងកល្យាណបោលឲ្យនៅម៉ាយកាយា

នេះគឺពៀរនៃអំពើលួចស្នេហា

លួចសម្ងួសស្រៃនៃកិរិយារបស់គេ ។

កាលដែលនាងកើតជាជាងមាសជាតិមុន
បានក្បាត់ស៊ិនប្រព្រឹត្តខុសក្នុងកាមេ
ពៀរនោះឯងតាមមកផ្តល់ឲ្យប្តីប្រែ
ស្អប់មាសស្នេហ៍លះលែងចោលគ្មានអាល័យ ។

ប្រុសលេងស្រីស្រីលេងប្រុសដោយផ្លូវកាម
បើដោយតាមទិដ្ឋនេះគួរភិតភ័យ
គួរលះចោលឈប់ប្រព្រឹត្តល្បែងចង្រៃ
ទើបធ្វើជាតិឲ្យប្រពៃបានសុខហើយ ។

---

ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

---

ឯជានប្រដាប់ សង់សឹងសម្រាប់ លៀនភ្លៀវកក្រា ប្រប ផេនបាយស ពណ៌សរបនា ធំខ្ពស់មហិមា ត្រដាបត្រដឹង ៗ មានល្វែងច្រើនជាន់ ពប់រយេកប់ពាន់ បណ្តោយទទឹង មានទីដំណេក តែងដេកតួនពឹង គ្រែតូកត្រដឹង សម្រាប់សព្វថ្ងៃ ៗ ទីលៀនបំណី រនាបថ្មថ្មី ថ្មកែវបវរណៃ ដើងតាំងសឹងថ្ម ខ្មៅសច្រើនក្រៃ កៅអី-ស្បែកស្បែ ពប់មុឺនពប់សែន ៗ មានការកាលណា លើកតាំងត្រៀបត្រា ពេញកឹងចុកណែន អ្នកម្នុខអ្នកការ នាំគ្នារៀបសែន អង្គុយលើទេន លើតាំងមិនអស់ ៗ អាងទឹកដាក់គ្រប់ ល្វែងកឹងសឹងអប់ ត្រដាក់មានរស មានមេកំណាន់ ប្រកាន់កឹងនោះ រក្សារៀបអស់ តុតាំងកៅអី ៗ ពោសប្រាសរនាប កន្ទេលដពប មិនឲ្យជាប់ដី គ្រឿងកែវតញ្ចក់ ស៊ើស្រក់ស្មើ តាំងទុកប្រក្រតី ក្អើងផ្ទែកពព្រាល ៗ គោមកែវថ្លាលា

បើយប់កាលណា អុជភ្លើងរន្ទាល រន្ទះទាំងពេង ពាព្រោងពព្រាល
ពព្រាតដូចកាល ថ្ងៃរះសន្ធៅ ៗ ភ្នាក់ផ្អើលចាត់ចែក ឲ្យត្រូវចំណែក
សង់ពេងចុងកៅ ធនធំក្រៃលែង ច្រើនល្វែងកប់ទៅ ប្រមាណជាត្រូវ
ដល់ពាន់គណនា ៗ ហោកទាំងបួន គន់គូរពល់ខ្លួន ផ្ទៀងដួងជាតា
ទិនកែវទិនក្បៀយ ជោគជ័យកជា សិទ្ធិជាគមហា សិរីវុឌ្ឍជ័យ ៗ
ហ្វូងឈៀងហ្វូងឈេរ បៀសទិនកាលមរណ៍ ចំនួលប្រពៃ បើកបាន
គ្រប់ពារ ពេលាល្អក្រៃ ទូលមកក្សត្រថ្ងៃ ប្រាប់គ្រប់ប្រការ ៗ
ត្រាស់ប្រើទូតទៅ នគរស្រុកក្រៅ រឹងក្សត្រា ឲ្យចូលមកធាប់
ប្រញាប់ម្ចាស់ ដ្បិតស្តេចមានការ មង្គលអភិសេក ៗ មន្ត្រី
ទេហ៍ពល កជទូតទៅដល់ ក្សត្រារយឯក បានស្តាប់ឱង្ការ
កជសារចាត់ចែក ក្សត្រារយឯក ចូលមកគ្រៀៈត្រា ៗ សឹងនាំស្មួយ
ថៃ ទ្រព្យល្អប្រពៃ ត្បូងកែវមុក្តា គ្រឿងទិព្វគ្រឿងទេស វិសេស
ជា ៗ ឡើងគាល់ក្សត្រា ក្រាបទូលថ្វាត់ថ្វាយ ៗ ព្រះបាទបពិត្រ
ធិកជរឿងរ័ទ្ធ យល់ស្តេចទាំងឡាយ ឡើងគាល់ក្សត្រក្សត្ត ហើយ
មានដង្វាយ ទ្រង់ត្រេកសប្បាយ សាកសួរមេត្រី ៗ បរមរាជា
ពេះពយឱង្ការ ត្រាស់ទ្រង់ថេតី រយឯកកជា ពណ៌នាសេចក្តី
សាទរមេត្រី តបព្រះឱង្ការ ៗ ហើយថាមកគង់ មកគាល់គ្រប់អង្គ

រៀបរៀងត្រៀបត្រា ដោយទីគ្នាគាប់ គំនាប់កជា ហើយក្រាបលុតពក
វិលមកឋានទី ៗ បរមក្សត្រា ត្រាស់ប្រើអាជ្ញា ទៅប្រាប់នាយពារ
ឈ្មោះឋានពិភក្តិ នូវក្រមន្ទីរ ភ្នាក់ងារទាំងពីរ ឲ្យរៀបដំណាក់ ៗ
សម្រាប់ក្សត្រា ទាំងយេឯកា យកគ្រឿងទៅដាក់ ឲ្យក្រាលបៀមចំ
ព្រែព្រំតាមស័ក្តិ ឲ្យគ្រប់ដំណាក់ រយឯកក្សត្រា ៗ ភ្នាក់ងារទាំងពីរ
តាក់តែងមន្ទីរ រៀបតាំងផ្កាលា គោមកែវអុជព្រាត ភ្ញីស្អាតមហិមា
កម្រាលល្អជា បៀមចំល្អពេក ៗ ប៉ាំងព្រះសុរិយា គ្រឿងគ្រប់ទុកជា
សម្រាប់អនេក អញ្ជើញស្តេចគង់ គ្រប់អង្គយេឯក គ្រឿងតាំងល្អពេក
ល្អពាមានខ្វះ ៗ រៀបរួចជម្រាប នាយធំបានក្រាប កិច្ចការដាក់ច្បាស់
ហើយឡើងជំនុំ ចតុស្តម្ភក្រែក្រាស់ សឹងគាល់អម្ចាស់ ឥស្សរសិរសា ៗ
ហើយវិលមកជុំ មកជួបជំនុំ នូវព្រះសាលា មានចតុស្តម្ភ ឡើងជំនុំការ
ស្តាប់អស់សេនា សម្រាប់ផែនដី ៗ ឯអស់សេនា បង្គាប់ភ្នាក់ងារ
សព្វមុខមន្ត្រី ឲ្យធ្វើសំបុត្រ កំណត់សេចក្តី គ្រប់ឯកទោត្រី ចត្វា
ហើយបោះ ៗ ត្រាប្រើប្រាប់ទៅ ហៅហ្វាយស្រុកក្រៅ ឲ្យមកទាំងអស់
បំរើស្តាប់ច្បាស់ សំពះលាស្មោះ ដើរត្រួតប្រាប់អស់ សព្វមុខមន្ត្រី ៗ
ទទួលប្រសាសន៍ សម្រេចឲ្យច្បាស់ កិច្ចការផែនដី រៀបតែងចុតហ្មាយ
សព្វសាយសេចក្តី គ្រប់ឯកទោត្រី ចត្វាបោះត្រា ៗ បាត់ប្រើបំរើ

ឲ្យប្រាប់ទៅលើ ខេត្តក្រៅនាមា ឲ្យចូលមកឆាប់ ប្រញាប់ម៉្មា បំរើ
នាំសារ ចុតហ្មាយទៅដល់ ៗ ចៅហ្វាយស្រុកក្រៅ គ្រប់ខេត្តរួសរាំ
រៀបខ្ទង់របស់ រិះរកដង្វាយ តាំងឡាយក័ស្តុផល ចរចូលមកដល់
ជួបជុំគ្រៀបគ្រា ៗ រៀបអស់ដង្វាយ ស្វាខ្ទីតាំងឡាយ ក្រូបមៀនផលា
មានបេកពង់មាន ទុំនាន់វេលា ដំឡូងដូងស្វា គ្រឡាបល្ពៅ ៗ
លុតត្នោតខ្នុរស្វាយ កែវសែងលំស្គាយ ដើរហែរតាមទៅ ដល់នាហ្មឺនធំ
ជួបជំនុំទៅ នាំឡើងគាល់ហ្វៅ ស្តាប់ព្រះឧង្ការ ៗ ទូលថ្វាយដង្វាយ
ចៅហ្វាៈស្រុកឆ្ងាយ ថ្វាយក័ស្តុផលា ទ្រង់ប្រោបជាក់ច្បាស់ មានព្រះ
ឧង្ការ ចៅហ្វាយកល់គ្នា សង់រោងដាក់ទស ៗ ចៅហ្វាយគ្រាមា
ទទួលឧង្ការ បង្គំលាចុះ មកសង់រោងខោល តាំនោលច្រើនប្រុះ ខ្វះត្រូវ
នាំទុស នាំឲ្យដល់ទៅ ៗ ប្រគល់សួស្តី ចៅហ្វាយបញ្ជី បើកឲ្យចូងកៅ
បើខ្វះទុសនោះ វាស្មុះក្រឡៅ ក្រឡើតតទៅ តាមកោះយកកាសៗខ្វះសែង
ទឹកទៅ ចាក់ពយដោយផ្លូវ មកវាំងពេញពាស កុំឲ្យធុលី ហុយទីតាំងផ្តាស
ខ្វះកាន់ប្រាសព្រាស សំពមបោលទៅ ៗ ខ្វះចូកដំរេះ ប្រាសជាត់ឲ្យជ្រះ
ទីខ្ពស់ទីទាប ប្រាបពបធេងទៅ មិនឲ្យមានស្មៅ ផុះដកកាប់កាត់ ៗ ហេតុ
ស្តេចឯកពជ រឹទ្ធិអំណាច បារមីច្រើនក្តាត់ មែនមានពាណិជ តែងត្រាប់
ប្រវាត់ ចូលជួញច្រើនក្តាត់ កង់ក្រុងភាព ៗ សំពៅប្រាំរយ ចូលចតរដយ

ពាសពេញត្រៀបត្រា សឹងទ្រព្យថ្លៃៗ ក្រៃក្រគណនា ត្បូងកែវមុក្តា មកុដទិព្វរ័ត្ន ៗ កាសាយមនា ទៀនព្រៃជាៗ ទឹមទាបអាត់ឡាត់ កុង ខ្លួនកាំម៉ី ស្បែងប្រវាត់ កាមវ័ន្ទច្រើនគ្នាត់ សាក្លាតជាតិ ៗ ជាមួយទទឹម សឹងទៀនសង់ទឹម មួកតាតស្មើ សត្វវិចរបោប ចំណាប់ឥតបី យ៉ាង ល្អថ្មីៗ ស្រស់ស្រៀបត្រឹមត្រូវ ៗ មានព្រៃចំឡែក ជាឱបទេសឯក ទេសល្បើកផ្កាថ្កូវ គ្រឿងមាសគ្រឿងប្រាក់ រើដាក់ត្រឹមត្រូវ រលែកនាំ ទៅ សែងឡើងដាក់ផ្សារ ៗ ជះផ្ទៀងធំនោះ ដីងដាក់ចំពោះ ជាមហា ក្បត្រា ស្តេចរៀបអភិសេក អគ្គឯកផាយា គិតគ្នាមិម្មា ឡើងគាល់ក្បត្រ ក្បត្តិ ៗ យកអស់ទ្រព្យជា កាសាយមនា ត្បូងកែវសុរិកាន្ត ដាក់ គុតាំងតែង ឲ្យសែងតាមប្រាណ ខ្លះរើកបាន ក្រឡៃទឹកមាស ៗ ខ្លះយកគ្រឿងតាំង គ្រឿងកុសំពង់ សម្រេចពេញពាស ខ្លះបានផ្កា ប្រាក់ ថ្កល់ដាក់តុមាស ខ្លះយកផ្កាមាស តុប្រាក់ថ្វាយទៅ ៗ ខ្លះសែង ស្ករស ថ្នាំចិនយ៉ាងល្អ កញ្ចប់ហោប៉ៅ ប្រកបាវឲ្យសែង ច្រើនស្នែង នាំទៅ ឯខ្លួនជះផ្ទៀង បង់បោយដើមុខ ៗ ជះផ្ទៀងគេត្រា នោះច្រើនកាសា យ្លួនផ្កាច្រើនស្រុក បាកំងចិនចាម ក្តិព្រាហ្មណ៍គ្រប់មុខ ចូលមក ពីស្រុក មានីលកូឡា ៗ ភូមាសៀមលាវ អង់គ្លេសភ្ជង់ក្រៅ ច្រើនក្រៃត្រៀបត្រា បណ្តើរគ្នាដល់ មណ្ឌលសីមា រៀនហ្វូងយាត្រា

នាំទៀនគាល់ក្បែរ ៗ ទូលថ្វាយដង្វាយ ដណ្ដៅថ្វាយ ៗ ចូលមកប្រគាត់
ស្ដេចប្រោបប្រទានអរ សាទរពេកក្លាត់ បន្ទូលទៅថ្វាត់ ដោយក្ដីករុណា ៗ
ដណ្ដៅតាំងឡាយ យល់ស្ដេចសប្បាយ ពេះពាយទុក្ខារ មានចិត្តត្រេកអរ
សាទរពល់គ្នា បង្គំក្រាបលា វិលចុះសំពៅ ៗ ឯអគ្គព្រះបាទ វិមលនរនាថ
ធិពជបម្ភៈចៅ មានព្រះទុក្ខារ វាចាក្រឡ ត្រាស់បង្គាប់ទៅ ឯកអគ្គមន្ត្រី ៗ
ឲ្យត្រួតភ្នាក់ងារ នាយពួកក្រយា ឲ្យរៀបចំណី ភស្តុភោជនា ខុជាតីសី
ពិសេសចំណី ថ្វាយក្សត្ររយឯក ៗ ហើយរៀបសម្រាប់ រយឯកផ្គូផ្គាប់
ចំណីចំឡែក រៀបផ្គង់ពាណិជ សម្រេចឲ្យចែក ភោគ្គាចំឡែក ហើយ
សាលទ៍ភាសា ៗ ដណ្ដៅបាពាំង បាពាំងរៀបតាំង លៀងជប់អាហារ ដណ្ដៅ
សៀមសុទ្ធ សៀមផ្គត់គេក្បា ដណ្ដៅកូឡា កូឡាផ្គត់ផ្គង់ ៗ ដណ្ដៅភូមា ភូមា
គេក្បា ជប់លៀងបម្រុង ដណ្ដៅឃ្មួនត្រូវ ចុងភៅឃ្មួនផ្គង់ ដណ្ដៅចិនចុង ភៅ
ចិនបម្រើ ៗ ដណ្ដៅចាមជ្វា ចាមជ្វាគេក្បា ភោជន៍ភស្តុសារពើ ដណ្ដៅជប៉ុន
ជប៉ុនបម្រើ ដណ្ដៅព្រាហ្មណ៍លើ ចុងភៅព្រាហ្មណ៍ផង ៗ ដណ្ដៅលន្ទា
អង់គ្លេសមនជ្វា និត្យនៅត្រូវចុង- ភៅតាមភាសា គេក្បាបម្រុង ដណ្ដៅកូង
ចុង- ភៅកូងលៀងជប់ ៗ ស្ដេចបើកប្រដាប់ ប្រាក់ព្រះរាជទ្រព្យ ប្រទាន
ឲ្យគ្រប់ ចុងភៅភាសា គេក្បាលៀងជប់ មិនឲ្យថុញថប់ សព្វថ្ងៃប្រក្រតី ៗ
ដ្បិតស្ដេចមានការ ជ័យដោគអាពាហ៍ ពិពាហ៍សួស្ដី មង្គលអភិសេក

អគ្គឯកទេសី រៀបលៀនចំណី ពាណិជស្រុកឆ្ងាយ ៗ ដោយ
សាសន៍ភាសា ចំណីគោក្ដា តាមចិត្តសប្បាយ តាំងពេងចុងគោ
ឯក្រៅទូលាយ ទំហំចំងាយ ពប់សែនគណនា ៗ ឯកអគ្គមន្ត្រី សម្រាប់
ផែនដី ទទួលទុក្ខារ គ្រាស់ទ្រង់បង្គាប់ ប្រញាប់ម៉ឺនមា បង្គំក្រាបលា
ពោះថយតាកទី ៗ ចុះដើរដល់ដុំ សាលាជំនុំ សព្វមុខមន្ត្រី ឡើងជំនុំការ
គៀបត្រាប្រក្រតី ទើបមុខមន្ត្រី ត្រួតគ្រប់ភ្នាក់ងារ ៗ ឯនាយព្រះក្រាល
ឲ្យរៀបកំពល ចៀមចំសយនា នាយពួកពិសេស គ្រឿងទេសក្រយា
នាយវេនក្រឡា មន្ទីរក្រុមវាំង ៗ គ្រប់នាយបានស្ដាប់ ទទួលបង្គាប់
រសរត់គ្គុងក្តាំង ខ្ទះសៀមចិនជ្វា កូឡាបារាំង គ្រប់សាសន៍រៀបតាំង
ចូលជំធ្វើការ ៗ នាយពួកពិសេស រៀបសំងគ្រឿងទេស គ្រឿងទិព្វ
ក្រយា ឡោតាចុងគោ គោឡៅយ៉ាំងជា រៀៗមីរៀបឆា រៀបហុង
សាច់ជ្រូក ៗ ទឹមមាន់ទឹមទា ខ្វះបកបង្គា ខ្វះឆាកគ្រាប់ឈូក អ្នកខ្វះ
ប្រញាប់ ខ្វះកាប់ដើងជ្រូក ខទឹងគ្រាប់ឈូក ឆ្អឹងលើកទុកទៅ ៗ ខ្វះពុះ
ត្រឡាច ចិតបេញសស្វាច ខ្វះពុះល្ពៅ ខ្វះពុះដំឡូង ដូងរូងល្ហុកឡៅ
ផៃប៉ូវមើមត្រាវ ព្រះពាយសណ្ដែក ៗ នាំគ្នាដើរហែ ទៅទិញបន្លែ
ពីផ្សារថ្មែក ១ មេស្ករតាំហ៊ុន ផ្កាចន្ទផ្កាចេក ពពុះសណ្ដែក តៅហ៊ូ
តាំងឆាយ ៗ ទិញឈើងសមុទ្រ ឈាមមោសសុទ្ធ អណ្ដើកកន្ធាយ

ស៊ុតមាន់ស៊ុតទា បង្គាក្រានលាយ សែនវែកប្រញាយ ប្រញាប់ពន់ពេក ៗ ដល់ពេលរៀបដាក់ ស្រាយបាវចូកចាក់ ចេញហើយចាត់ចែក រៀបតុដើរក្រាន គ្រប់ប្រាណចំឡែក ចំណាំនាយផ្នែក ដោយមុខដោយខ្លួន ៗ រៀបស្លដណ្ដាំ ដោយពួកចំណាំ ចំណាប់មាំមួន ថ្ងៃយប់ប្រុងប្រាណ មិនហ៊ានដកពួន ដោយពួកដោយខ្លួន គ្រប់សាសន៍ភាសា ៗ ចុងភៅខ្មែររៀប ចំណីស្រស់ស្រៀប ខ្លះខ្ញាំភ្លា សំឡប្រហើរ ខ្លះធ្វើកប់សា ចៀនអាំងឆ្អួរឆា ហើយធ្វើសាម៉ុក ៗ អាំងសាចខ្លះធ្វើ ឡប្រហៀមទុកធ្វើ ស្ងាគ្រុក ខ្លះធ្វើនំបុក ចំឡែកដោយមុខ ធ្វើខ្យងសំរុក នំបង់ខ្ញាញ់ផង ៗ ខ្លះធ្វើអន្សម ស្ងនងផ្លែល្ហុង ខ្លះខ្លួបង្កង ខ្លះញាំពស់ប្រា ខ្លះភ្លាអង្ក្រង លួកក្ដក្រមួង ៗ ក្រែងសាចប្រែពេក ៗ ខ្លះហាន់សាចជ្រូក ស្លក្តខ្ទឹមបង់ផ្លូក ជួរប្រេះចម្លែក ស្លដំឡូងត្រាវ ល្ពៅសណ្ដែក ស្ពៃដាយចំណែក គ្រប់មុខបន្ទែ ៗ ខ្លះចិត្តផ្លែម្រះហាន់សាចដាក់ខ្លះ គ្រលែងឆ្អប់ឆ្អួ លីងគ្រាប់សណ្ដែក បុកបែកម៉ត់ប៉ីបង់ពៅ ហើយថៃ បន្ទយភ្លើងចេញ ៗ ស្លអង្ករលីង គ្រកាលសាចផ្សេងក្លិនឈ្ងប់ឈ្ងុយឆ្ងាញ់ ខ្លះដស់ស៊ុតទា ដាក់ធាទឹងខ្ញាញ់ ឆ្អិនស្របដាក់ចេញ ឈ្ងុយឈ្ងប់ពីសា ៗ

(នៅមានត)

# រឿងព្រេងប្រទេសស៊ុយអែដ

## បែងអំពី អំបិល និង នំប៉ុង

ភិក្ខុ ម៉ែន-វៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែចាកភាសាអង់គ្លេស

---

សម័យមួយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់មានព្រះរាជ-ធីតា ៣ ព្រះអង្គ ៗ បណ្ដាព្រះរាជធីតាទាំងនោះ ព្រះរាជធីតាពៅ បានជាទីស្រឡាញ់ពេញព្រះរាជហឫទ័យយ៉ាងខ្លាំង នៃព្រះមហាក្សត្រជាព្រះបិតា ជាងព្រះរាជបុត្រីច្បងទាំងពីរ ៗ ម្ល៉ោះហើយព្រះរាជបុត្រីច្បងទាំងពីរនោះ ក៏កើតសេចក្ដីប្រណែន នឹងប្អូនពៅខ្លួន, បានចំណាយពេលជាច្រើន នឹងសេចក្ដីព្យាយាមដ៏មាំ ដើម្បីនឹងបំផ្លាញនូវសេចក្ដីស្នេហា រវាងព្រះមហាក្សត្រ នឹងប្អូនពៅនោះឲ្យវិនាសបាត់ទៅ ៗ ព្រះនាងទាំងពីរ ខំព្យាយាមដើម្បីទាញយកនូវសេចក្ដីស្នេហា នឹងឋានៈនេះឲ្យបានមកខ្លួនវិញ, មិនគេចសោះ នូវឱកាសដើម្បីណែនាំព្រះមហាក្សត្រជាព្រះបិតាខ្លួនឲ្យឃ្លាតព្រះទ័យពីព្រះនាងពៅ ដោយបង្កាច់

ថា " នាងនៅឥតស្រឡាញ់ព្រះមហាក្សត្រ ដូចដែលទ្រង់ស្រឡាញ់នាងនោះទេ " ។ ការប្រណៃនដំណាមករបស់ព្រះនាងទាំងពីរ មិនអនុញ្ញាតឲ្យព្រះនាងសម្រាកសោះ ។ ទីបំផុតព្រះមហាក្សត្រកាលទ្រង់ឮពាក្យមួលបង្កាច់នោះពីព្រះរាជបុត្រីច្បងទាំងពីរ ទ្រង់ក៏ខ្វល់ព្រះរាជហឫទ័យជាខ្លាំង ៗ

ថ្ងៃមួយ កាលដែលព្រះរាជបុត្រីទាំងអស់ បានមកជួបជុំគ្នាទៅចំពោះព្រះភក្ត្រព្រះអង្គ ទ្រង់ក៏ពិសោធមើលទំហំសេចក្ដីស្នេហានៃព្រះរាជធីតាទាំងនោះផ្ទាល់ព្រះអង្គ ។

ដំបូង ទ្រង់ចាប់សួរអំពីទំហំសេចក្ដីស្នេហារបស់ព្រះរាជបុត្រីច្បងចំពោះព្រះអង្គ តើខ្លាំង - ធំ - ថ្លៃ យ៉ាងណា ។ ព្រះនាងឆ្លើយថា៖

– « បពិត្រព្រះបិតា, ខ្ញុំម្ចាស់សូមថ្វាយតម្លៃព្រះបិតា ដូចតម្លៃទេពតានៅឋានសួគ៌" ។

ចម្លើយនេះ បានញុំាងព្រះមហាក្សត្រឲ្យទ្រង់សប្បាយព្រះទ័យជាខ្លាំង ។ រួចទ្រង់សួរទៅព្រះរាជបុត្រីបន្ទាប់ ដូចមុនទៀត ព្រះនាងឆ្លើយថា៖

– " បពិត្រព្រះបិតា, ខ្ញុំម្ចាស់ សូមថ្វាយតម្លៃព្រះបិតា ស្មើនឹងតម្លៃជីវិតរបស់ខ្ញុំម្ចាស់ ! » ។

ចម្លើយនេះ ក៏ធ្វើព្រះមហាក្សត្រឲ្យសោមនស្សដែរ ។

បន្ទាប់ពីនេះ ទ្រង់បែរទៅសួរព្រះរាជបុត្រីពៅថា "តើនាងឲ្យតម្លៃបិតាដូចម្ដេចដែរ ?" ។ ព្រះនាងឆ្លើយថា ៖

- "ឱព្រះបិតា, ខ្ញុំម្ចាស់សូមថ្វាយតម្លៃព្រះអង្គស្មើនឹងតម្លៃនៃទំងន់នឹងអំបិល !" ។

ចម្លើយនេះ បណ្ដាលឲ្យមហាក្សត្រ រំភើប ភ្ញាក់ យ៉ាងពន្លឹក ។ ពេលនោះ ទ្រង់ខ្ញាល់នឹងព្រះរាជបុត្រីពៅក្រៃពេក ដោយទ្រង់យល់ថា "នាងគ្មានគាំពារព្រះកិត្តិយសព្រះអង្គ ឲ្យបានលើសពីវត្ថុគម្រក់បំផុត ដែលគេតែងតែគិតលើតុបុរសទុគ៌តនោះសោះឡើយ" ។ ព្រះពិរោធរបស់ទ្រង់ ដូចព្យុះសង្ឃរា ដោយហេតុទ្រង់ស្ដាយចំពោះសេចក្ដីស្នេហាដ៏សម្បើមរបស់ទ្រង់ ដែលបង់ខាតដោយខ្ជះខ្ជាយទៅលើព្រះរាជបុត្រីពៅ ហើយទ្រង់បានទទួលនូវសេចក្ដីស្នេហាតបដ៏តិចបំផុត ដូច្នេះវិញ ។ ទ្រង់ព្រះរាជបញ្ជាឲ្យពួកទាសកម្មករ បណ្ដេញព្រះនាងពៅចេញពីព្រះដំណាក់របស់ទ្រង់ ។ ពួកទាសាទាសីក៏បានធ្វើតាមព្រះរាជបញ្ជា ដោយនាំព្រះនាងទៅបំបរបង់ចោលក្នុងព្រៃ ។

គ្រានោះ ព្រះរាជបុត្រីច្បងទាំងពីរសប្បាយព្រះទ័យណាស់ព្រោះសម្រេចតាមគោលបំណងរបស់ទ្រង់ ។

នៅក្នុងព្រៃ, ព្រះរាជបុត្រីពៅ ប្រកបដោយសេចក្ដីតោកយ៉ាកនឹងការភិតភ័យយ៉ាងក្រៃលែង ។ កាលណាព្រះនាងនឹកអំពីដំណាក់

ដែលធ្លាប់គង់ អំពីព្រះរាជបិតាដ៏ជាទីស្នេហារបស់ទ្រង់, សម្ដេចយំខ្សឹកខ្សួលក៏កើតមានឡើង ។ ព្រះនាងមិនបានដឹងសោះថា តើព្រោះហេតុអ្វីបានជាព្រះបិតាខ្ញាល់នឹងព្រះនាង? ហើយព្រោះហេតុអ្វីបានជាខ្លួនព្រះនាងត្រូវគេបំបរបង់ចោល? ។ ពេលនោះ ព្រះនាងដើរត្រាច់ទៅក្នុងព្រៃតែមួយព្រះអង្គ ឥតមានទីពឹង ហើយទីបំផុត ដោយខ្លាចសត្វព្រៃបៀតបៀន ព្រះនាងក៏ឡើងទៅពួនលើដើមឈើខ្ពស់មួយ ។

ក្សណៈនោះ មានព្រះមហាក្សត្រមួយព្រះអង្គនៃប្រទេសដទៃទៀតទ្រង់ចេញបរបាញ់សត្វក្នុងព្រៃ ។ កាលទ្រង់គង់សេះ បរតាមព្រៃនោះហូរហែរមក ទ្រង់បានឮសំឡេងឆ្កែរបស់ព្រះអង្គ ព្រុះកោះឡើង ដោយអាការក្រោកផ្អើល ។ ទ្រង់បរសេះយ៉ាងរួសរាន់ ឆ្ពោះទៅតាមសម្លេងឆ្កែស្រាប់តែឃើញពួកឆ្កែនោះ នៅចោមព័ទ្ធជុំវិញដើមឈើ ដែលព្រះរាជបុត្រីលាក់ព្រះអង្គ ។ ដោយសង្ស័យថា នឹងបានឃើញខ្លាឃ្មុំ ទ្រង់ក៏ងើបព្រះភក្ត្រទៅលើ ។ តែជំនួសខ្លាឃ្មុំ, ទ្រង់បានយល់នូវផ្ទៃព័ក្ត្រដ៏ឆើតឆាយនៃស្ត្រីក្មេង ដែលមានអាការប្រកបដោយទុក្ខព្រួយទៅវិញ ។ ពេលនោះព្រះអង្គបានពោលទៅកាន់ព្រះនាងដោយសុភាព សុំឲ្យព្រះនាងចុះមកក្រោម ។ លុះព្រះនាងចុះមក ព្រះអង្គបានលើកព្រះនាងដាក់លើខ្នងសេះបញ្ឆះយកទៅកាន់ប្រាសាទព្រះអង្គ ។ នៅក្នុង

ប្រាសាទ, ទ្រង់ឲ្យព្រះនាងសោយអាហារ, ធ្វើឲ្យព្រះនាងកក់ក្ដៅបាត់រងាដោយភ្លើងសម្រាប់អាំង ៗ ទីបំផុត ដោយអំពើសប្បុរសរបស់ព្រះមហាក្សត្រអង្គនោះ គ្របមកលើព្រះនាង, ព្រះនាងក៏បញ្ចេញរឿងទ្រង់ទូលព្រះមហាក្សត្រជ្រាបសព្វគ្រប់ ៗ

អំពើដ៏ល្អ និងលំអដ៏ឆើតឆាយរបស់ព្រះនាងធ្វើឲ្យព្រះមហាក្សត្ររំភើបព្រះទ័យយ៉ាងក្រៃលែង ៗ ទ្រង់ថែរក្សាព្រះនាងទុកក្នុងប្រាសាទ, ហើយក្រោយមក ទ្រង់សុំឲ្យព្រះនាងរៀបអភិសេកសមរសជាមួយព្រះអង្គ ៗ

ព្រះរាជធីតាក្មេងនេះ ដោយធ្លាក់ចុះក្នុងសេចក្ដីស្នេហាដែរនោះ ក៏ទ្រង់ទទួលព្រមរៀបអភិសេកជាមួយទ្រង់ ៗ

ដូច្នេះហើយ, កាលបរិច្ឆេទនៃព្រះរាជពិធីមង្គលាភិសេក ក៏ត្រូវបានគេកំណត់ទុកជាស្រេច, សំបុត្រអញ្ជើញភ្ញៀវ ក៏ត្រូវគេចាត់ការផ្ញើទៅក្រុមព្រះរាជវង្សានុវង្ស នៃព្រះរាជអាណាចក្រជិតខាង ចំនួនប្រាំពីរអាណាចក្រ ៗ

កាលថ្ងៃនៃមង្គលាភិសេកមកដល់ ភ្ញៀវជាព្រះរាជវង្ស ក៏បានមកដល់ត្រៀបត្រា ៗ ក្នុងចំណោមភ្ញៀវទាំងនោះ ព្រះមហាក្សត្រជាព្រះបិតានៃព្រះនាងសាម័ខ្ទុនក្នុងអាក់ហារិកហាមគ្គល និងព្រះរាជបុត្រីច្បងទាំងពីរនៃទ្រង់ ក៏ទ្រង់យាងមកជាភ្ញៀវជាន់ខ្ពស់មួយដែរ ៗ ទាំង៣អង្គនេះ

ឥតមានអន្តណាទីករឃើញចំពោះព្រះនាងសាម៉ីខ្លួនឡើយ, ព្រោះទ្រង់ជឿជាក់ថា ព្រះរាជបុត្រីពៅអង្គនោះ វិនាសបាត់បង់ព្រះជន្មគង់ព្រៃទៅហើយ ។

ពេលដែលភ្ញៀវអង្គុយរៀបរយ នៅនាតុជប់លៀងភោជនាហាររួចរាល់អស់ហើយ, ម្ហូបដ៏ល្អគ្រប់បែប បានត្រូវគេលើកដាក់លើតុមុខភ្ញៀវទាំងនោះ ។ ចំពោះភោជនាហារទាំងនោះ គ្មានម្ហូបណាមួយប្រៃសោះ គឺសុទ្ធតែសាប ៗ ទាំងអស់ ហើយថែមទាំងគ្មានដាក់អំបិលប្រចាំការទៀតផង, នំប័ងក៏គ្មានដែរ ។

ព្រះមហាក្សត្រជាព្រះបិតាព្រះនាងពៅ ដោយទ្រង់មិនអាចទប់ព្រះទ័យគង់ការសួរគេ ក៏ទ្រង់បន្ទូលថា៖

–« យីអើហ្ន៎ ! ខ្ញុំមិនយល់សោះ ម្ដេចបានជាគេភ្លេចដាក់វត្ថុដ៏ប្រណីតបំផុតពីមុខ គង់ពិធីជប់លៀងនេះហ្ន៎ ? » ។

ព្រះនាងពៅ ដែលពេលនោះ ជាតួព្រះខត្តិយានី ឆ្លើយថា ៖

" ទ ! ព្រះអង្គត្រូវការអ្វី ? „ ។

–«អាសិខាន់ពីមុខ គឺអំបិលនឹងនំប័ងណា!» ព្រះមហាក្សត្រឆ្លើយ

–"ពិតហើយក្រាបទូល» ; ព្រះនាងបន្ថែម, "អំបិលនឹងនំប័ងហ្នឹងឯងហើយ ដែលយើងស្គាល់ថា ជាវត្ថុដ៏ប្រណីតថ្លៃបំផុត, តែប៉ុន្តែ នៅ

គ្រាមួយនោះ ដោយសារតែខ្ញុំថ្វាយតម្លៃយ៉ាងថ្លៃ ទៅព្រះបិតាខ្ញុំស្មើនឹងវត្ថុទាំងនេះ ខ្លួនខ្ញុំក៏ត្រូវលោកបណ្ដេញចេញពីព្រះដំណាក់ឲ្យទៅនៅក្នុងព្រៃ ដើម្បីសម្លាប់ខ្លួនខ្ញុំទៅវិញ» ។

ទ្រង់ឮពាក្យនេះ ព្រះមហាក្សត្រក៏ស្ងៀមមួយសន្ទុះ រួចដល់ព្រះអង្គស្គាល់ព្រះនាងច្បាស់ ក៏ទ្រង់ស្ទុះទៅឱបព្រះនាងដោយសម្រែកពេញទៅដោយសេចក្ដីសប្បាយរីករាយព្រះទ័យជាអនេក ព្រោះទ្រង់ទើបនឹងបានជ្រាបថា ព្រះនាងមានព្រះជន្មរស់នៅឡើយ ។ ពេលនោះ ព្រះអង្គសុំឲ្យព្រះនាងអភ័យទោស ចំពោះការណ៍ដែលទ្រង់មិនយល់នូវពាក្យពេញទៅដោយសេចក្ដីស្នេហារបស់ព្រះនាងចំពោះព្រះអង្គ នឹងនូវការបណ្ដេញព្រះនាងចេញពីព្រះដំណាក់របស់ព្រះអង្គ ។

អំពើអាក្រក់នៃព្រះរាជបុត្រីច្បងទាំងពីរដែលរួមគំនិតប្រឆាំងនឹងព្រះរាជបុត្រីពៅនោះក៏ត្រូវទទួលលទ្ធផលអាក្រក់យ៉ាងសម្បើម ។ វេនដែលត្រូវឃ្លាតចេញចាកព្រះដំណាក់នៃព្រះបិតាខ្លួន ក៏វិលមកដល់នាងទាំងពីរវិញ ។ ម្យ៉ាងទៀត តាំងពីថ្ងៃនោះមក ដំណឹងអ្វី សូម្បីតែបន្តិចបន្តួចពីនាងទាំងពីរ ក៏លែងលេចឮសោះ ។ ទុកជានាងត្រូវស្ដេចបរបាញ់ណាមួយ ជួយសង្គ្រោះឲ្យរស់ពានមានជីវិតក្ដី ក៏គ្មានអ្នកណាមួយបានដឹងបានឮឬបានឃើញសោះឡើយ ។

ស្នាដៃឪពុក

# ចែងអំពីរបៀបប្រដៅកូនប្រុសស្រី

លោក ស៊ុន-ជូ រៀបរៀង

លោក ចាប-ពិន ពិនិត្យ

---

## ជំពូក ១

### ដំបូន្មានកូនប្រុស ១

បទពាក្យ ៧

ហៃកូនពន្លកមាសឪពុក   ចូរថាចាំទុកគ្រប់រូបកាយ
នូវពាក្យឪពុកដែលអធិប្បាយ   តាមពុទ្ធបរិយាយត្រាស់ទេសនា ។

ទី ១. សមាននាយ:   ចូរចាំឲ្យជាក់តាមតម្រា
ពីក្មេងអ្នកនៅនឹងមាតា   តាមតែចិត្តបាត្រអាលលេង ។
ឥឡូវខ្លួនអ្នកមានប្រពន្ធ   រៀនចិត្តឲ្យធ្ងន់ជាងពីក្មេង
លើកមុខប្រពន្ធឲ្យចំពែង   គឺតែក្រែងអាណិតចិត្តភរិយា ។
កុំអាងតែខ្លួនឯងជាប្រុស   គួរដឹងត្រូវខុសផងនានា
ត្រូវសួរពីគ្រោះដល់ភរិយា   គិតគ្នាធ្វើការផងទាំងឡាយ ។

ទី ២· អរិមាននាយ: ក្បួនតាំងឲ្យជាក់ពាក្យអធិប្បាយ
ទោះបីកិរិយាឆ្គងនាយអាយ កុំបីមើលងាយជេរផ្តាសា ៗ
ត្រូវប្រៀនប្រដៅដោយស្មោះសរ ប្រកបដោយធម៌ព្រះទេសនា
កុំធ្វើវិស័យក្មេងពាលា អាងជេរកិរិយាគ្រប់តែថ្នាក់ ៗ

ទី ៣· បាលីព្រះថែងថា អនតិចារិយាយ:
ធម៌នេះលោកប្រាប់ស្តាប់ឲ្យជាក់ កុំឲ្យចិត្តស្ម័គ្រប្រាថ្នាស្ងន់ ៗ
ទីងកូនប្រពន្ធអ្នកដទៃ កុំបីរំពៃគិតកប់កាន់
ចោលប្រពន្ធឯងឲ្យអាក់អន់ ទោសនេះទាន់ហាន់ឃើញហើយតើ ៗ

ទី ៤- ឥស្សរវោសគេន: ប្រគល់ទុកដាក់ខ្ញុំសារពើ
កិច្ចការក្នុងផ្ទះសព្វអន្ទើ ដាច់មុខទៅលើខាងភរិយា ៗ
មុខងារដាំស្លអង្ករបាយ ចំណូលចំណាយខាងភោជនា
ប្រគល់ការផ្ទះគ្រប់វេលា ទៅឲ្យភរិយាជាមេទ្រព្យ ៗ

ទី ៥- ពោលគឺអលង្កា- ទានុប្បទានេន: គាប់
ឲ្យគ្រឿងស្លៀកពាក់គ្រប់ប្រដាប់ ល្អៗចំណាប់ហើយថ្មីៗ ៗ
ចិញ្ចៀនកាវែងក្លងស្នៀតសក់ ទាំងក្រាសកញ្ចក់ប្រេងកាណី
ម្សៅទឹកអប់ក្លិនក្អូបពិសី គ្រឿងស្រីឲ្យស្រស់បស់ល្អៗ ៗ
ទំហូត្បូងពេជ្រលេចសមសួន ខ្សែដៃខ្សែខ្លួនកន្ទាស់ក

អាវខ្លីអាវវែងតែងលំអ　　លាតឡេវឡាញ់សជង្ករបី ៗ
រៀបចំឲ្យសមចិត្តភរិយា　　ទៅទិសនានាពេញមុខស្រី
កើតកេរ្តិ៍ពីពេះខ្ពស់មុខប្តី　　នៅនាលោកិយល្បីសុះសាយ ៗ
　　វិសង្គហធម៌ទាំង៥នេះ　　ចូរបាចាំបេះគ្រប់រូបកាយ
បេះហើយត្រូវកាន់គ្រប់គម្រាយ　　ប្រយ័ត្នឃ្លាតខ្លាយជាតិកំណើត ៗ
បំណាច់សំណាងបានជាមនុស្ស　　ពោះស្រីពោះប្រុសសឹងក្រកើត
ត្រូវកាន់ចិត្តធម៌ឲ្យល្អឆើត　　កសាងកំណើតឲ្យថ្កើងថ្កាន ៗ
　　សន្ទើបបែបបទគត់សញ្ញា　　បិតាវែងទុកតាមលំអាន
ឲ្យកូនប្រុសៗខំរះធ្យាន　　ប្រតិបត្តិតាមស្ថានទីងបានសុខ ៗ
ថ្កើងពូជថ្កើងពង្សឲ្យស្រស្តាន　　សាបញាតិប៉ុន្មាននៅក្នុងស្រុក
នៅនាលោកិយឥតកលិយុគ　　អនាគតមុខក៏សុខហោង ៗ

## បំពូក២

### ដំបូន្មានកូនស្រីៗ

បទពាក្យ ៧

　　ហៃអស់ពួកនាងកូនស្រីៗ　　ចូរនាងឃ្នាតខ្ចីកុំប្រមាទ
កិច្ចការក្នុងផ្ទះត្រូវឲ្យស្អាត　　សង្វាតគ្រប់គ្រងណាកូនស្រី ៗ

ឪពុកតាវែងថ្លែងអធិប្បាយ	បរិយាយតាមបែបបទបាលី
ឲ្យជំបូន្មានដល់កូនស្រី	សង្ខេបបែបវិធីយ៉ាងនេះឯង ៗ
១ សុសំវិហិតកម្មន្តា	ប្រែថាស្រីចេះការចាត់ចែង
រៀបចំកិច្ចការផ្ទះសម្បែង	ទុកដាក់គ្រឿងល្វែងជាខាងក្នុង ៗ
ជើងក្រានចានឆ្នាំងពាងក្រឡ	គន្លក់អង្ករបាវការុង
អំបិលប្រហុកដាក់ពាងអុង	បំរុងទៅមុខទុកមានខាត ៗ
ខាងក្រៅរៀបចំឲ្យសមស័ក្តិ	តែងក្បាច់ដាក់ក្បែរគ្រែសំអាត
កន្ទេលចៀមចំព្រំសក្លាត	បោសប្រាសសំអាតកល់ពត្រី ៗ
ខោអាវសំពត់បត់ដោយបែប	ហើយខ្វល់គល់តែបមានចាស់ថ្មី
គ្រឿងស្លៀកគ្រឿងពាក់ការប្តី	មានបុណ្យទាំងអ្វីប្តីស្លៀកទៅ ៗ
មួយទៀតប្តីចេញចាកគ្រឹហា	ជិតឆ្ងាយក្តីណាខ្លួននាងនៅ
ចាំផ្ទះថែទាំឃ្លាំមើលផ្លូវ	មកដល់លំនៅចុះទទួល ៗ
ទឹកមុខស្រស់បស់ញញឹមស្អាត	ប្រណិបត្តន៍ត្រូវខ្នាតដោយទំនួល
បើមានចំណីអ្វីដោយស្រួល	គួរលើកទទួលជូនជាមុន ៗ
ចូរនាងចងចាំតាមច្បាប់ស្រី	ប្រណិបតន៍ស្វាមីកុំទម្រន
មានកេរ្តិ៍ពីរោះឈ្មោះល្អលន់	ស្រីគន់ជួបស្ថានសួគ៌ធំធេង ៗ
២–សង្គហិតបរិជនា	កុំធ្វើកិរិយាដូចពីក្មេង

បើញាតិខាងប្តីគេមកលេង ឬក្រែងមានបើរកការអ្វី ៗ
ចូរនាងសង្គ្រោះដោយគួរសម រៀបចំហិបស្លាថ្នាំបារី
សួរសាកឲ្យដឹងដើមហេតុ រកអ្វីលៃលកមើលមុខក្រោយ ៗ
បង្ការថ្ងៃក្រោយយើងមានការ បានញាតិការពារជួយគិតឲ្យ
ហេតុនេះត្រូវយើងធ្វើអំណោយ ពេលក្រោយយើងក្រគ្រាន់គេយកគន់ ៗ
តែពាក្យបុរាណមានមួយផ្នែក ថាសប្បុរសពេកច្រើនចាញ់ជន
អ្នកណាប្រុសប្រាជ្ញចិត្តទុជ៌ន បានក្តីទម្ងន់ចាញ់ឥន្ទ្រិយ ៗ

៣ -ពោរវតីអនុគិតា·

រីឯស្រីណាចិត្តសោកី
រួមរ័ក្សស្ម័គ្រចិត្តគិតពេញទី មានចិត្តរម្មណីយប្តីពិតៗ ៗ
ទោះខ្មៅទោះសក្អិលខូច ឬកពាបភាពតូចក៏ចូលចិត្ត
ឃើញប្រុសដទៃគ្មានចិត្តគិត ចង់ផិតចង់ផាយហោលប្តីឯង ៗ
បើនាងផិតប្តីខុសទំនងច្បាប់ ព្រះពុទ្ធទ្រង់ប្រាប់ស្តាប់ឲ្យស្តែង
ត្រូវស្តាយកេរ្តិ៍ឈ្មោះយសខ្លួនឯង ព្រោះទោសនោះតែងបានបាបធ្ងន់ៗ

៣– សម្បត្តិអន·

ក្នុងមានល័ក្ខណ៍ធ្វើប្រពន្ធ
ចេះរៀបទុកដាក់ទ្រព្យធន ទ្រព្យអ្វីស្រាលធ្ងន់មិនខូចខាត ៗ
ប្តីរកបានមកទុកដោយបទ គិតក្រែងក្រខ្សត់មានសំកាត
សំអាងកុំចាយឲ្យហួសខ្នាត ឲ្យសមបទបាទខ្លួនជាស្រី ៗ

កុំមានទ្រព្យច្រើនក្រើនតាយ ក្រែងមានអន្តរាយក្រោយក្ដី
បើយើងមានទ្រព្យនោះគប្បី ប្រាជ្ញាធ្វើអ្វីបានដូចចិត្ត ៗ
បើយើងក្រឡត់អត់ទ្រព្យធន មានការទម្ងន់ព្រួយរិះគិត
បុរាណលោកចងជាភាសិត ថាទ្រព្យគង់ល្បិតតែពីស្រី ៗ

៥-ទុក្ខាអនលសា

កូនស្រីគ្រប់គ្នាគួរគប្បី
ស្ដាប់តាមពុទ្ធដីកាព្រះជិនស្រី ត្រូវខំឃ្មាតខ្មីខំប្រឹងប ៗ
រៀនដេរផុលប៉ាក់ចាក់ជាក្បាច់ កុំល្ងង់លេបលង់ទន្ទិរល
សំអាងសំអាតចាកមន្ទិល កុំខ្ជិលឲ្យខ្ជាប់ជាប់កល់ថ្ងៃ ៗ
កុំធ្វើប្រកាន់ថាតាមថោក ខំរៀនខំរកកំរៃទ្រព្យ
កុំរើសរកការណាថោកថ្លៃ សព្វថ្ងៃដំឡៃភេទទាំងអស់ ៗ
គង់លោកបច្ចុប្បន្នមនុស្សកើតមក គេខំរៀនរកទាំងស្រីប្រុស
គេកប់តែអ្នកមានរបស់ តែយើងគ្មានសោះនឹងខ្វះស៊ី ៗ
សូម្បីបងប្អូនសាលោហិត សាច់ញាតិជុំជិតលំនៅទី
គេលែងរាប់រកធ្វើគ្នាគ្នី អាប់ឱនអំពាក់ពិទួន ៗ
សន្ធើបថែបបទពាក្យប្រដៅ ទុកគ្រាន់កូនចៅជាច្បាប់ក្បួន
កូនស្រីត្រូវចាំបណ្ដាំជូន នឹងបាននាំខ្លួនទៅសួគ៌ា ៗ
លោកិយប្រសើរសើងសព្វមុខ ទាំងម្ដាយឪពុកញាតិមីងមា

ឲ្យគេរាប់មុខកូនពាប់គ្នា    ចប់ពាក្យពណ៌នាស្រះម៉្រះហោង ។

# ជំពូក ៣

## បណ្ដាំឪពុក

### បទព្រហ្មគីតិ

ឱ! កូនស្ងួនពន្លក    ចូរអ្នកយកពាក្យបិតា
ទៅកាន់ថែរក្សា    កុំបីបាប្រហែសឡើយ ។
ឪពុកចាស់ហើយណា៎    មានតែបាបុត្រត្រាណត្រើយ
ស្នងខ្លួនឪពុកហើយ    ប្រុងប្រយ័ត្នណា៎កូនណា៎ ។
ត្រូវរិះរករៀនច្បាប់    ចាំឲ្យខ្ជាប់ក្នុងអាត្មា
ខំប្រឹងរៀនសិក្សា    ពាក្យបិតាទុកក្នុងប្រាណ ។
បើកូនស្ងួនពន្លក    អ្នកកាន់យកដំបូន្មាន
បិតាកូននឹងបាន    សុខក្សេមក្សាន្តយ៉ាងឧត្ដម ។
ហើយកូនស្ងួនឪពុក    ពេញមាត់មុខថ្កើងថ្កូនមាំ
ឥតមានក្ដីបារម្ភ    បានរុងរឿងកេរ្ដិ៍បិតា ។
អ្នកកុំអាងយសស័ក្ដិ    អាងមាសប្រាក់ហាលប្រាជ្ញា

ម្ដេចកាន់កិរិយា　　　ចុកសុភាពទើបប្រពៃ ។
ថ្កើងកេរ្តិ៍ថ្កើងរូបអង្គ　　　ថ្កើងពូជពង្សផុតក្រៃ
មានសួស្ដីនិងជោគជ័យ　　　ក្នុងលោកិយនេះណាបា! ។

ក)(១) លោកឲ្យគ្រាប់ពុតកង់　　　ដែលវិលវង់ត្រូវគ្រប់គ្នា
កុំគ្រាប់ពុតសត្វា　　　ឃើញតែសាច់ចង់ស៊ីនោះ ។

ខ) កុំគ្រាប់ពុតដើមជ្រៃ　　　ពឹងប្រស្រ័យឈើណាផ្ដោះ
យូរទៅរិតឈើនោះ　　　ឲ្យដល់ឆាប់នោះមិនល្អ ។

គ)- ឲ្យគ្រាប់ឯកុកសាប់　　　កុំបីគ្រាប់ឯកុកស
ឲ្យគ្រាប់ឬស្សីល (២)　　　កុំបីគ្រាប់កន្ទ្រាញស្នាយ ។

ឃ)- ឲ្យគ្រាប់សត្វក្ងោក　　　កុំបីយកពុតទន្សាយ
ឲ្យគ្រាប់ម្ទេសប្រាជ្ញប្រាយ　　　កុំបីគ្រាប់ជនពាលា ។

## ពាក្យពន្យល់

ក)- លោកឲ្យគ្រាប់ពុតកង់　　　វិលត្រូវអង្គគ្រប់អាត្មា
ឲ្យមានចិត្តជ្រះថ្លា　　　ត្រជាក់ជាក្នុងសន្តាន ។

---

១ អក្សរនេះ គ្រាន់តែដាក់ឲ្យដឹងចំនួន មិនឲ្យអានទេ ។

២ ឬស្សី ១ ពូកដែលលិចរលំចុះទៅក្នុងទឹក ហើយដែលមើលទៅឃើញតែដើមភ្លឺបភ្លែតឡើង ដោយសារទឹកហូរ នោះហៅថាឬស្សីល ។ ឬស្សីលនេះ បើចាប់លើកឡើងតែងបានច្រើនដើម ។

កុំឲ្យត្រាប់ពុតខ្លា ឃើញមនុស្សសឹងតែឃ្លាន

ប្រាថ្នាចង់តែបាន ដូចមនុស្សលោកក្រៅតម្រា ។

ខ)–កុំឲ្យត្រាប់ពុតក្រៃ ពឹងប្រស្រ័យដើមឈើណា

រូបរឹតជិតលុះត្រា តែឈើនោះលុះដល់មរណ៍ ។

គ)–ឲ្យត្រាប់ពុតកុកសាប កុំបីត្រាប់ពុតកុកស

ឲ្យត្រាប់ឬស្សីលេ កុំបីត្រាប់កន្ទ្រាញស្នាយ ។

អំពើពុតកុកសាប ប្រសើរតាប់លបលាក់កាយ

គឺមិនអួតប្រុះជប្រាយ ចេះអាគមមន្តកលកិច្ច ។

កុកសសម្បុរថ្លា នោះយាត្រាត្រេចហើរហិច

ពុំប្លែកបែបកលកិច្ច កលនោះម្តេចដូចមនុស្សខ្មៅ ។

អួតអាងអគ្គអាត្មា ភូតកថាដោយសៅដៅ

ទុកចិត្តជឿមនុស្សក្រៅ ទ្រព្យផងនៅពុំកំបាំង ។

រីឯឬស្សីល គល់ភ្លឺរៀងពល់ថ្នាំង

អ្នកផងគិតសម្រាំង សម្រួលទៅត្រូវប្រាថ្នា ។

រីឯស្នាយកន្ទ្រាញ នោះសឹងសាញដូចបន្ទា

គម្រមានអ្នកណា ប៉ងប្រាថ្នាធ្វើការអ្វី ។

ក្អែកលោកពប់អាន ថាបើបានយកមកខ្ញី

កន្ទុយល្អពីស៊ី　　មានស្នើខៀវសព្រឿង ៗ
អ្នកផងវីវងចូលចិត្ត　　បានមកគិតទុកជាគ្រឿង
កាក់តែងវីវង់រុងរឿង　　ធ្វើដំកើងយសបរិវារ ៗ
　　ទន្សាយពុកភ្លុកនៅ　　កោរកាត់ស្រូវស្រែចំការ
គេឃើញខឹងសម្បារ　　នាំគ្នាដាក់បង្កាត់បាន ៗ
　　ហេតុនេះលោកប្រដៅ　　កុំបីទៅចូលផ្សព្រាណ
នឹងអ្នកខ្ទៅសាមាន្យ　　នាំអសោចកេរ្ដិ៍អាត្មា ៗ
　　ហៃអស់កូនទាំងឡាយ　　កុំភាយមាយខំស្ដាប់
រិះរកវៀនមាត្រា　　ច្បាប់ទម្លាប់ឲ្យចាំថែន ៗ
ប្រុងចិត្តប្រុងបញ្ញា　　កុំមុសាឲ្យវង្វេង
យកតែទីងចិត្តឯង　　មិនគិតក្រែងគ្រូបរិយាយ ៗ
មិនយកតាមសណ្ដាប់　　មិនត្រាប់ច្បាប់លោកពីនាយ
គួរបេះរិះដោះស្រាយ　　ពាក្យទំនៀមទំនាយនោះ ៗ
យកទុកក្នុងចិន្ដា　　ពិចារណាឲ្យចំពោះ
រំពឹងឲ្យសាយសុះ　　សព្វសេចក្ដីកុំបីធ្លោយ ៗ
កុំយកតាមចិត្តឯង　　មិនគិតក្រែងក្រក្រោយ
ចិត្តទឹងកុំបណ្ដោយ　　បណ្ដែតឲ្យកើតទោសា ៗ

កុំលោភកុំបង់បាន ធ្វើបំពានក្រៅគម្រោ
កុំគាំងមានប្រាជ្ញា ថាគេល្ងង់មិនចេះស្មើ ៗ
ឃើញក្មេងកុំមាក់ងាយ ឃើញអ្នកឆ្ងាយកុំសើរើ
មានក្អែកឲ្យចេះប្រើ មើលឲ្យសព្វកុំទំនេរ ៗ
ទីងឈានឲ្យមានរប់ ពោះទីងឈប់ឲ្យគិតគួរ
ខឹងធ្លួលកុំគាលជេរ មើលទៅគេកុំមាក់ងាយ ៗ
ក៏ខុសកុំគាលទំ ក៏សុខមកុំពែងចាយ
រំពឹងឲ្យវែងឆ្ងាយ នោះទើបហៅអ្នកប្រាជ្ញា ៗ
កុំធ្វើពារបំពាន លោកបង់បានក្រៅគម្រោ
កុំគាំងយសសក្តា បុណ្យអំណាចធ្វើគេបាន ៗ
មិនគិតត្រង់បាបបុណ្យ ទោសទុក្ខធ្ងន់ដូចដល់ប្រាណ
ចំណេរទៅទីងមាន ទោសទុក្ខភ័យពុំឃ្លាតឃ្លា ៗ
ដូច្នេះអស់កូនៈចៅ ចាំតទៅគ្រប់គ្នា
ត្រូវផ្គង់ប្រុងកាយា តាមមាត្រាច្បាប់ប្រដៅ ៗ
កុំធ្វើតាមចិត្តពាល កុំស្រើបស្រាលដោយមនុស្សខ្លៅ
គេប្រាប់កុំគាលទៅ ព្រោះគេហៅកុំគាលអរ ៗ
ទីងណាស់ឲ្យខំអត់ បើខ្ជូនខ្សត់ឲ្យខំរក ,

គេឲ្យកុំអាលយក ទ្រព្យបានមកឲ្យទុកដាក់ ៗ
ថែទាំទើបគង់ទ្រព្យ មានប្រដាប់ទើបថ្កើងស័ក្តិ
ធ្វើការទើបបានប្រាក់ មានបុណ្យស័ក្តិព្រោះឧស្សាហ៍ ៗ
បាត់យសព្រោះក្តីខ្ជិល បាត់ពានសីលព្រោះសេពស្រា
ខឹងច្រើនបាត់ប្រាជ្ញា ចិត្តមោហាភ្លេចគិតទក ៗ
ឲ្យចាំដាក់ក្នុងប្រាណ គ្រាន់ទូន្មានខ្លួនយប់ព្រឹក
បើភ្លេចឲ្យរំលឹក រិះគិតនឹកពាក្យប្រដៅ ៗ
របស់ឪពុកម្តាយ គ្រូបាធ្យាយក្រែងខ្លួនខ្លៅ
អ្នកប្រាជ្ញលោកចេះជ្រៅ ចងជាច្បាប់នេះទុកមក ៗ
ប្រដៅកូនគ្រប់គ្នា ឲ្យឧស្សាហ៍រះរៀនរក
រៀនច្បាប់ចាប់ចាំយក ជាពន្លកពន្លឺខ្លួន ៗ
កូនណាឧស្សាហ៍ស្តាប់ គេគ្រងគ្រាប់ទុកជាក្បួន
កូននោះនឹងមាំមួន បានសុខខ្លួនក្នុងលោកិយ ៗ
ឥតទុក្ខឥតទោសា ល្អថ្លៃថ្លាទាំងប្រុសស្រី
ទោះទៅនាលោកីយ បរលោកក្តីបានសួគ៌ា ៗ

# ជំពូក ៤

## បកិណ្ណកៈដំបូន្មាន

### ស្ដីពីគុណនៃសេចក្ដីព្យាយាម

បទពាក្យ ៧

នេះពាក្យទំនៀមបុរាណមុន ទូន្មានពួកជនតទៅមុខ
ឲ្យអស់គ្នាទៅចងចាំទុក នឹងបានទីសុខដោយស្មោះស្ម័គ្រ ។
ព្យាយាមសិក្សានឹងបានចេះ ព្យាយាមត្រិះរិះនឹងយល់ជាក់
ព្យាយាមធ្វើការរកមាសប្រាក់ ព្យាយាមរាក់ទាក់នឹងបានមិត្ត ។
ព្យាយាមទន្ទេញនឹងបានចាំ ព្យាយាមចំណាំនឹងមិនភ្លាត់
ព្យាយាមប្រុងប្រមនឹងមិនព្រាត់ ព្យាយាមផ្ទៀងផ្ទាត់នឹងបានត្រង់ ។
ព្យាយាមរក្សានឹងមិនបាត់ ព្យាយាមហ្វឹកហាត់នឹងបានធ្លាប់
ព្យាយាមចូលគាល់នឹងបានគាប់ ព្យាយាមថែទ្រព្យនឹងមិនខាត ។
ព្យាយាមដុសលាងនឹងបានជ្រះ ព្យាយាមជំរះនឹងបានស្អាត
ព្យាយាមប្រយ័ត្នគ្មានប្រមាទ ព្យាយាមទុកហាតនឹងបានសុខ ។
ព្យាយាមសង្កេតនឹងយល់ការ ព្យាយាមវិចារណ៍[1] យល់ទៅមុខ
ព្យាយាមក្លាយខ្លួនរួចចាកទុក្ខ ព្យាយាមរុលរុកឈ្នះឧបសគ្គ ។

---
១ ពិចារណា ។

ព្យាយាមធ្វើល្អទើបបានបវរ(១) ព្យាយាមស្មោះសរគេស្មោះស្ម័គ្រ
ព្យាយាមរាប់អានគេរាក់ទាក់ ព្យាយាមគារវៈបានអំណាច ។
ព្យាយាមតស៊ូទើបបានឈ្នះ ព្យាយាមមានះទើបអស់អាច
ព្យាយាមម៉ឺងម៉ាត់មានគេខ្លាច ព្យាយាមលះកាចបានការុណ(២) ។
ព្យាយាមសន្សំទើបបានមាន ព្យាយាមធ្វើទានទើបបានបុណ្យ
ព្យាយាមរៀនមិនជាបដុន ព្យាយាមធ្វើគុណទើបគ្មានទោស ។

## ជំពូក ៥

### បកិណ្ណកៈដំបូន្មាន

### ស្ដីពីកិច្ចត្រូវស្គាល់គ្រប់លក្ខណៈ

បទកាកគតិ

កើតមកជាមនុស្ស គួរស្គាល់ត្រូវខុស
ស្គាល់ធ្ងន់ស្គាល់ស្រាល ស្គាល់បាបស្គាល់បុណ្យ
រើសទន់ប្រាជ្ញពាល ដើមចុងកណ្ដាល
ស្គាល់ខ្លាចស្គាល់ហ៊ាន ។
ស្គាល់តិចស្គាល់ច្រើន សន្សាតក្រើន
ស្គាល់អត់ស្គាល់ឃ្លាន ស្គាល់វៀចស្គាល់ត្រង់
ស្គាល់ចង់ស្គាល់បាន ស្គាល់ដីស្គាល់ដាន

---
១ ល្អ ។ ២ សេចក្ដីករុណា ។

ស្គាល់ព្រៃស្គាល់គ្រាញ់(១) ។

ស្គាល់គាប់ស្គាល់ខុស ស្គាល់ស្លាប់ស្គាល់រស់
ស្គាល់ឈ្នះស្គាល់ចាញ់ ស្គាល់ឆ្ងាញ់ស្គាល់ជោះ
ស្គាល់ដោះស្គាល់ដេញ ស្គាល់ចូលស្គាល់ចេញ
ស្គាល់ក្រស្គាល់មាន ។

ស្គាល់តឹងស្គាល់ធូរ ស្គាល់ឆាប់ស្គាល់យូរ
ស្គាល់មានស្គាល់គ្មាន ស្គាល់ដើរស្គាល់ដេក
ស្គាល់ស្រេកស្គាល់ឃ្លាន ស្គាល់ខ្ពស់ទាបមាន
ស្គាល់ទ័លស្គាល់ក្រ ។

កិច្ចត្រូវស្គាល់នេះ កូនត្រូវចាំចេះ
ហើយត្រូវកាន់យក ត្រង់បទជាបុណ្យ
ជាគុណល្អៗ លះបទមិនល្អ
ឲ្យឆ្ងាយចេញហោង ។

# ជំពូក ៦

បកិណ្ណកៈជំបូន្មាន

ស្តីពីព្យញ្ជនៈ (ក) ទីងស្រ (ុ)

ផ្សំបានជាពាក្យ (កុំ)

---

១-ភិលគូប ៗ មានស្មៅទាបៗ ។

បទពាក្យ ៧

នេះគឺពួកគួរគប្បី "កុំ" ចូរកូនទាន់កុំបីកយមាយ

ពាក្យនេះទុកដូចជាសំពាយ ទៅបរលោកនាយគ្រាន់ជាស្បៀង ។

កុំគិតស្រេពេកវាបែកបាក់ កុំឲ្យថ្នាំងថ្នាក់វាបាត់សួន

កុំខ្ជិលច្រអូសវាថោកខ្លួន កុំឲ្យវេះពួនវាបាត់មុខ ។

កុំមានះពេកវាបែកមិត្ត កុំឲ្យទ្រុស្តស្និទ្ធវាបាត់សុខ

កុំឲ្យលើកខ្លួនវាផ្ទួនទុក្ខ កុំឲ្យបាត់មុខវាអប្រីយ ។

កុំឲ្យលាក់ស្នេហ៍វាបែរឃ្លាត កុំឲ្យទ្រុស្តញាតិវាកើតក្តី

កុំឲ្យហ៊ានហួសអាយុខ្លី កុំឲ្យរាយស្រីវាខូចបុក ។

កុំឲ្យស្ទៀមដៃវាធ្លាប់លួច កុំឧបជន្លង់វាធ្លាប់ស្ពឹក

កុំឲ្យយឺតពេកវាទ្រមឹក កុំឲ្យធ្មើងបុកគេខ្ពើមស្អប់ ។

កុំឲ្យស៊ីច្រើនវាបែកពោះ កុំឲ្យលេះលោះវាខូចទ្រព្យ

កុំឲ្យខុសបរៀយវាអតត្ថ័ កុំឲ្យលេលាប់វាធ្លាប់ចិត្ត ។

## ជំពូក ៣

### បកិណ្ណកៈជំបូន្មាន

ស្តីពីស្រៈ (ឱ) និងព្យញ្ជនៈ (យ)

ផ្សំបានជាពាក្យ (ឱយ)

បទពាក្យ ៧

នេះគឺពួកគួរអក្សរទុយ កូនចៅខាងក្រោយត្រូវរក្សា
ទុកជាសម្បត្តិកេរ្តិ៍ជូនតា តម្រាប់តម្រាច្បាប់ចាស់ថ្មី ។
ឲ្យរៀនអត់ទុនពាក្យជូនតា ឲ្យរៀនវិជ្ជាការលោកិយ
ឲ្យរៀនចិត្តល្អកុំខ្វះខ្វី ឲ្យខំឃ្មាតខ្មីរកទ្រព្យធន ។
ឲ្យរៀននូវច្បាប់ប្រពៃណី ឲ្យខំរកស៊ីកុំលួចប្លន់
ឲ្យសង្គ្រោះញាតិមានអាសន្ន ឲ្យចេះអត់ធន់ក្តីទាំងឡាយ ។
ឲ្យចាំទំនៀមទំនងព្រេង ឲ្យចេះចាំថែងបទបរិយាយ
ឲ្យចេះពប់គ្រឿងលានជិតឆ្ងាយ ឲ្យផ្សាយមេត្តាដល់ជនផង ។
ឲ្យស្គាល់ខ្ពស់ទាបដកបទៅ ឲ្យស្គាល់ប្រាជ្ញខ្លៅនូវរៀមច្បង
ឲ្យចងចាំចិត្តទឹកខ្ញាបហ្នង ឲ្យគ្រាប់ឲ្យគ្រង់ច្បាប់ធម្មា ។
ឲ្យមានមេត្តាប្រយ័ត្នទោស ឲ្យមានសន្តោសលះរាក
ឲ្យមានមេត្រីប្រណីគ្នា ឲ្យមានចិត្តជាជាប់ទទី ។

## ជំពូក ៨

### បកិណ្ណកៈដំបូន្មាន

ស្តីពីព្យញ្ជនៈ ( ប ) និងស្រៈ ( ើ )

ផ្សំបានជាពាក្យ ( បើ )

បទពាក្យ ៧

នេះគឺពួកតួអក្សរ " បើ " មានគុណលើសលើកពដែនដី
កូនចៅប្រុស ៗ នឹងស្រី ៗ គប្បីចង់ចាំចណ្ដាំពិត ៗ
បើម៉្វីនឹងបេះឲ្យគេកោត បើម៉្វីនឹងដោតឲ្យគេអាណិត
បើម៉្វីនឹងហ៊ានឲ្យមានចិត្ត បើម៉្វីនឹងគិតឲ្យថ្លៃថ្លា ៗ
បើម៉្វីនឹងកាចឲ្យពេញវង្ស បើម៉្វីនឹងល្ងង់ឲ្យផុតថា
បើម៉្វីនឹងបេះឲ្យហានក្លា បើម៉្វីពប់គ្នាឲ្យទៅមក ៗ
បើចិត្តគិតស្អប់កុំឲ្យបាញ់ បើចិត្តស្រឡាញ់កុំឲ្យរក
បើស្រីប្ដីលែងកុំឲ្យយក បើថ្កុចង់ម្ចាស់មកកុំក្បា ៗ
បើរនាបបាក់គ្រាន់នឹងជួស បើសំដីហួសបង់ទ្រព្យា
បើធ្វើតាមហានត្រូវធានា ការជាតិសាសនា ព្រះមហាក្សត្រិយ៍ ៗ
ពាក្យនេះបុពណលោកទូន្មាន កូនចៅគ្រប់ប្រាណចូរប្រណិប័តន៍
ចង់ចាំគ្រប់បទដោយមធ្យត កុំបីភ្លាំងភ្លាត់បទណាឡើយ ៗ

## ជំពូក ៩

### បកិណ្ណកៈដំបូន្មាន

### ស្ដីពីមេអំបៅជៀលផ្លូវ

បទកាកគតិ

មេអំបៅថា អាបោះមោហា សត្វដង្កូវនេះ រូបកងអាក្រក់
ក្រខ្វក់អីម្ល៉េះ ក្លិនខ្ទុយឆ្អាបឆ្អេះ អញខ្ពើមណាស់ណា ។
ទៅណាក៏ទ្រែលទ្រល អាក្រាលទនល ជាអនាថា ម្តេចក៏គេឃើន
ព្រហើនមហិមា វារលើផ្កាណា ផ្កានោះបាត់ក្លិន ។
បៀសចេញឲ្យឆាប់ ខំនៅទីស្ងាប់ ទីងិរង្គិកមរិន(១) ចិញ្ចឹមជីវី
ទីងផ្កាមានក្លិន ជាតិឯងជាតិហិន ទៅសុំលាមកគេ ។

ដង្កូវថាយើ! ពីម្សិលមិញតើ! ក្លួចខ្លួនហើយបៅ ស្លាបខ្លួនទៅ
អ្នក ត្រជាក់ប្តូក្តៅ សត្វមេអំបៅ ចេញទៅពីណា ? ។
ឲ្យដឹងជាតិខ្លួន សមលេងសំនួន ដៀលគ្នាទោរ៉ា កុំអាលគ្នះគេ
ជាមេជាបា ដូចបាចខ្សាច់ណា ប្រាសខ្យល់វិញទៅ ។

រឿងនេះព្រះច្បាប់ លោកមិនឲ្យត្រាប់ តាមមេអំបៅ
ជាសត្វដែលកើត កំណើតដង្កូវ ហើយដៀលគ្នះទៅ
កំណើតដើមឯង ។

---

១- កគ្ទង់ ។

# រឿងសាមកុក

## កណ្ឌទី ៤១

ឧកញ៉ាវិបុលរាជសេនា ញ៉ូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងចេះឧបាយកលបំណាន<br>ទាំងមានសន្ដានស្នេហាជាតិ។ |

អ៊ុយកាយឮដូច្នោះក៏ស្រាយជម្ងឺក្នុងខ្លួន ខំផ្ចង់ខ្លួនក្រោកឡើងអង្គុយ ទន់នាប់ឆាំតេកហើយថា ដែលអ្នកទទួលសារភាពជួយទំនុកបំរុងការទាំងអម្បាលនេះខ្លួនអ្នកមិនបង់កំឡាំងដែលបានតាំងខ្លួនមកធ្វើជាទាហានទេ ៗ ឆាំតេកថា ការនេះនឹងបង្អង់ឲ្យយូរមិនបាន បើអ្នកមានកិច្ចត្រូវពន្យល់បំភ្លឺយ៉ាងម្ដេច ក៏ឲ្យប្រញាប់ប្រាប់ឬធ្វើជាសំបុត្របុតហាយឲ្យមកចុះ ខ្ញុំនឹងអាលទៅរិះគិតឲ្យបានប្រយោជន៍ក្នុងរាជការរបស់នាយចៅហ្វាយយើង ៗ អ៊ុយកាយក៏ខំប្រឹងសរសេរសំបុត្រ ហើយបិទស្រោម ហុចទៅឲ្យឆាំតេក ហើយប្រាប់ថា ចូរអ្នកខំទៅគិតឲ្យបានសម្រេចការរាជការរបស់នាយចៅ

ហាយយើងចុះ ៗ ឆាំតេកទទួលសំបុត្រហើយក៏លាទៅកាន់ទីសំណាក់ លុះវេលាយប់ក៏កែងខ្លួនស្លៀកពាក់បន្ទំជាព្រានប្រម៉ង់ ចុះទូកចែវតម្រង់ទៅជិតបន្ទាយបូឆ ៗ

ខណៈនោះទទួលពួកពាហានយាមល្បាតកងទ័ពបូឆ ឃើញមនុស្សប្លែកចែវទូកតូចចូលទៅក៏ចាប់យកខ្លួនទៅសាកសួរ ហើយចូលប្តឹងដល់បូឆតាមការថា យើងខ្ញុំចាប់មនុស្សបង់ត្រីបានម្នាក់ បានសួរបញ្ជាក់ថាឈ្មោះឆាំតេកជាទីប្រឹក្សាស៊ុនគួនទឹងបង់ចូលមកជាកបការអាថ៌កំបាំង ដល់លោក បូឆ ឮដូច្នោះក៏ថា ឆាំតេកមកនោះ ប្រាថ្នាទឹងស៊ើបស្ដាប់ការក្នុងកងទ័ពយើង ទើបឲ្យយកខ្លួនឆាំតេកចូលទៅក្នុងបន្ទាយ ប្រហែលយាម ៣ បាយ សួរថាខ្លួនអ្នកមកក្នុងទីនេះដោយហេតុអ្វី ? ៗ ឆាំតេកឆ្លើយថា ខ្ញុំបាទបានឮគេនិយាយជាច្រើនគ្នាថា មហាខុបកជនេះ មានកម្រិះប្រាជ្ញាជ្រៅទូលាយណាស់ ប្រកបទាំងចិត្តក៏សុចរិតល្អ មានអធ្យាស្រ័យសុភាពរៀបរយ គួរសមនឹងខ្ញុំរាជការតូចតាច់មិនរើសមុខ ខ្ញុំបានដឹងទំនុកដូច្នេះ បានជាចូលមកដល់លោក ខុបមាដូចមនុស្សទញ់ពាល់ដើរផ្លូវ ហើយស្រេកទឹកណាស់ លុះបានទៅប្រទះឃើញស្រះមានទឹកថ្លា ក៏ប្រាថ្នានឹងដងទទួលទានដោយអំណរនេះដូចខ្ញុំបាទបានមកឃើញមុខមហាខុបកជបើល្អ ប្រកបដោយអំណាច ខ្ញុំឃើញថាជាអ្នកប្រកាន់ទិដ្ឋមានះ មិនបានស្គាល់ច្បាស់ជាមនុស្សល្អនឹងអាក្រក់សោះ បើនឹងពិគ្រោះមើលឲ្យ

សព្វ កំមិនគាប់តាមពាក្យដែលគេពបសរសើរអួតនោះសោះ ដែលគំនិតអ៊ុយកាយនឹងខ្ញុំបាទបានរិះគិតចាត់ប្រើឲ្យខ្ញុំបាទមកនេះ ក៏ព្រួយការអសារប្រយោជន៍ទៅទទេ ៗ

ចុច្ចពុដ្ឋទោះក៏សួរថា យើងនឹងស៊ិនគួនទៅហ្វាយស្រុកកាំងតាំង ក៏ជាខ្មាំងសត្រូវធ្វើសឹកសង្គ្រាមនឹងគ្នា ខ្លួនអ្នកឯងក៏ជាទីប្រឹក្សារបស់ស៊ិនគួនដូចជាគូសត្រូវនឹងយើងដែរ ដែលអ្នកឯងមកនេះ ហេតុម្តេចកំមិនសាកសួរឲ្យដឹងសេចក្តីពីក្រៅឲ្យច្បាស់ថាចូលមកនេះ នឹងល្អឬអាក្រក់ជាមុនសិន ឬនឹងមកសង្កត់សង្កិនបន្ទំឲ្យយើងរត់ចុះទៅទទួលអ្នកឯងនោះ ជាគួរសមនឹងអធ្យាស្រ័យនៃមេទ័ពដ៏ជាធំហើយឬ ៗ ឆាំគេកពុដ្ឋទោះក៏ធ្វើជាសរសើរចុច្ចថា លោកមានប្រសាសន៍នេះត្រូវណាស់ ហើយថាអ៊ុយកាយនោះ បានទៅធ្វើពជការតាំងពីគ្រាស៊ិនគៀននឹងស៊ិន-សេកតហ្ពូតមកដល់ស៊ិនគួន ត្រឹមអំណាចស៊ិនគួនក៏នៅមិនដែលមានបាបទោសខ្លួនពីអ៊ីសោះ ឥឡូវធ្លាក់មកដល់មុខឆាំរជីវយី បានធ្វើជាមេទ័ពប៉ុណ្ណោះ ដោយស៊ិនគួនលើកមុខពថ់ថា មានតម្រិះប្រាជ្ញា ជីវយីក៏កៀវក្ខាក់រើបចិត្តឥតកេតក្រែង តាំងតែបញ្ចាញអំណាចហារក៏ហែងប្រើបង្គាប់អ៊ុយកាយដែលជាខ្ញុំពជការចាស់ ឲ្យលុះក្នុងអំណាចខ្លួនបានសេចក្តីអ័ប្បយសផ្សេង ៗ ពាល់តែបណ្តាលចិត្តរង្វើងឲ្យជាប់អាឃាតព្យាបាទជីវយីវិញ ឯអ៊ុយកាយនឹងខ្ញុំបាទនោះ គឺជាកៀនសំឡាញ់គ្នាដ៏ស្និទ

ធ្លាប់ស្គាល់ចិត្តកក់ក្ដៅនៅនឹងគ្នាដូចបងប្អូនបង្កើតមកយូរហើយ គ្រានេះអ៊ីយកាយក៏មានទុក្ខទោមស្ស លុះនឹងលះបង់មកនៅជ្រកកោននឹងលោកក៏ពុំអាចដឹងថាចិត្តលោកមានសេចក្ដីអាណិតអាសូរករុណាដែរឬយ៉ាងម្ដេច ពាល់គំនិតគិតមិនដាច់ស្រេច ព្រោះត្រូវទណ្ឌកម្មដោយអាជ្ញាដីវយើរាយ ដំគ្រាំគ្រាជាទម្ងន់ណាស់ បេះតែគិតមិនស្រេចស្រឡះជាយូរថ្ងៃណាស់មកហើយ ទើបវេលានេះក៏ប្រថុយប្រថ៊ខ្ញុំបាទឲ្យមកជំនួស មានតាំងសំបុត្រ ១ ច្បាប់មកផង ដើម្បីនឹងគំនាប់ជូនលោក ។

ចូចុពុជូបោះសួរថា សំបុត្រអ៊ីយកាយដែលឲ្យមកនោះ ឥឡូវនៅឯណា ? ។ នាំគេកក៏ដកជូនទៅចូចុ ។ ទទួលហើយក៏ហែកស្រោមលាមើលឃើញមានសេចក្ដីថា:

" ខ្ញុំបាទអ៊ីយកាយ សូមគំនាប់មកដល់មហាទេបកជ្រាប, ព្រោះខ្ញុំបាទបាននៅធ្វើការតាំងពីស៊ីនតៀនទឹងប៊ុនសេក រហូតមកដល់ស៊ិនគួន ៣ ចៅហ្វាយនាយនេះហើយ មិនដែលបានទទួលនូវទុក្ខភ័យអន្តរាយអ្វីសោះ គុណរបស់សែស៊ុខជាទម្ងន់ពេកក្រៃប្រៀបពុំបាន ខ្ញុំបាទតាំងចិត្តនឹងគិតធ្វើការតបស្នងសងគុណគេជានិច្ច ដែលលោកលើកកងទ័ពមកគ្រានេះ មានទាហានរាប់ម៉ឺន តម្រិះប្រាជ្ញាលោកក៏ជ្រៅទូលាយ ទេបមាដូចដុំថ្មសិលាដ៏ធំមិនរលីករម្រើក ឯទាហានក្នុងស្រុកកាំងតាំងក៏មានតិច ទេបមាដូចពងមាន់ដ៏តូច . . . . . . . .

(នៅមានត)

# ពាក្យវប្បធម៌

លោក នាន-ហ៊ូ រៀបរៀង

លោក សម-ថាំង ពិនិត្យ

---

អស់លោកអ្នកទាំងឡាយ !

ក្នុងវេលានេះ គណៈកម្មការវប្បធម៌ សូមធ្វើអត្ថាធិប្បាយ ដោះស្រាយទឹងសំនួររបស់លោក តន់-ម៉ន គ្រូបង្រៀន នៅសាលាបឋមសិក្សាបំពេញវិជ្ជា «សមោធិញាណ» ក្នុងឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដែលបានផ្ញើជាសំនួរមកឲ្យគណៈកម្មការវប្បធម៌ ដោះស្រាយ-រំគាយសេចក្តីផ្សាយ តបទឹងសេចក្តីសង្ស័យរបស់ខ្លួន ។

មុនទឹងដោះស្រាយតបទឹងសំនួរនោះ គណៈកម្មការវប្បធម៌ សុំថ្លែងនូវសេចក្តីគ្រេកអរដោយសុទ្ធចិត្ត ចំពោះលោក តន់-ម៉ន ដែលជាម្ចាស់សំនួរ ។

ក្នុងសំបុត្ររបស់លោក តន់-ម៉ន មានសេចក្តីសង្ស័យចំពោះពាក្យដូចខាងក្រោមនេះ :

១-មេត្តេយ្យសាលា

២– ហោស្បាយ

៣– បេតិកកណ្ឋ

៤– កញ្ញា នារី និងយុវតី

ពាក្យទាំងបីម៉ាត់នេះ តើជាស្រ្តីផ្សេងគ្នាដូចម្តេច ឬមួយជាពាក្យសម្រាប់ហៅបានច្រើនម៉ាត់ ៗ ឯពាក្យ ទី ១ ទី ២ និងទី ៣ ខាងលើ លោក តន់–ម៉ន ពុំបានបញ្ជាក់អំពីការងឿងឆ្ងល់របស់លោកផងទេ ប៉ុន្តែលោកអ្នកសួរនេះប្រហែលជាចង់ឲ្យយើងបកស្រាយពន្យល់អំពីអត្ថន័យ ក្នុងពាក្យទាំងនោះ ឲ្យបានយល់ច្បាស់ឡើងទៀត ។

៨– សួរថា ពាក្យជាភាសាខ្មែរសុទ្ធ ដែលពុំមានក្លាយមកពីបាលីនិងសំស្រ្កឹតទេ ហើយសរសេរត្រូវដាក់អក្សរ " រ " ពីមុខ តើមានលក្ខណៈ ឬមេរៀនអ្វីជាគ្រឿងចំណាំឲ្យពិតប្រាកដដែរឬទេ ?

យើងសុំឆ្លើយតបវិញតាមសំនួរទាំងអស់ដូចតទៅ :

ទី១– ពាក្យថា មត្តេយ្យសាលា=សរសេរ: ម ស្រៈអេ–ត ជើង ត–យ ជើង យ– ស–ស្រៈ អា–ល– ស្រៈអា ។ ពាក្យនេះ ជាពាក្យ បាលី , កើតមកពីសព្ទ ២ ម៉ាត់ គឺ មត្តេយ្យ: ១ និងសាលា១ ។ សំរេចមកពីរូបដើមថាមាតាតាមវេយ្យាករណ៍បាលី គេស្គាល់បានថាជាពួកភាវតទ្ធិតបុះ " ណ: " បច្ច័យ ។ បើចង់ជាបទវិគ្រោះថា មាតុយា

ការពារ, មាតេយ្យ ប្រែថា ការពារនៃមាតា ។ សាលា ប្រែថា រោងឬផ្ទះ ។ ប្រើរួបចូលគ្នាជាសមាសនាម បានជាមាតេយ្យសាលា, ប្រែតាមអត្ថានុរូប ថាសាលាមានការពារដូចជាមាតា ; តាមអត្ថប្បដិរូប បានទៅជាឈ្មោះនៃ សាលារៀនពិសេសមួយ ដែលគេសម្រាប់បង្រៀន ឬ អប់រំកុមារ-កុមារីតូច ៗ ដែលមានវ័យពុំទាន់ល្មមនឹងរៀនអក្សរសាស្ត្រនៅឡើយ ហៅថា មាតេយ្យសាលា បារាំង ថា (Ecole Maternelle) ។

ទី២ រហស្សោបាយ= សរៈសរ= រ ហ-ស-ជើងសស្រៈអូ ប ស្រៈអា និង យ ។ ពាក្យនេះ ជាពាក្យបាលីកើតមកពីសព្ទ ២ មាត់គឺ រហស្សៈ ១ និង ឧបាយៈ ១ រហស្សៈ ប្រែថា សេចក្ដីស្ងាត់, ការសម្ងាត់, ការកំបាំង, ឧបាយៈ ប្រែថា ល្បិច, កិច្ចកល, ផ្លូវគំនិត ។ រួបចូលគ្នាជាសមាសនាម បានជា រហស្សុបាយ ប្រែថា ល្បិច, កិច្ចកល ជាការសម្ងាត់ ។ បារាំង (Intrigue) ។

សុំជូនឧទាហរណ៍ ជាប្រយោគដូច្នេះ ដើម្បីឲ្យងាយយល់ ៖

ក្នុងពេលថ្មី ៗនេះ, ទោះបីពួកក្បត់មានរហស្សុបាយយ៉ាងណា ក៏ពួករដ្ឋកិច្ចបាលនៅតែឈ្លាសវៃជាងពួកសត្រូវ រហូតដល់ចាប់បានពួកអ្នកសមគំនិតឥតមានសល់ ។

ឧទាហរណ៍ ជាប្រយោគប៉ុណ្ណេះ បញ្ជាក់ជូនអស់លោកអ្នកឲ្យ

យល់អំពីពាក្យថា រហស្សប្បាយ ។

ទី៣ - ពាក្យថា បេតិកភណ្ឌ = ប + ស្រៈ អេ – ត ស្រៈ អិ - ក ភ - ណ - ជើង ឌ ។ ពាក្យនេះជាពាក្យបាលី, កើតមកពីសព្ទ ២ គឺ បេតិកៈ ១ និង ភណ្ឌៈ ១ ។ បេតិកៈ តាមវេយ្យាករណ៍បាលីជាពួកតទ្ធិត, សំរេចមកពីរូបដើមថា "បិតា" ។ ហើយជាបទវិគ្រោះថា បិតុនោ សន្តកំ, បេតិកំ ប្រែថា ជារបស់ ឬជាចំណែកខាងបិតា ; ភណ្ឌៈ ប្រែថា ទ្រព្យ, របស់, គ្រឿងប្រើប្រាស់, ផ្សំចូលគ្នាជាសមាសនាម បានជា បេតិកភណ្ឌ ប្រែថា ទ្រព្យ, របស់ជាចំណែកខាងបិតា, បារាំងថា (Patrimoine) ។

សុំជូនឧទាហរណ៍ ជាប្រយោគឲ្យងាយយល់ដូចខាងក្រោមនេះ ឯករាជ្យ នៃប្រទេសកម្ពុជា ជាបេតិកភណ្ឌរបស់ពលរដ្ឋខ្មែរគ្រប់រូប ព្រោះជាគុណសម្បត្តិបានមកដោយសារស្នាព្រះហស្ត របស់សម្តេចសហជីវិនជាព្រះបិតានៃពលរដ្ឋខ្មែរទាំងអស់គ្នា ។

យើងសុំបញ្ជាក់ជូនទៀតថា ទ្រព្យរបស់ផ្សេងៗទាំងអស់ ដែលជាចំណែក ឬជាកេរ្តិ៍ដំណែលខាងឪពុក ហៅថា បេតិកភណ្ឌទាំងអស់ ។ ក្នុងភាសាបាលី ជួនកាលឃើញមានប្រើសំដៅទៅលើទ្រព្យរបស់ទាំង២ ចំណែក គឺទាំងចំណែកខាងមាតានិងចំណែកខាងបិតា ក៏ហៅថា បេតិ-

កកណ្ដាដែរ ។

សេចក្ដីអធិប្បាយប៉ុណ្ណោះល្មមអស់លោក-អ្នកអាន អាចយល់បានអំពីពាក្យ ចេតិកកណ្ដានេះហើយ ។

សំនួរទី ៤ លោកតន់-ម៉ន សួរថាពាក្យ៣ម៉ាត់គឺ កញ្ញា-នារី និង យុវតី តើជាស្រីផ្សេងគ្នាដូចម្ដេច,? យើងឆ្លើយជូនវិញដូចតទៅនេះ

សូមអស់លោក-អ្នកអានទាំងឡាយជ្រាបថា ពាក្យទាំង៣ម៉ាត់ខាងលើនេះ មានអត្ថន័យមិនដូចគ្នាទេ ។ ពាក្យថា កញ្ញា ជាស្ត្រីក្មេងដែរ ប៉ុន្តែសំដៅទៅលើស្ត្រីក្រមុំ ដែលនៅជំទង់ពុំទាន់ពេញការនៅឡើយ ។ ឯពាក្យ យុវតី ក៏ជាស្ត្រីក្មេងដែរ ប៉ុន្តែសំដៅស្ត្រីក្រមុំគ្រប់ការហើយ ។ ដែលពុំទាន់មានគូស្រករនៅឡើយ ត្រូវគ្នានឹងពាក្យខ្មែរថា "ស្រីក្រមុំ" នេះឯង ។ ចំពោះពាក្យយុវតីនេះ យើងតែងសង្កេតឃើញមានប្រែក្លាយទៅជា យុវនីក៏មានដែរ ។ ពាក្យយុវនីក្នុងភាសាបាលីមិនមានប្រើសោះតែម្ដង ឃើញមានតែយុវៈឬយុវនៈដែលក្លាយមកជាយុវនប៉ុណ្ណោះ ប្រែមកថា កំលោះ-ប្រុសកំលោះ, ឯចំណែកពាក្យជាគូគ្នានឹងពាក្យថា យុវៈ យុវនៈនោះ គឺពាក្យយុវតីនេះឯង ត្រង់ពាក្យថា យុវនី ពុំឃើញមានប្រើក្នុងភាសាបាលីទេ ។ ដូចគ្នានឹងពាក្យថាមិត្ត ពាក្យនេះជាពាក្យបាលីដែរ ប្រែថាអ្នកដែលរាប់អានគ្នាជិតដិត ។ ពាក្យមិត្តនេះជាពាក្យកណ្ដាល

ពុំមែនជាពាក្យសំរាប់ប្រើបានតែខាងប្រុសហើយខាងស្ត្រីប្រើពុំបានទោះទេ ឧទាហរណ៍ ដូចជាបាបមិត្ត មិត្តអាក្រក់, កល្យាណមិត្ត មិត្តល្អ គឺសំដៅទៅលើមនុស្សប្រុស ស្ត្រីទាំងអស់គ្នា ពុំមែនបានតែខាងប្រុសតែមួយផ្នែកនោះទេ, ព្រោះយើងពុំដែលឃើញមានពាក្យបាលីថា «បាបមិត្តី កល្យាណមិត្តី» សំរាប់ខាងស្ត្រីគេទេនោះទាល់តែសោះ ផ្ទុយទៅវិញ ស្រាប់តែឃើញខ្មែរយើងនាំគ្នាប្រើដោយច្រើនថាមិត្ត នឹងមិត្តី សំដៅសេចក្ដីថា មិត្តប្រុស មិត្តស្ត្រីទៅវិញ ។

ហេតុដូច្នេះ គួរយើងនាំគ្នាប្រើឲ្យបានត្រឹមត្រូវឡើងវិញ គឺប្រើតែត្រឹម មិត្តៗ តែប៉ុណ្ណោះបានន័យថា មិត្តទាំងប្រុសទាំងស្រីទៅហើយ ។ ដូចគ្នានឹងពាក្យថា មនុស្ស-បុគ្គល-រាស្ត្រ-ខ្មែរ ។ល។ ដូច្នេះដែរ យើងមិនចាំបាច់ បំបែកឲ្យទៅជា មនុស្សី បុគ្គលី រាស្ត្រី-ខ្មែរីដើម្បីឲ្យទៅជាស្ត្រីភេទនោះឡើយ គឺគ្រាន់តែថា មនុស្ស-បុគ្គល រាស្ត្រ-ខ្មែរ តែប៉ុណ្ណោះ បានសេចក្ដីទូទៅទាំងប្រុសទាំងស្រីទៅហើយ ។ ឯពាក្យថា នារី ប្រែថា ស្ត្រី ១ មាត់ប៉ុណ្ណោះឯង ជាគូគ្នានឹងពាក្យថា «នរៈ» នរៈ ថាមនុស្សប្រុស នារី ថាមនុស្សស្រី ។ ទោះបីស្ត្រីចាស់ ឬក្មេងក៏ហៅថានារីបានទាំងអស់ ។

សំនួរទី ៤ លោក គន់-ម៉ន សួរថាពាក្យខ្មែរសុទ្ធដែលយើងសរសេរ

ត្រូវដាក់អក្សរ(រ)ពីមុខដូចជាពាក្យថា សរសេរ ផ្សារ—គំនរ - ទំនេរ ។ល។

ពាក្យទាំងនេះ តើមានលក្ខណៈអ្វីជាមេរៀនឬទេ ? ដើម្បីឲ្យគ្រាន់តែក្រឡេកឃើញភ្លាម អាចសំគាល់បានថាពាក្យនេះត្រូវមានអក្សរ ( រ ) ពីមុខ ឬមិនមានអក្សរ ( រ ) ពីមុខ ? ។

ត្រង់សំនួរនេះ យើងសុំឆ្លើយតបវិញថា ពុំទាន់មានលក្ខណៈអ្វីជាមេរៀន ឲ្យបានទៀងទាត់ពិតប្រាកដនៅឡើយទេ ។ បើតាមការពិចារណាដេញដោលតាមផ្លូវគំនិត ដែលធ្លាប់សំគាល់មកក៏គង់តែអាចឲ្យមានការកត់សំគាល់បានដោយអន្លើ ៗ ដែរ ប៉ុន្តែទោះបីមានការកត់សំគាល់បានខ្លះដូច្នោះ ក៏យើងមិនអាចនឹងយកមកបកស្រាយជូនជាផ្លូវការបានឡើយដែរ ព្រោះវចនានុក្រម ដែលជាក្បួនធំបំផុត នៃអក្សរសាស្ត្រយើង លោកពុំមានឲ្យអត្ថន័យអ្វីសោះអំពីរឿងនេះ ។ ហេតុដូច្នេះ បើយើងបកស្រាយជូនតាមផ្លូវគំនិតនោះទៅ ខ្លាចក្រែងផ្ទុយគ្នានឹងគំនិតរបស់វចនានុក្រម ។

ដូច្នេះ សុំអស់លោក-អ្នករៀននិយមទៅតាមការចំណាំរបស់ខ្លួនរៀងៗទៅចុះ ព្រោះករណីនេះពុំទាន់ជាការហួសវិស័យរបស់យើងម្នាក់ ៗ ដែលជាអ្នករៀនសូត្រនៅឡើយទេ បើយើងប្រៀបធៀបរឿងនេះទៅនឹងអក្សរសាស្ត្របារាំងវិញឃើញថាពុំទាន់ស្មើគ្នា នឹងពាក្យរបស់បារាំងមួយម៉ាត់ ១ ដែលអ្នករៀនត្រូវកត់ចំណាំឲ្យចាំថា ពាក្យនេះជាបុល្លិង្គ ឬជាឥត្ថីលិង្គនោះផងដែរឡើយ ។

## ផ្នែកកំណត់និងប្រវត្តិការណ៍

# មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យលោក ទី ១១

*លោក ភ៉យ-ប៉ុក រៀបរៀង*

កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ ១៩៦០ វេលាម៉ោង ១៦ នៅសា-លាបាលីរងវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ ។ មានការជួបជុំពុទ្ធបរិស័ទទាំងភេទបព្វជិត និងគ្រហស្ថចំនួនច្រើន ក្រោមបរិយាកាសយ៉ាងស្និទ្ធស្នាល ។

ខាងព្រះសង្ឃមានសម្តេចព្រះសង្ឃនាយកគណៈមហានិកាយជាប្រធាន ព្រមទាំងភិក្ខុសាមណេរជាច្រើន ដែលយើងសុំអភ័យទោសដោយពុំអាចពាយព្រះនាមឲ្យអស់បាន ។

ខាងគ្រហស្ថមានលោក ភ៉យ-ល៊ុត តំណាងក្រសួង ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ និងលោក ភ៉យ-ប៉ុក ប្រធានសមាគមមិត្តពុទ្ធិកមហាវិទ្យាល័យជាដើម និងអស់លោកមន្ត្រីធំតូច ឧបាសកឧបាសិកា ជាច្រើនទៀតដែលយើងសុំអភ័យទោស ដោយពុំបានពាយនាមឲ្យសព្វគ្រប់បាន ។

ម៉ោង ១៦ និង ៣០ នាទី មហាសន្និបាតក៏បានបើកសម័យឡើង ។

ដើមដំបូងលោកកឹយ-ប៊ុក ចាប់ថ្លែងសុន្ទរកថាមួយរៀបរាប់អំពីស្ថានការណ៍សមាគមក្នុងឆ្នាំ ១៩៥៩ ដោយសង្ខេប ហើយនឹងបញ្ជាក់ នូវកិច្ចការជាសារប្រយោជន៍ ដែលសមាគមបានបំពេញមកហើយ នឹងជំហានមិត្តភាពខាងពុទ្ធសាសនានៅកម្ពុជរដ្ឋនឹងពុទ្ធសាសនានៅបរទេសផង ដែលគេបានទទួលស្គាល់សមាគមយើងពេញលក្ខណៈ ។

ទីបំផុតលោក កឹយ-ប៊ុក អំពាវនាវដល់មហាសន្និបាតថា សូមឲ្យអស់លោក ជាពុទ្ធបរិស័ទមេត្តាជួយទំនុកបំរុងសមាគមនេះឲ្យបានរឹងបារឋិតថេរបរិកាលជាយូរអង្វែងតទៅអនាគត ។

លំដាប់ពីនោះលោកម៉ៅ-ម៉ី ក្នុងឋានៈជាអគ្គហេរញ្ញិកក៏ចាប់ថ្លែងរៀបរាប់ពីស្ថានភាពហិរញ្ញវត្ថុ របស់សមាគមក្នុងឆ្នាំ១៩៥៩ដូចតទៅនេះ ៖

១– ប្រាក់ចំណូលមានចំនួន ១០៧.៨៩៦៛០០

២– ប្រាក់ចំណាយមានចំនួន ៦២.៣៦០៛០០

៣ ប្រាក់នៅសល់មានចំនួន ៣៩.៥៣៦៛០០ ក្នុងហិបសមាគមសព្វថ្ងៃ ។

ចប់សេចក្តីថ្លែងការណ៍ហើយលោក ម៉ៅ-ម៉ី ថ្លែងអំណរគុណចំពោះមហាសន្និបាត ។

លំដាប់តទៅទៀត មហាសន្និបាតបានរៀបចំពិធីបោះឆ្នោត រើស

គណៈកម្មាធិការនាយកថ្មី សម្រាប់ឆ្នាំ ១៩៦០ បានតាំងគណៈកម្មការបោះឆ្នោតមួយ គឺលោក កែប-អ៊ុល អាចារ្យវត្តលង្កាជាប្រធាន លោក ស៊ូ-ស៊ុផន និងលោក ផៃ-វៀង ជាលេខាធិការ ។

ក្រោយពីបោះឆ្នោតហើយ មានបេក្ខជន ២០ រូបឈរឈ្មោះសម្រាប់ឲ្យជ្រើសរើសយក ១៥ រូប ធ្វើជាគណៈកម្មាធិការនាយកសម្រាប់ឆ្នាំថ្មី ។

លទ្ធផលនៃការបោះឆ្នោត បានសម្រេចដូចតទៅនេះ ៖

១ អ្នកស្រី សង-សៃ បានឆ្នោត ៤៦

២- លោក ឆាំ-ម៉ុ -ដ- ៤៣

៣ - ឈុន-ប៊ុន -ដ- ៤២

៤- - ហង្ស-ប៉េក -ដ- ៤២

៥ - ពិន-ប៊ុក -ដ- ៤០

៦- - ផេត-ព្រៀ -ដ- ៣៩

៧- អ្នកស្រី ប៉ុ-ស្អាត -ដ- ៣៩

៨- លោក ប៊ិន-ហាក -ដ- ៣៧

៩- អ្នកស្រី ពៅយ-ប៊ុក -ដ- ៣៧

១០- លោក ផៃ-វៀង -ដ ៣៦

១១- - ស៊ូ-ស៊ុផន -ដ- ៣៥

១២– – មាឃ.តុំ –ដ- ៣៤

១៣– – សៅ.វ៉ែន –ដ- ៣៤

១៤ លោកស្រី ម៉ៅញ.ផាត –ដ- ៣២

១៥– លោក ជា.ទន់ –ដ- ៣១

រួចហើយលោកប្រធានក៏បានប្រកាស ជម្រាបមហាសន្និបាតថា: បេក្ខជនទាំង ១៥ រូបខាងលើនេះ ដែលបានឆ្នោតច្រើនជាងគេ ត្រូវបានតែងតាំងជាគណ:កម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦០ ។

បន្ទាប់ពីការប្រកាសលទ្ធផលមក សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណ:មហានិកាយ បានមិនត្រឡប់លើវេទិកាថ្លែងរៀបរាប់អំពីសមាគម ដែលគាត់ធ្លាប់បានទៅវិញទៅមកនៅក្នុងសមាគមដូចគ្នា ព្រមទាំងប្រទានដំបូន្មានដល់អស់លោកសមាជិកសមាជិកា ហើយបានរៀបរាប់អំពីផ្លូវលោក និងផ្លូវធម៌ ដើម្បីជាគ្រឿងប្រតិបត្តិតទៅ ។ លុះចប់ហើយ សម្ដេចប្រទានពរសព្វសាធុការដល់អស់លោកដែលបានជាប់ឆ្នោតថ្មីនេះឲ្យបានប្រកបដោយសេចក្ដីសុខចំរើនតទៅ ។

មហាសន្និបាតបានលើកពេលប្រជុំ នៅវេលាម៉ោង ១៨ ក្រោមបរិយាកាសយ៉ាងរីករាយបំផុត ។

# សុន្ទរកថា នៃលោកប្រធានសមាគម

សូមនមស្ការសម្ដេច និងព្រះថេរានុត្ថេរៈទាំងឡាយ សូមជំរាបព្រះតេជគុណ លោក-អ្នក លោកស្រី អ្នកស្រីទាំងឡាយ ។

សមាគមមិត្តពុទ្ធិកវិទ្យាល័យ សូមថ្លែងនូវសេចក្ដីសោមនស្សក្រៃពេក ចំពោះសម្ដេច ចំពោះព្រះថេរានុត្ថេរៈទាំងឡាយ និងព្រះតេជគុណលោក-អ្នក លោកស្រី-អ្នកស្រី ដែលបាននិមន្តបានអញ្ជើញមកកាន់មហាសន្និបាតនេះ ដើម្បីជាកិត្តិយសចំពោះសមាគមយើង សមាគមសូមសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ហើយជាលំដាប់តទៅ សមាគមសូមពិតថេរដីកាសម្ដេច ព្រះថេរានុត្ថេរៈទាំងឡាយ និងជំរាបអស់លោកអ្នកដូចតទៅ ៖

១ សមាគមបានព្យាយាមប្រមូលសិស្សានុសិស្ស និងមិត្តសាលាបាលីទាំងឡាយ ដែលមានប្រាថ្នាលើកដំកើងភាសានិងអក្សរជាតិ បានចំនួនសមាជិកដូចតទៅនេះ ៖

- កិត្តិយសសមាជិក ៨ នាក់
- ជនក – ៨ នាក់
- ឧបការី – ៥ នាក់
- ពាយក – ៥២ នាក់

- កម្មិក សមាជិក ៦០៥ នាក់

- បាសាទិក - ៨២៧ នាក់

បូករួម ១.៥៤០ នាក់ ឆ្នាំ ១៩៥៩

ក្នុងឆ្នាំ ១៩៥៨ មានចំនួន ១ ៤៥២ នាក់ ឃើញកើនជាងឆ្នាំ ចាស់ ៨៨ នាក់ ។

២- បានឧបត្ថម្ភអ្នកសិក្សាភាសាបាលីនិងភាសាជាតិ ដោយសម្ភារៈ និងសីលធម៌ គឺ

កាលពីថ្ងៃទី ១៦-១៧ ធ្នូ ១៩៥៩ សមាគមបានធ្វើពិធីបុណ្យ ព្រហ្មទានចែកផ្គាំងដល់សមណសិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ចំនួន ៤៥ រូប ដែលទើបនិមន្តទៅបន្តការសិក្សានៅគ្រឹះស្ថាននេះ ជា លើកដំបូងបង្អស់ ដើម្បីញុំាងទឹកព្រះទ័យលោកឲ្យខំព្យាយាមសិក្សាត- ទៅទៀត ។

៣- បានបង្កើតឲ្យមានការបោះពុម្ពទស្សនាវដ្តី និងសៀវភៅ ផ្សេងៗ ដើម្បីពង្រីកអក្សរសាស្ត្រខ្មែរ ។

ចំពោះបញ្ហាទស្សនាវដ្តីនេះ សមាគមបម្រុងនឹងបោះពុម្ពទៅថ្ងៃ ក្រោយជាមិនខាន តែក្នុងឆ្នាំ ១៩៥៩ នេះ បានជាខានព្រោះសមាគម មានថវិកាទន់ខ្សោយ ។

៤– បានបង្កើតឲ្យមានបណ្ណាល័យសម្រាប់សមាគម បណ្ណាល័យនេះបានចំរើនតាមលំដាប់រៀងរាល់ឆ្នាំដោយមានអ្នកសប្បុរសធ្វើអំណោយសៀវភៅជាច្រើន ។

៥– បានសង្គ្រោះដល់លោក-អ្នកមានប្រាជ្ញាវាងវៃឲ្យទៅចេញសិក្សានៅប្រទេសក្រៅ ។

សមាគមបានបម្រុងនឹងបញ្ជូនគង់ ពលឆាប់-ឆាប់នេះ នូវព្រះមហាស៊ុន សារឿម វត្តលង្កា ដោយសហារូបករណ៍នៃរដ្ឋាភិបាលប្រទេសឥណ្ឌា ។ បេក្ខជនភាពនៃព្រះមហាអង្គនេះបានទទួលសេចក្តីយល់ព្រមពីមន្ទីរស្តីការនាយករដ្ឋមន្ត្រី នឹងព្រះរាជានុញ្ញាត នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ហើយនៅតែកំណត់កាលបរិច្ឆេទនឹងនិមន្តទៅ ។

៦–កាលពីថ្ងៃទី ៤-៥ មេសា ១៩៥៩ សមាគមបានរួបរួមជាមួយពុទ្ធិកសមាគមកម្ពុជាបានធ្វើទក្ខិណានុប្បទានដាក់បាត្រព្រះសង្ឃ ថ្វាយព្រះរាជកុសលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះឧបយុវរាជ ដោយពេលនោះ សម្តេចព្រះឧបយុវរាជទ្រង់កំពុងអាពាធបានស្តេចយាងទៅប្រទេសបារាំង ដើម្បីព្យាបាលរោគព្រះអង្គ ។

៧–កាលពីថ្ងៃទី ១៩ ធ្នូ ១៩៥៩ សមាគមមិត្តពុទ្ធិកវិទ្យាល័យបានធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធ ព្រះសពព្រះ

តេជគុណព្រះមុនីកោសល សោម-ឈុន វិមលបញ្ញោ អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ មេគុណខេត្តកណ្ដាល ចៅអធិការវត្តនិពេធរង្សី ដែលទទួលអនិច្ចធម្មពីថ្ងៃអង្គារ ទី ៦ តុលា ១៩៥៩ ដោយព្រះតេជព្រះគុណអង្គនេះ លោកជាបុព្វការីចំពោះសមាគមយើង ។

៨- សមាគមបានធ្វើការប្រស្រ័យទាក់ទងនឹងស្ថានឯកអគ្គរដ្ឋទូតប្រទេសឥណ្ឌា ប្រចាំក្រុងកម្ពុជា ដើម្បីសុំអាហារូបករណ៍ចំពោះសមណនិស្សិតដែលនិមន្តទៅសិក្សាឯមហាវិទ្យាល័យនាលន្ទា ខេត្តបត្នះ ប្រទេសឥណ្ឌា គឺព្រះមហា ពី-យ៉ាវ ១ ព្រះមហាប៉ែន-សាអឿន នឹងព្រះមហាអ៊ុក-អ៊ឹន ក្នុងឆ្នាំ ១៩៦០-៦១ ។

៩–សមាគមបានធ្វើការប្រស្រ័យទាក់ទងនឹងក្រុមមូលនិធិអាស៊ី ដើម្បីឲ្យក្រុមនេះជួយឧបត្ថម្ភអាហារូបករណ៍ ចំពោះសមណនិស្សិត អាំ-សួន នឹងមាស-ចន ដែលនិមន្តទៅសិក្សាឯមហាវិទ្យាល័យពារាណសី-ប្រទេសឥណ្ឌា ក្នុងឆ្នាំ ១៩៦០-៦១ ។

ម្យ៉ាងទៀត ក្រុមមូលនិធិអាស៊ីបានសន្យាថា ក្នុងឆ្នាំ១៩៦០នេះ នឹងធ្វើអំណោយចំពោះសមាគម នូវម៉ាស៊ីនអង្គុលីលេខភាសាបារាំងមួយគ្រឿងទុកសម្រាប់ប្រើប្រាស់ក្នុងការិយាល័យសមាគម ។

នេះជាលទ្ធផលដែលក្រុមអភិបាលនៃសមាគមបានព្យាយាមបំពេញករណីយកិច្ចសព្វគ្រប់ក្នុងឆ្នាំ១៩៦០ ខ្ញុំសូមសរសើរចំពោះសមាជិកក្រុម

អភិបាលថា ព្រះតេជគុណ-លោកអ្នក-លោកស្រី-អ្នកស្រីបានព្យាយាមធ្វើតាមមុខការរៀងៗខ្លួន ជាយ៉ាងម៉ឺនម៉ាត់គ្រប់ៗគ្នា ។ សមាគមដែលនឹងអាចចំរើនទៅបាន មកពីសមាជិកនៃក្រុមអភិបាលខំស្វាហាប់អញ្ជើញមកប្រជុំដើម្បីនឹងប្តូរយោបល់គ្នា ។ ម្យ៉ាងវិញទៀត សូមជំរាបថា សមាជិកនៃសមាគមទាំងមូលត្រូវធ្វើកិច្ចជាប្រយោជន៍សមាគមគ្រប់គ្នា ព្រោះមនុស្សម្នាក់ធ្វើការមិនមានអានុភាពស្មើនឹងសមាគម ដែលធ្វើការដោយសាមគ្គីធម៌នោះទេ, ឯសមាគមបើចេះរៀបចំអង្គការឲ្យបានស្រួលនឹងបានឡើងទៅកាន់វឌ្ឍនធម៌ដោយឆាប់រហ័សមិនខាន ។

បើពិចារណាឲ្យហ្មត់ចត់ទៅទៀត សមាគមយើងមានវត្ថុធាតុពីរបែប

១– ក្រុមអភិបាល,

២– សមាជិក សមាជិកាសមាគម ។

ក្រុមអភិបាលដែលនឹងធ្វើឲ្យចំរើនសមាគមបានលុះតែក្រុមនោះមាន :

ក– កម្មវិធី សកម្មភាព ហើយត្រូវប្រព្រឹត្តប្រតិបត្តិឲ្យបានសម្រេចនូវលទ្ធផលដ៏ប្រសើរនៃកម្មវិធីនោះ ៗ ។

ខ– ត្រូវប្រព្រឹត្តតាមមុខការរៀងៗខ្លួន ហើយញ៉ាំងសកម្មភាពឲ្យមានឡើងចំពោះកិច្ចការនោះ ៗ ។

គ– ត្រូវឧស្សាហ៍មកប្រជុំរឿយៗ ដោយសេចក្តីអញ្ជើញពីប្រធាន

សមាគម ។

ឃ- ត្រូវរិះរកនូវមធ្យោបាយដែលប្រព្រឹត្តទៅ ហើយរបទាសមាគមឲ្យមានវឌ្ឍនធម៌តទៅ ។

ង- ត្រូវពន្យល់បំភ្លឺញាតិមិត្តឲ្យយល់ជាក់ច្បាស់ថា ការចូលមកជាសមាជិកនៃសមាគមជាការប្រសើរ ព្រោះថា កិច្ចធ្វើការដោយគ្នាច្រើន ហើយព្យាយាមធ្វើដោយសាមគ្គីធម៌ តែងបានផលប្រយោជន៍ជាងអ្នកដែលធ្វើការម្នាក់ៗ បើការនោះធ្វើដោយសេចក្តីពេញចិត្ត ដោយគិតតែប្រយោជន៍សមាគមម្យ៉ាងផងទៀត នោះរឹតតែគាប់ប្រសើរ ។

២- សមាជិក-សមាជិកានៃសមាគម

សមាជិក-សមាជិកា នៃសមាគមត្រូវទុកសមាគមនេះដូចជាគ្រួសារ ហើយត្រូវទុកសមាជិក-សមាជិកាទាំងឡាយជាបងប្អូនរួមសាច់ឈាម ជាមួយគ្នា ការសុខទុក្ខបងប្អូនក្នុងគ្រួសារ ត្រូវជួយឧបត្ថម្ភគ្នាទៅវិញទៅមកដោយការគោរព មិត្តភាព សាមគ្គីធម៌យ៉ាងណាមិញ សមាជិកសមាជិកាក៏ដូច្នោះឯង ។ សមាជិក-សមាជិកា ទាំងអស់នៃសមាគមត្រូវប្រមូលជាពួក ជាក្រុមធ្វើកិច្ចការអ្វីមួយជាប្រយោជន៍សមាគមមានការស្វែងរកសមាជិកថ្មី ១ ការបោះពុម្ពទស្សនាវដ្តីជាសំឡេងសមាគម ១ ការចូលមកក្នុងក្រុមឃោសនា ១ ការធ្វើអ្វីមួយជាប្រយោជន៍ពុទ្ធសាសនា ១ ។ល។

ការរំលឹកដាស់តឿនមហាសន្និបាតមកប៉ុណ្ណេះ ដើម្បីជាគតិទុកសម្រាប់ឲ្យមហាសន្និបាត យកសេចក្តីនេះទៅពិចារណាសាកសួរដេញដោលឲ្យអស់សង្ស័យ ដើម្បីនឹងរិះរកនូវមធ្យោបាយផ្សេងៗ ដើម្បីជាប្រយោជន៍ដល់សមាគមយើងតទៅអនាគត ។

អវសាន ខ្ញុំសូមឧទ្ទិសកុសលរាសីដែលសមាគមធ្វើតាំងពីឆ្នាំ១៩៤៩មក ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ សូមព្រះអង្គគង់ជាសុខក្នុងសិរីរាជសម្បត្តិអស់កាលជាអង្វែងតទៅ ។

សូមឲ្យពុទ្ធមាមកជនទាំងឡាយ ទាំងបុរស-ស្រី-ទាំងបព្វជិត-គ្រហស្ថ បានប្រកបដោយសិរីសួស្តីជ័យមង្គលទាំងឡាយគ្រប់ប្រការ !

សូមឲ្យសមាគមចម្រើនស្ថិតស្ថេរចេរកាលតទៅអនាគត !

## សមាសភាពនៃគណៈកម្មាធិការនាយកថ្មីសម្រាប់ឆ្នាំ១៩៦០

១- លោក ភ៉យ-ប៊ុក ប្រធាន

២- លោក អ៊ឹង-ទួន អនុប្រធានទី ១

៣- លោកស្រី គួច-ស្អាត អនុប្រធានទី ២

៤- លោក ហ៊ៅ-ម៉ី អគ្គហេរញ្ញិក

៥- លោក ចឹង-ហារិត លេខាធិការ

៦- លោក សូរ-ស៊ីផន អនុហោរញ្ញិក

៧- លោក សៅ-វ៉ែន . . . . .

៨- លោក ឆៃ.វង្ស អនុលេខាធិការ

៩- លោក ហង្ស-បេត . . . . .

១០- លោក ជា-ខន់ បណ្ណារក្ស

១១- លោក មាឃ-តុំ . . . .

១២- លោក ផេង.ជ្រីវ ស្នងការ

១៣- លោកស្រី សម-ណៃ . . . .

១៤- លោកស្រី ក៉យ-ប៊ុក . . . .

១៥- លោកស្រី ម៉ោញ-ឆាត . . . .

---

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិឃ្នី ស្រី. កិរិយាភ្លេច ។

អតិបត្វរ គុ. ដែលលឿនក្រៃលែង ។

អតិចរ៑ ឥ.គុ. ប្រព្រឹត្តក្រៃពេក, ប្រព្រឹត្តកន្លង ។

អតិប្រលាប នបុំ កិរិយាត្រឡប់ត្រឡិន, កិរិយាឡេះឡោះ ។

អតិចិត្រម៑ ក្រិ. វិ. ដោយវិចិត្រផ្សេងៗ ។

អតិចិរ គុ. ដែលយូរក្រៃលែង ។ *អតិចិរស្យ* ឬ *អតិចិរម៑* ក្រិ.វិ. អស់កាលយូរណាស់ហើយ ។

អតិចេឞ្ដ ឆាគុ. ប្រឹងប្រែងក្រៃលែង ។

អតិច្ឆន្ទ បុំ. ចិត្តស្រាល, ចិត្តរហាស់; សេចក្ដីប្រាថ្នាក្រៃពេក ។

អតិច្ឆន្ទស៑ គុ. ដែលមានឆន្ទក្រៃលែង ។ នបុំ. ស្រី. ឈ្មោះរង្កាស់ ។

អតិច្ឆេទ បុំ. ការមុតក្រៃពេក, ការផ្ដិលផ្ដាច់ ។

អតិច្ឆេទ្យ គុ. ដែលគប្បីមុតក្រៃពេក ។

អតិជគតី ស្រី. ឈ្មោះរង្កាស់ ។

អតិជន គុ. ដែលឥតមានមនុស្ស ។

(នៅមានត)